ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ៤ ខែមេសា ព. ស. ២៤៩៩ គ. ស. ១៩៥៦

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


| ផ្នែកសាសនា | | ទំព័រ |
|---|---|---|
| — វិបារណកថា (ដំណើរជីវិត) | យុគបណ្ណានុរ័ក្ស ប៊ូ-ប៉ូ | ៣០៣ |
| — សង្ឃសរណកថា | ព្រះមហា ហ៊ុន-ប្រិញ | ៣១៣ |
| — បាឋកថារឿងពុទ្ធរូបបុរាណ (តមក) | យុគអគ្គកោវិទជា-យូរ ប្រែ | ៣២៣ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — រឿងអ្នកស្នេហាជាតិ សាសនា មហាក្សត្រ (ត-ចប់) | យុគបណ្ណានុរ័ក្ស ប៊ូ-ប៉ូ | ៣៣០ |
| — រឿងព្រះបាទរុសភ៉នសាជ និងព្រះនាងសេហេរិស្ដានី (តមក) | អ្នកស្រី សារិះយ៉ាន ប្រែ | ៣៣៦ |
| — សុភាសិតរាជនីតិ ពាក្យកាព្យ (តមក) | អ្នកឧកញ៉ា នៅ | ៣៤៤ |
| — ពេជ្រព្រះរាជា (តមក) | លោក ស៊ុន-ហ៊ាន ប្រែ | ៣៤៩ |
| — រឿងសាមកុក (តមក) | ឧកញ៉ា នូ-កន | ៣៥៧ |
| — រឿងបល្ល័ង្កទិព្យ (តមក) | លោក រ៉ាយ-ប៊ុក ប្រែ | ៣៦៥ |
| **កំណត់និងប្រវត្តិការណ៍** | | |
| — សេចក្ដីកត់ហេតុអំពីគ្រោងការណ៍បុណ្យពាក់កណ្ដាល ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា | ក្រសួងធម្មការ | ៣៧០ |
| — ពិធីសម្ពោធឆ្លងមន្ទីរពេទ្យព្រះសង្ឃ | ពុទ្ធសាសនបណ្ឌិត្យ | ៣៨២ |
| — ពិធីបុណ្យព្រហ្មទានវិថីនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ | លោក បាប-ពិន | ៣៩៨ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២៣០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:

| | | Page |
|---|---|---|
| — Editorial (la vie) . . . . . | M. BOU-PO . . . . . . . . | 303 |
| — Sanghasaranakatha . . . . . . | Moha HUN-PRENH . . . . . | 313 |
| — Les statues Bouddhiques primitives (suite) . . . . . . . . | Traduit par M. CHEA-YOU | 323 |

### PARTIE LITTÉRAIRE:

| | | |
|---|---|---|
| — Le Patriotisme (fin). . . . . . | M. BOU-PO . . . . . . . | 330 |
| — Le Roi RUZVANCHAD et la Princesse CHEHERISTANI (suite) . . . . . . . . . . | Traduit par Mme PICH-SAL née SRIN-SARIS-YANN .... | 336 |
| — Subhasitarajaniti (suite) . . . | Oknha NEOU . . . . . . | 344 |
| — Conte "Le Diamant du Raja" (suite) . . . . . . . . . . | Traduit par M. SIN-HEAN | 349 |
| — Histoire de SAMKOK (suite). . | Oknha NOU-KAN . . . . . | 357 |
| — Les trente deux récits du TRONE (suite) . . . . . . . | Traduit par M. RAY-BUC | 365 |

### NOTES ET CHRONIQUES:

| | | |
|---|---|---|
| — Procès-verbal de la fête du 2.500 anniversaire de la mort du Bouddha . . . . . . . . . . | Ministère des CULTES . . . | 370 |
| — Inauguration de l'Hôpital des Bonzes . . . . . . . . . . | Institut Bouddhique . . . . . | 382 |
| — Distribution des prix à l'Ecole Supérieure de Pâli . . . . . | M. CHAP-PIN . . . . . | 398 |

Prix d'abonnement annuel (comprenant 12 numéros) 230$00

# ផ្នែកសាសនា

## វិចារណកថា

ដំណើររបស់ជីវិត

ឃុនបណ្ឌិតរក្សប៊ូ-ប៉ូ រៀបរៀង

---

ជីវិត ជាពាក្យបាលី ប្រែថា "ការរស់នៅ", សម្រាប់មនុស្សសត្វដែលមានវិញ្ញាណ សំដៅយកត្រង់មានខ្យល់ដង្ហើមចេញចូល បើអស់ដង្ហើមពេលណាហើយ ពេលនោះឈ្មោះថា ស្លាប់ ។ ការរស់នៅនិងការស្លាប់នេះ ជាគូសត្រូវនឹងគ្នា តែងប្រយុទ្ធគ្នាយកជ័យជំនះតែរៀងខ្លួនជានិច្ច គ្មានពេលណាឈប់ស្ងៀមទេ បេះតែដណ្ដើមរស់ដណ្ដើមស្លាប់គ្រប់នាទី ។ ឯការរស់និងការស្លាប់ តាមក្បួនពេទ្យថា ស្រេចលើរូបមនុស្សជាអ្នកបេះថែរក្សានឹងមិនបេះថែរក្សាខ្លួនតាមក្បួនអនាម័យ ឬថាស្រេចលើឧសថត្រូវ ឬមិនត្រូវ និងស្រេចលើគ្រូពេទ្យអ្នកប៉ិនប្រសប់និងមិនប៉ិនប្រសប់មើលជម្ងឺ ។ តាមក្បួនពុទ្ធសាសនាថា ការរស់នៅនិងការស្លាប់ស្រេចលើកម្មផល មិនមែនស្រេចលើឧសថត្រូវមិនត្រូវ ឬគ្រូពេទ្យប៉ិនប្រសប់មិនប៉ិនប្រសប់ទេ ។ មតិគ្រូពេទ្យក្នុងលោកនឹងមតិពុទ្ធសាសនាខ្វែងគ្នាយ៉ាងនេះ មិនដឹងវិនិច្ឆ័យឲ្យដាច់ស្រេចទៅតាមមតិណាទេ ប៉ុន្តែសូមលោកអ្នកអានសង្កេតមើលសេចក្ដីបរិយាយតទៅនេះចុះ, មុននឹងបរិយាយខ្ញុំតាំងជាប្រស្នា ៣ យ៉ាង:

- ១.– អ្វីបង្កើតមនុស្ស សត្វ និងវត្ថុផ្សេងៗ?

២.– អ្វីធ្វើឲ្យមនុស្សមានអាយុរស់នៅរហូតដល់ចាស់ជរា ?

៣.– អ្វីធ្វើឲ្យអ្នកមានអាយុវែងនោះបានទទួលសុខទុក្ខខុសគ្នា ?

ប្រស្នាទាំង៣ខនេះ ខ្ញុំនឹងដោះស្រាយតាមមតិ (សេចក្តីយល់ឃើញ) ផ្សេងៗគ្នា ទុកជូនលោកអ្នកអានដូចតទៅនេះ ៖

មតិសាសនាខ្លះ.— សាសនាខ្លះប្រកាន់ថា ព្រះជាអ្នកបង្កើតមនុស្ស បង្កើតសត្វ និងវត្ថុទាំងពួង, ព្រះធ្វើឲ្យមនុស្សមានអាយុវែង, ព្រះធ្វើឲ្យមនុស្សសត្វមានអាយុវែងបានទទួលសុខទុក្ខខុសៗ គ្នា ។

មតិអ្នកវិទ្យាសាស្ត្រ –អ្នកវិទ្យាសាស្ត្រប្រកាន់ថា ហេតុនិងផល បង្កើតមនុស្ស សត្វ និងវត្ថុទាំងពួង ។ ហេតុផលធ្វើឲ្យមនុស្សមានអាយុវែង ។ ហេតុផលធ្វើឲ្យអ្នកអាយុវែងបានទទួលសុខទុក្ខខុសៗគ្នា ដ្បិតថា ជីវិតរបស់មនុស្សយើងសព្វថ្ងៃនេះ តាមពិត ជាការធ្វើដំណើរមួយបែប ហៅថា ដំណើររបស់ជីវិត ដែលដើរតាមផ្លូវពេញពោរទៅដោយទុក្ខភយន្តរាយ កាត់សំដៅទៅរកទីរលត់ទុក្ខព្រួយ ជាទុក្ខដែលខ្លួនធ្លាប់បានជួបប្រទះរួចមកហើយនោះឯង មិនថាខ្លួនអ្នកនោះស្គាល់ផ្លូវឬមិនស្គាល់ផ្លូវទេ ជីវិតចេះតែធ្វើដំណើរទៅមុខជាដរាបគ្រប់នាទីឥតឈប់ឈរសោះឡើយ សូម្បីតែដេកលក់ក៏មិននៅស្ងៀមដែរ ។ បើជីវិតដើរទៅទាំងងងឹតងងល់មិនយល់ផ្លូវខុសផ្លូវត្រូវហើយ ជីវិតក៏រមែងទៅប៉ះទង្គិចនឹងឧបសគ្គភយន្តរាយ ដែលមាននៅកណ្តាលផ្លូវជាធម្មតា ជីវិតចេះតែមានទុក្ខព្រួយលំបាកតាមផ្លូវរហូតទៅ ។ ឯដំណើររបស់ជីវិត

នេះ មិនមែនជាដំណើរដើរទៅដោយជើងទេ ជាដំណើររបស់ចិត្ត ជាផ្លូវឥតអ្នកណាមើលឃើញដោយភ្នែកទេ ជាផ្លូវខ្ពស់ផុតហួសផ្លូវកាយ ឬផ្លូវជើង ។ ហេតុនោះ បានជាអ្នកប្រាជ្ញពីបុរាណតក់ស្លុតខ្វល់ចិត្តខ្លាចដំណើររបស់ជីវិតនេះខ្លាំងណាស់ ហើយខំព្យាយាមរៀបរៀងក្បួនច្បាប់សម្រាប់ពន្យល់ពីដំណើររបស់ជីវិតទុកជាយ៉ាងច្រើន ៗ

តាមធម្មតារបស់ផ្លូវ ទោះបីជាផ្លូវចិត្តក្តី ជាផ្លូវដើរដោយជើងក្តី ត្រូវតែប្រកបដោយអង្គគុណច្រើនប្រការ ទើបអ្នកដំណើរបានសុខសប្បាយ គ្មានភយន្តរាយកណ្តាលផ្លូវ ៗ មែនពិត ផ្លូវជើងដ៏ឆ្ងាយដាច់ស្រយាល ត្រូវតែមានស្ពានឆ្លងទឹក, មានម្លប់ដើមឈើ, មានទីស្នាក់អាស្រ័យ, មានការគ្រប់គ្រងរក្សាទៅតាមចន្លោះផ្លូវ, មានគាបករល្អរកបរិភោគបានតាមផ្លូវហូតទៅ ៗល ៗ លុះតែផ្លូវណាមានរបស់ប៉ុណ្ណោះជាដើម ទើបអ្នកដំណើរទៅតាមផ្លូវនោះបានសុខសប្បាយ គ្មានគ្រោះថ្នាក់កណ្តាលផ្លូវ អាចដើរដល់ទីកន្លែងដែលខ្លួនដៅទុកបានដោយសុវត្ថិភាព ៗ ផ្លូវជើងនេះយ៉ាងណា បំណែកផ្លូវរបស់ជីវិតក៏យ៉ាងនោះដែរ សូម្បីជីវិតធ្វើដំណើរសំដៅទៅរកទីបំផុតទុកតែម្យ៉ាងប៉ុណ្ណោះ ក៏ពិតមែនហើយ ប៉ុន្តែត្រូវឲ្យប្រកបដោយអង្គគុណច្រើនប្រការ ដូចជាផ្លូវជើងនោះដែរ ៗ ឯអង្គគុណសម្រាប់ផ្លូវរបស់ជីវិតឲ្យបានសុខសប្បាយចំរុងចំរើននោះ មាន ៨ (១) យ៉ាងគឺ :

---

១ ស្រង់ចាកទស្សនាវដ្តី អនុស្សរណៈមហាចុឡាលង្ករណ៍ រាជវិទ្យាល័យ ភាសាថៃ ។

១.— សាសនា ជាអង្គគុណដ៏សំខាន់ អាចជួយទំនុកបម្រុងជីវិត ឲ្យមានសេចក្ដីរីករាយ ជ្រះថ្លា ឲ្យជឿទុកចិត្តខ្លួនឯង ឲ្យរស់នៅជាសុខ សប្បាយ ត្រជាក់ត្រជុំមិនឲ្យក្ដៅក្រហាយ ។ សាសនាប្រៀបដូចទឹក សម្រាប់ទំនុកបម្រុងព្រឹក្សាជាតិ ឲ្យត្រជាក់ត្រជុំស្រស់បស់លូតលាស់ធំ ឡើងរាល់វេលា ។

២.— ប្រាជ្ញា សំដៅយកប្រាជ្ញាដែលមានមកអំពីកំណើត (ជាតិក-ប្បញ្ញា) ។ ប្រាជ្ញានេះជាអង្គគុណដ៏សំខាន់ អាចជួយឲ្យកើតឧត្ដមគតិ ដ៏មានកម្លាំងរឹងប៉ឹងក្នុងការប្រតិបត្តិសាសនា ឬធ្វើកិច្ចការដទៃ ៗ ឲ្យជឿទុកចិត្តខ្លួនឯង ឲ្យកើតសេចក្ដីព្យាយាម និងឲ្យកើតគុណធម៌ដទៃ ៗ ទៀត ដ៏ជាគ្រឿងកម្លាំងយ៉ាងសំខាន់ដូចគ្នាទាំងអស់ ធ្វើចិត្តមិនឲ្យរួញរា មិនឲ្យលេះណោះសារា ឬថយក្រោយ ។ បើនិយាយដោយសរុប ៖ ប្រាជ្ញាជួយឲ្យមានសមត្ថភាពទៅជាអ្នកប្រាជ្ញ ឬជួយឲ្យគោលបំណងរបស់ខ្លួនបានសម្រេចផលដូចប្រាថ្នា ។

៣.— វិទ្យាសាស្ត្រ ជាអង្គគុណ អាចជួយកែតម្រង់ប្រាជ្ញា ឲ្យធ្វើការត្រង់ផ្លូវដែលនឹងឲ្យបានសម្រេចផលល្អ ព្រោះថាមនុស្សខ្លះ កើតមកមានប្រាជ្ញាពីកំណើតឈ្លាសវៃណាស់, ប៉ុន្តែបើមិនរៀនសូត្រ ចំណេះវិជ្ជាណាមួយសោះ អ្នកនេះនឹងធ្វើការអ្វី ៗ ច្រើនតែចួស ក្លាយខូចខាតផលប្រយោជន៍ ដ្បិតបេះតែគិតស្មាន ៗ ផ្សែផ្សំយក

តាមគំនិតរបស់ខ្លួន គ្មានកាន់ក្បួនច្បាប់អ្វីសោះ ឈ្មោះថាគ្មានវិទ្យាសាស្ត្រជួយតម្រិតម្រង់ប្រាជ្ញាផង ។

៤.— **សិល្ប:** ជាអង្គគុណ អាចជួយឲ្យចិញ្ចឹមជីវិតបានងាយៗ ព្រោះការចេះកិច្ចការផ្សេងៗ មានការជាងគំនូរ, ជាងឆ្លាក់ជាដើម រហូតដល់ការរាំ, ការច្រៀង និងតូរ្យតន្ត្រី ជាការលម្អឲ្យជីវិតធ្វើដំណើរទៅបានសុខស្រួល ។

៥.— **ភូមិធម៌** ភូមិធម៌ក្នុងទីនេះសំដៅយកសេចក្តីសុចរិតល្អ សេចក្តីពិតត្រង់ ។ បើអ្នកណាប្រព្រឹត្តសុចរិតស្លូតត្រង់ល្អ, ប្រកាន់សច្ចៈហើយ អ្នកនោះឈ្មោះថាមានធម៌នៅក្នុងខ្លួន ។ ធម៌នេះអាចជួយឲ្យកើតបុគ្គលិកលក្ខណៈ គឺធ្វើឲ្យកើតកិរិយាមារយាទពេញលក្ខណៈជាមនុស្ស មានការនាំឲ្យអ្នកផងស្រឡាញ់រាប់អានចង់សេពគប់យកជាមិត្ត អាចធ្វើជីវិតឲ្យតាំងនៅក្នុងឋានៈជាបូជនីយបុគ្គលគួរគេគោរពបូជា ដើម្បីជាទីពឹងដល់ខ្លួនឯងបានផង ដើម្បីទង់ទាញជីវិតរបស់មនុស្សឯទៀតឲ្យរស់នៅជាសុខសប្បាយតាមខ្លួនផង ។ ចំណែកមនុស្សដែលចេះសិល្ប: ហើយ ប៉ុន្តែខុសភូមិធម៌ ចាត់ជាមនុស្សមិនបានការ ព្រោះដំណើរជីវិតរបស់អ្នកឥតធម៌នោះ គ្មានសុខ គ្មានចំរើន ។

៦.— **សេចក្តីចេះដឹង** ជាអង្គគុណដ៏សំខាន់ អាចជួយឲ្យមានកម្លាំងក្នុងការត្រិះរិះពិចារណាវិនិច្ឆ័យរឿងរ៉ាវផ្សេងៗ, ក្នុងការស្រាវជ្រាវពិសោធមើល, ក្នុងការកែសម្រួលដោះស្រាយឧបសគ្គផ្សេងៗ

ទឹងក្នុងរឿងដទៃទៀតបានយ៉ាងឆ្ងាយទូលាយ ដើម្បីរកផ្លូវដែលនឹងធ្វើដំណើររបស់ជីវិតឲ្យប្រព្រឹត្តទៅបានស្រួល ៗ ងាយ ៗ ។

៧.— ស្មារតី ជាអង្គគុណដ៏សំខាន់ អាចជួយឲ្យកើតសមត្ថភាពឬបដិភាណ (ប្រាជ្ញា) ក្នុងការធ្វើដំណើររបស់ជីវិតឲ្យបានសម្រេចផលល្អយ៉ាងជាប់ស្រេច គ្មានគ្រោះថ្នាក់កណ្តាលផ្លូវ ព្រោះបាននឹករលឹកដឹងផ្លូវវៀចឬត្រង់ ខុសឬត្រូវ តាមតម្រាយនៃសេចក្តីចេះដឹងដែលមានក្នុងខ្លួនស្រាប់មកហើយ ។ ស្មារតីជាធំបំផុតក្នុងដំណើររបស់ជីវិតគ្រប់យ៉ាងគ្រប់លំដាប់ខ្យល់ដង្ហើមចេញចូល, ធ្វើឲ្យដំណើររបស់ជីវិតប្រព្រឹត្តទៅបានដោយងាយ, ដោយសម្បូណ៌សប្បាយ ទឹងឲ្យរួចពីភយន្តរាយទាំងពួង ។

៨.— អនាម័យ ជាអង្គគុណដ៏សំខាន់ អាចជួយឲ្យមានកម្លាំងកាយខែងរ៉ែងដ៏ជាបាទដ្ឋាននៃកម្លាំងចិត្ត, ជួយឲ្យកាយធ៌កគ្រួដល់ការងារផ្សេងៗ, ជួយឲ្យចិត្តរីករាយក្លាហាន ដោយឥតរោគធ្ងន់ៗប្រចាំនៅក្នុងខ្លួន, ជួយធ្វើរូបកាយមិនឲ្យមានជម្ងឺ ។ បើរូបកាយមិនឈឺចាប់ហើយរមែងមានកម្លាំងខ្លាំងអាចនឹងធ្វើការអ្វីៗ បានតាមចិត្តចង់ ប្រៀបដូចសេះដែលម្ចាស់ថែរក្សាដោយម៉ត់ចត់ ជាពាហនៈអាចដឹកនាំម្ចាស់ឲ្យទៅដល់ទីដៅបានដោយងាយ ដោយឆាប់រហ័ស ។ ឯរូបកាយរបស់យើងប្រៀបដូចខ្លួនសេះ, ចិត្តគំនិតរបស់យើងប្រៀបដូចម្ចាស់សេះ ។ ចុះបើយើងកើតដំបៅត្រង់ដៃឬជើងហើយ តើយើងអាច

នឹងធ្វើការអ្វីៗ បានតាមចិត្តបង់ដែរឬទេ? ចុះបើសេះកើតដំបៅនៅបាទជើងទាល់តែបើកក្រចកចេញបាត់ហើយ តើវានឹងបោលនាំម្ចាស់ទៅរួចដែរឬទេ ? អនាម័យនេះ ជាអគ្គគុណដ៏សំខាន់បំផុត លើសអគ្គគុណ ៧ ខាងដើម ព្រោះថាផ្ទុយទៅវិញ បើយើងកើតជម្ងឺអករបេងតាំងពីក្មេងតូចមកនោះ តើសាសនា, ប្រាជ្ញា, វិទ្យាសាស្ត្រ, សិល្បៈ, ភូមិធម៌, សេចក្ដីចេះដឹង នឹងស្មារតី មាននៅបរិបូណ៌ក្នុងខ្លួនយើងដែរឬទេ? សូមពិចារណាមើលចុះ ។

អគ្គគុណទាំង ៨ ប្រការ ដូចបានពប់មកនេះ កាលបើរួមចូលគ្នាជាកម្លាំងតែមួយហើយ អាចនឹងជួយឲ្យដំណើររបស់ជីវិតរស់នៅបានវែងឆ្ងាយរហូតដល់ចាស់ជរា មិនឆាប់ស្លាប់ពីក្មេង ហើយថែមទាំងធ្វើជីវិតឲ្យបានសេចក្ដីសុខសប្បាយច្រើនផង ឲ្យមានភោគសម្បទបរិបូណ៌ ឬយសសក្ដិជាធំផង ។

ចំណែកមនុស្ស ១ ពួកទៀត វែលមានអាយុវែងដូចគ្នាដែរ ប៉ុន្តែជាអ្នកមានសេចក្ដីទុក្ខព្រួយលំបាកច្រើន ហើយថែមទាំងទលក្រណាស់ផងនោះ ព្រោះតែខ្វះអគ្គគុណ ៨ ប្រការនេះ បើទុកជាមានខ្វះ ក៏មានតែបន្តិចបន្តួចស្ទួចស្ដើងមិនសូវបរិបូណ៌ ។

សព្វថ្ងៃនេះ មតិអ្នកវិទ្យាសាស្ត្រប្រកាន់ថា មនុស្ស, សត្វ នឹងវត្ថុទាំងអស់ដែលកើតមានឡើងក្នុងលោកនេះកើតឡើងតាមធម្មតានៃលោកធាតុ កាលកើតឡើងហើយតែងប្រែប្រួលសាបសូន្យទៅវិញ គឺមនុស្ស

កើតមកក្លាយជាក្មេងតូច លុះយូរទៅធំចាស់ជរាឈឺស្លាប់ជាទីបំផុត, ពូជឈើកាលដុះពន្លកចេញមកពីគ្រាប់ហើយ ក៏ចេះតែចំរើនធំឡើងរាល់វេលាដោយគ្មានអន្តរាយអំពីអ្វីៗ រហូតដល់ធំខ្ពស់អស់ចំណាស់ហើយ ក៏ត្រូវងាប់ទៅវិញ ។

មតិអ្នកវិទ្យាសាស្ត្រប្រកាន់យកហេតុផល (កម្មផល) ថាជាគោលធំបំផុតដូចមតិពុទ្ធ.ដែរ, បដិសេធព្រះអ្នកសាងលោកដូចមតិពុទ្ធៈដែរ គឺគេមិនជឿថា លោកនេះមានព្រះសាងឡើងទេ ។ គេជឿថា លោកនេះកើតឡើងតាមធម្មតានៃលោកធាតុដោយអាស្រ័យហេតុផល (កម្មផល) ។ ហេតុជាក្រសែឲ្យកើតផល ផលជាប់ក្រសែមកពីហេតុ ប្រៀបដូចគ្រាប់កាំភ្លើងមានរំសេវនៅខាងក្នុងសម្រាប់ឆេះផ្ទុះស្រាប់ហើយ ប៉ុន្តែបើមនុស្សមិនចុចទ្រនិចឲ្យវាឆេះទេ វាក៏ចេះតែនៅស្ងៀមរហូតទៅ បើគេចុចទ្រនិចវាកាលណា វាក៏ឆេះផ្ទុះក្នុងកាលនោះភ្លាម ត្រង់តួគ្រាប់កាំភ្លើងមានរំសេវនៅខាងក្នុងទុកជាពូជរបស់មនុស្ស សត្វនឹងវត្ថុទាំងពួង, ត្រង់កិរិយាចុចទ្រនិចទុកជាហេតុ (កម្ម), ត្រង់វាឆេះផ្ទុះចេញទៅទុកជាផល ។

មតិអ្នកវិទ្យាសាស្ត្រប្រកាន់យកហេតុផល (កម្មផល) ថាជារបស់សំខាន់ណាស់, គោលទូទៅរបស់វិទ្យាសាស្ត្រនោះនៅត្រង់ហេតុផល ។ អ្នកវិទ្យាសាស្ត្រ កាលគេនឹងជឿប្រកាន់យករបស់ណាមួយ តែងពិសោធន៍ស្រាវជ្រាវរកហេតុផលឲ្យឃើញពិតជាមុនសិន, នេះជាគោលដែលគេប្រតិបត្តិជាប់ជានិច្ច ។ ការដែលជឿប្រកាន់ស្មានៗដោយមិនបាន

ដើញដោយរកហេតុផលឲ្យឃើញពិតទេ នោះមិនមែនជាគោលនៃវិទ្យាសាស្ត្រឡើយ ។

មតិពុទ្ធ: ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាន់ថា "លោកនេះ គ្មានអ្នកណាកសាងឡើងទេ កកើតឡើងឯង១ តាមធម្មតា, ដូចជាមតិអ្នកវិទ្យាសាស្ត្រដែរ ។ ព្រះសព្វញ្ញូពុទ្ធជាម្ចាស់ ព្រះអង្គប្រកាន់ហេតុផលនិងការពិសោធន៍រកហេតុផលជាគោលសំខាន់បំផុត ដូចមតិអ្នកវិទ្យាសាស្ត្រដែរ សឹងមានពាក្យជាសំអាងដែលព្រះអស្សជិត្ថេរសំដែងពីមតិពុទ្ធ: ដោយសារុបគោលធម៌យ៉ាងខ្ពង់បំផុតថា 'របស់ទាំងពួង (ធម៌) មានហេតុជាដែនកើតមុន, កាលបើហេតុរលត់ហើយ ផលក៏រលត់ទៅតាម, ហេតុនិងផលជារបស់ដែលត្រូវតែជាប់ទាក់ទងនឹងគ្នាជានិច្ច

(យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ,

តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោតិ)" ។

មតិពុទ្ធ: កងព្រះសូត្រមួយ បានដំណាលថា កាលព្រះពុទ្ធអង្គគង់ព្រះជន្មនៅឡើយ មានមាណពម្នាក់ជាអ្នកចេះដឹងវិទ្យាសាស្ត្រច្រើនយ៉ាង បានចូលទៅក្រាបទូលសួរព្រះពុទ្ធជាម្ចាស់អំពីរឿងដែលមនុស្សកើតមកប្លែក១ គ្នា អ្នកខ្លះល្អ, អ្នកខ្លះអាក្រក់, អ្នកខ្លះមាន, អ្នកខ្លះក្រ ។ ល ។ យ៉ាងនេះតើព្រោះហេតុអ្វី? ព្រះពុទ្ធទ្រង់ឆ្លើយប្រស្នានេះដោយគោលធម៌យ៉ាងខ្ពង់ថា :

“មនុស្សសត្វទាំងឡាយដែលកើតមកប៉ុក ៗ គ្នានោះ ព្រោះជាប់ចំពាក់នឹងកម្មរបស់ខ្លួនឯង ជាទាយាទរបស់កម្ម ជាអ្នកមានកំណើតអំពីកម្ម ជាផៅពង្សរបស់កម្ម មានកម្មជាទីពឹង បើធ្វើកម្មល្អ នឹងបានទទួលផលល្អ បើធ្វើកម្មអាក្រក់ នឹងបានទទួលផលអាក្រក់ (សព្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ)” ។

ព្រះពុទ្ធដីកាថា “កម្ម, ផល” នេះ ត្រូវនឹងពាក្យថា “ហេតុ, ផល” ដែរ មិនខុសគ្នាទេ អាចប្រើផ្លាស់ប្តូរគ្នាបាន ចង់ថា “កម្ម” ក៏បាន ចង់ថា “ហេតុ” ក៏បាន ។

ការពិចារណាអំពីដំណើរជីវិត ទុកជាផ្លូវគំនិតនៃសាធុជនក៏ល្មមនឹងបញ្ចប់ហើយ ដូច្នេះលោកអ្នកអានគួរជឿតាមមតិណា ? តាមមតិពាហិរសាសនា ឬតាមមតិអ្នកវិទ្យាសាស្ត្រ ឬក៏តាមមតិពុទ្ធសាសនា ។ ចំណែកខាងខ្ញុំ ជឿធ្ងន់ទៅក្នុងមតិអ្នកវិទ្យាសាស្ត្រនឹងមតិពុទ្ធសាសនា, នេះសូមដំកបដោយត្រង់ហើយ ។

---

# សង្ឃសរណគាថា

ព្រះមហា ហ៊ុន-ប្រិញ រៀបរៀង

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះមានជោគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

អាត្មាភាព សូមសំដែងអំពីសង្ឃសរណៈដូចមានសេចក្ដីតទៅនេះ:

ព្រះពុទ្ធជាបរមគ្រូ ទ្រង់មានយុត្តិធម៌ស្មើភាគ គឺទ្រង់មិនលើកកំពស់ ឬកៀរកោយប្រមូលដាក់លើព្រះអង្គតែមួយព្រះអង្គប៉ុណ្ណោះឡើយ ទាំងព្រះសទ្ធម្មជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលទ្រង់សំដែងហើយព្រះអង្គ ៗ ក៏មិនមានសេចក្ដីរង្កៀស ទ្រង់លើកឡើងជាសរណៈស្មើគ្នានឹងព្រះអង្គ, រកសាស្ដាណាមួយដែលជាគ្រូកាន់យុត្តិធម៌ស្មើភាគដូចព្រះអង្គគ្មាន សាស្ដាដទៃច្រើនតែលើកកំពស់ ឬកៀរកោយដាក់លើខ្លួន សម្រេចលើខ្លួន ធំលើខ្លួន ជាសេចក្ដីមិនសមហេតុមិនសមផល ។ ដែលព្រះអង្គទ្រង់លើកជាសរណៈស្មើភាគគ្នានេះ ជាការប្រសើរណាស់ ព្រោះសរណៈត្រ័យទាំង ៣ ប្រការ គឺពុទ្ធសរណៈ ធម្មសរណៈ នឹងសង្ឃ-សរណៈនោះតោងអាស្រ័យគ្នានឹងគ្នា, បើខ្វះខាងណាមួយមិនបានឡើយ មិនកើតឡើងទៅជាសាសនា ; ឧបមាដូចជាឈើ ៣ កំណាត់ ដែលបុគ្គលយកទៅបញ្ឈរផ្ដុំទល់គ្នា ក៏អាចតាំងនៅបាន, កាលណាបុគ្គលយក

មួយកំណាត់ចេញ ពីរកំណាត់ទៀតមិនអាចតាំងនៅបានទេ, បើបុគ្គលយកពីរកំណាត់ចេញ មួយកំណាត់ទៀតក៏រឹតតែមិនអាចតាំងនៅបានណាស់ទៅទៀត ។ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, ក៏តោងអាស្រ័យគ្នាដូច្នោះដែរ; ព្រោះថា បើមានព្រះសម្ពុទ្ធត្រាស់ដឹងឡើងហើយ ៗ ប្រសិនជាព្រះអង្គមិនបានសំដែងធម៌ឲ្យអ្នកណា ស្ដាប់ទេ ក៏គ្មានប្រយោជន៍អ្វីដល់សត្វលោក ព្រះអង្គបរិនិព្វានទៅតែមួយអង្គប៉ុណ្ណោះ ។ បើព្រះអង្គសំដែងធម៌ហើយគ្មានអ្នកណា ចូលទៅជិតត្រងត្រាប់ប្រតិបត្តិយក ក៏ទទេទៀត សំដែងទៅគ្រាន់តែពុះកាក ៗ ដូចគ្មានទីត្រដោកគោក្របីអ្នកស្រុក ៗ ប៉ុន្តែមិនដូច្នោះឡើយ អាស្រ័យដោយព្រះមហាករុណាជាកំឡាំង កាលព្រះអង្គបានត្រាស់ហើយ បានសំដែងសាសនធម៌បង្អុលប្រាប់ផ្លូវល្អអាក្រក់ គុណទោស គួរធ្វើមិនគួរធ្វើ ឲ្យសត្វលោកបានស្ដាប់យកប្រតិបត្តិតាម ទាល់តែដល់នូវសេចក្ដីបរិសុទ្ធផូរផង់ផុតទុក្ខភ័យដូចជាព្រះអង្គដែរ ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គនោះ ក៏ប្រតិស្ឋានជាពុទ្ធសាសនាត ៗ គ្នាមក ជាប្រយោជន៍ដល់ប្រជុំជនច្រើនរហូតមកដល់សព្វថ្ងៃនេះ ។ បើប្រសិនជាគ្មានព្រះសង្ឃជាអ្នកត្រងត្រាប់ស្ដាប់រៀនសូត្រប្រតិបត្តិតាមទេ ហើយគ្មានអ្នកនាំពាក្យប្រៀនប្រដៅប្រកាសតៗ មក, យើងរាល់គ្នាកងជំនាន់នេះ ក៏ងងឹតល្ងង់ឥតដឹងបាបបុណ្យគុណទោសអ្វីឡើយ ។ សូមលើកយកឧទាហរណ៍ចំពោះការដែលព្រះសង្ឃធ្វើប្រយោជន៍ដ៏ធំទុកដល់យើងរាល់គ្នា ឲ្យឃើញដូចតទៅនេះ :

កាលព្រះបរមសាស្តាស្តេចរលត់ខន្ធចូលកាន់ព្រះនិព្វានហើយ បើរាប់ឈ្មោះខែបាន ៤ ខែ, បើរាប់ចំនួនថ្ងៃបាន ៩០ ថ្ងៃគត់ ព្រះអរិយសាវកទាំងឡាយនាំគ្នាធ្វើសន្និបាតប្រជុំនូវមណ្ឌបថ្មី ឈ្មោះសត្តបណ្ណគូហា នាគុំវេភារៈ ក្បែរក្រុងរាជគ្រឹះមហានគរ ដែលព្រះបាទអជាតសត្រូវបានសាងប្រគេន, ជួយគ្នារួបរួមព្រះធម៌ដែលព្រះអង្គទ្រង់ប្រៀនប្រដៅនិងព្រះវិន័យដែលទ្រង់បញ្ញត្តទុកជាផ្លូវប្រតិបត្តិសម្រាប់ភិក្ខុសង្ឃតាំងអំពីដើមរៀងមក ឲ្យចូលជារបៀបរៀបរយតែមួយ ។ ព្រះមហាកស្សបត្ថេរជាប្រធានក្នុងការប្រជុំនោះ បានចាត់ព្រះមហាអានន្ទត្ថេរដែលស្ទាត់ជំនាញក្នុងបទធម៌ឲ្យជាអ្នកវិសជ្ជនាថែកខាងព្រះធម៌, ចាត់ព្រះឧបាលិត្ថេរដែលស្ទាត់ជំនាញក្នុងវិន័យឲ្យជាអ្នកវិសជ្ជនាថែកខាងវិន័យ ។ លុះប្រជុំតម្រូវឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីកាហើយ ក៏សម្រេចទុកជាបែបផែន នាំគ្នាទន្ទេញស្វាធ្យាយព្រះធម៌វិន័យនោះចាំមាត់ស្ទាត់រៀងខ្លួន តែសម័យនោះមិនទាន់មានការចារិកជាតួអក្សរនៅឡើយ ។ ក្នុងសន្និបាតនោះព្រះមហាកស្សបត្ថេរបានជ្រើសរើសព្រះអរហន្ត ដែលទ្រទ្រង់បដិសម្ភិទាញាណ ចំនួន ៤៩៩ អង្គ ជា ៥០០ នឹងអង្គលោក, មានព្រះបាទអជាតសត្រូវជាសាសនូបត្ថម្ភក៍, ធ្វើចំនួន ៧ ខែ ទើបហើយស្រេច ហៅថា “បឋមសង្គាយនា” ។ ហេតុដែលកើតបឋមសង្គាយនានេះ មកពីភិក្ខុចាស់មួយរូប ឈ្មោះសុភទ្ទ ជាអ្នកពោលប្រទូស្តទៅរកព្រះបរមគ្រូ ។ ព្រះមហាកស្សបត្ថេរបានជ្រាបពាក្យបម្រឹងបម្រាស់នេះហើយ ក៏យល់ថា “ពាក្យនេះអាចនាំបំបែកសាសនាជាថ្មីទៀតបានមិនខាន” លោកពិចារ-

ណា ថា "កិច្ចសំខាន់ដែលនឹងរំងាប់នូវពាក្យប្រមងប្រមាស់នេះបាន គឺត្រូវតែប្រមូលពុទ្ធវចនៈរបស់ព្រះបរមគ្រូ ឲ្យមានរបៀបរៀបរយឡើងទើបគួរ" ។ លុះស្រេចការសង្គាយនាហើយ ព្រះអរិយសាវកទាំងឡាយ ក៏បែកខ្ញែកគ្នាទៅនៅក្នុងប្រទេសផ្សេងៗ ត្រាច់ទៅប្រកាសសាសនា ប្រដៅប្រជាជនព្រមទាំងឲ្យបព្វជ្ជា ឧបសម្បទា ដល់អ្នកមានសទ្ធា ។ ពួកក្រោយៗមក ក៏នាំគ្នាទន្ទេញធម៌វិន័យតាមបែបផែនដែលបានធ្វើសង្គាយនានោះ កាន់យកជាគោលចារិកព្រះពុទ្ធសាសនា ។

លុះកន្លងយូរមក ព្រះអរិយសាវកលោកអ្នកធ្វើសង្គាយនាទាំងនោះចូលបរិនិព្វានអស់ទៅ, ភិក្ខុដែលជាថេរៈក្នុងគណៈនីមួយៗ ក៏គ្រប់គ្រងគណៈសង្ឃតមក សូត្រអំពីដើមស្វាធ្យាយន៍ធម៌វិន័យតាមបែបផែនដែលធ្វើសង្គាយនាមកជាមួយគ្នាក៏បែកគំនិតផ្សេងៗគ្នា តាមគណៈនោះៗ ។ កាលព្រះបរមសាស្តាស្តេចចូលកាន់ព្រះនិព្វានទៅ បានជាង ១០០ ឆ្នាំ មានភិក្ខុមួយពួកហៅថាវជ្ជីបុត្តកៈនៅនគរវេសាលី ។ ពួកវជ្ជីបុត្តកៈប្រហែលជាប្រកាន់យកខដែលមានក្នុងមហាបរិនិព្វានសូត្រថា "ព្រះពុទ្ធអង្គបានអនុញ្ញាតទុកថា បើភិក្ខុទាំងអស់យល់ឃើញព្រមព្រៀងគ្នាថា ខុទ្ទានុខុទ្ទកសិក្ខាបទ គឺសិក្ខាបទតូចៗ ណាមួយដែលទ្រង់បានបញ្ញត្តរួចហើយ លុះកាលកន្លងទៅ បើប្រព្រឹត្តមិនស្រួលឲ្យកែប្រែបាន"; ខនេះជាមូលហេតុ ពួកភិក្ខុវជ្ជីបុត្តកក៏កែប្រែវិន័យបញ្ញត្តិលើកយកវត្ថុ ១០ ប្រការឡើងប្រារព្ធ មានដើមថា កប្បតិ សិង្គិលោណកប្បោ ទុកអំបិលបម្រុងដើម្បីពភាយដោយបិណ្ឌបាត គឺទៅថ្ងៃមុខទៀតបាន ។

គ្រានោះព្រះយសត្ថេរ ជាអ្នកខ្វះខ្វែងក្នុងការរម្ងាប់អធិករណ៍នោះ បាននិមន្តព្រះមហាថេរដែលជាមេគណាចារ្យក្នុងគណៈដទៃ ៗ មានព្រះសព្វកាមិត្ថេរ និងព្រះរេវតត្ថេរជាដើម ព្រមទាំងគណៈសង្ឃឯទៀតជាច្រើន មកប្រជុំគ្នានៅនគរវេសាលី វិនិច្ឆ័យថាវត្ថុ ១០ ប្រការ ដែលពួកភិក្ខុវជ្ជីបុត្តប្រែវិន័យនោះមិនសមគួរទេ ព្រោះកាលព្រះអរិយសាវកធ្វើបឋមសង្គាយនានោះ បានយល់ព្រមថា "ទោះព្រះពុទ្ធអង្គបានប្រទានទុកក្តី ក៏មិនគួរទឹងមកកែប្រែឲ្យខុសអំពីបទដែលទ្រង់បញ្ញត្តឡើយ" ។ ហើយបានរម្ងាប់វត្ថុ ១០ ប្រការឲ្យសាបសូន្យទៅ រួចប្រជុំព្រះអរហន្តចំនួន ៧០០ អង្គ លើកសង្គាយនាតាមលំអានព្រះមហាកស្សបត្ថេរមួយលើកទៀត ហៅថាទុតិយសង្គាយនា ប្រជុំធ្វើនៅវាលុការាម ទៀបក្រុងវេសាលី មានព្រះបាទកាលាសោកជាសាសនូបត្ថម្ភក៍ធ្វើ ៨ ខែហើយស្រេច ។

លុះព្រះពុទ្ធសាសនាកន្លងទៅជាច្រើនឆ្នាំ ព្រះពុទ្ធសាសនាក្នុងបាតលីបុត្រ មានវិបរិតដោយពួកតិរ្ថិយចូលបួសបន្ទំយកលាភសក្ការៈជាច្រើន; ព្រះមោគ្គលិបុត្តតិស្សត្ថេរ បានញុំាងព្រះបាទអសោកព្រះចៅក្រុងបាតលីបុត្រឲ្យទ្រង់សិក្សាបានជ្រាបច្បាស់នូវពុទ្ធសាសនា ហើយទ្រង់ពិនិត្យផ្ស្រកពួកតិរ្ថិយចេញអស់ ។ រួចហើយព្រះមោគ្គលិបុត្តតិស្សត្ថេររើសព្រះអរហន្តដែលទ្រទ្រង់បដិសម្ភិទាជាច្រើនអង្គ ប្រជុំធ្វើសង្គាយនាទៀត ហៅតតិយសង្គាយនា នៅអសោការាម ទៀបក្រុងបាតលីបុត្រ មានព្រះបាទអសោកជាសាសនូបត្ថម្ភក៍ធ្វើ ៩ ខែហើយស្រេច ។ រួចហើយ

ព្រះបាទអសោកទ្រង់អារាធនាព្រះភិក្ខុសង្ឃឲ្យចេញទៅប្រកាសសាសនាក្នុងប្រទេសផ្សេង ៗ ដូចតទៅនេះ :

១ – ព្រះមហាទេវត្ថេរ ទៅមហិសមណ្ឌល (គឺដែនខាងក្រោមទន្លេគោទាវរី ប្រទេសម៉ៃសូរសព្វថ្ងៃនេះ);

២ – ព្រះរក្ខិតត្ថេរ ទៅវនវាសីប្រទេស (គឺដែនខាងលើ ជាខេត្តបុមបៃសព្វថ្ងៃនេះ);

៣ – ព្រះធម្មរក្ខិតត្ថេរ ទៅបរន្តប្រទេស (គឺដែនផ្លូវឆ្ងាយទន្លេខាងលើស្រុកបុមបៃសព្វថ្ងៃនេះ);

៤ – ព្រះមហាធម្មរក្ខិតត្ថេរ ទៅមហារដ្ឋប្រទេស (គឺដែនខាងដើមទន្លេគោទាវរី);

៥ – ព្រះមជ្ឈន្តិកត្ថេរ ទៅកស្មិរៈនិងគន្ធារៈប្រទេស (គឺអាហ្វ-ឃានិស្ថានសព្វថ្ងៃនេះ);

៦ – ព្រះមជ្ឈិមត្ថេរ ទៅហិមវន្តប្រទេស (គឺមណ្ឌលដែលតាំងនៅជើងភ្នំហិមាល័យ មាននេប៉ាល់រដ្ឋជាដើម);

៧ – ព្រះមហារក្ខិតត្ថេរ ទៅយោនកប្រទេស (គឺស្រុកដែលនៅក្នុងប្រទេសប៉ែរ្សសព្វថ្ងៃនេះ);

៨ – ព្រះមហិន្ទត្ថេរ ទៅលង្កាទ្វីប;

៩ – ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរមកកាន់សុវណ្ណភូមិ គឺជ្រោយឥណ្ឌូចិនយើងនេះ ។

លុះដល់ព្រះពុទ្ធសករាជ ៩៥៦ ឆ្នាំ ព្រះពុទ្ធឃោសាចារ្យនៅក្នុង

ឥណ្ឌា បានទៅលង្កាទ្វីប ប្រែអដ្ឋកថាអំពីភាសាសីហឡៈ គឺភាសាអ្នកលង្កាទ្វីបមកជាមគធភាសា ហរដាក់ស៊ុករិតទាល់តែចប់ទាំងអស់ ។ វេលាក្រោយមកមានព្រះសង្ឃខ្មែរនិងព្រះសង្ឃប្រទេសឯទៀត ចេញទៅរៀនព្រះត្រៃបិដកភាសាមគធៈនៅលង្កាទ្វីប ហើយត្រឡប់មកកាន់ប្រទេសរបស់ខ្លួន បានទាំងនាំយកព្រះត្រៃបិដក មកប្រៀនប្រដៅប្រជាជនក្នុងប្រទេសរៀង ៗ ខ្លួន ដែលជាប់មានមកដល់សព្វថ្ងៃនេះ ។ ពប់ថាព្រះសង្ឃបានធ្វើប្រយោជន៍ដ៏ធំ ជាបរហិតសម្បត្តិដល់ប្រជុំជនជាច្រើន ៗ នេះសំដែងតែប្រយោជន៍ខាងក្រៅ ដែលព្រះសង្ឃបានធ្វើដល់ពុទ្ធសាសនិកជន ។

ឯប្រយោជន៍ខាងក្នុង ដែលលោកខំបំពេញសម្រាប់ខ្លួនលោកជាអត្តហិតសម្បត្តិនោះ គឺលោកខំសិក្សាត្រង់ត្រាប់ឱវាទរបស់ព្រះបរម-សម្ពុទ្ធហើយប្រតិបត្តិញ៉ាំងកាយ, វាចា, ចិត្តឲ្យស្អាតពរបសា ព្យាយាមលះសំយោជនៈជាគ្រឿងរឹតរួតចិត្តដែលជាប់នៅក្នុងភព តាមលំដាប់ទាល់តែបានលុះលោកុត្តរភូមិជាជាន់ ៗ ឡើងទៅ ។ កំណត់តាមថ្នាក់ដែលលោកលះសំយោជនៈបាននោះមាន ៤ ថ្នាក់ :

ថ្នាក់ទី ១ លោកដែលបានសំរេចសោតាបត្តិមគ្គនិងសោតាបត្តិផល; លោកលះសំយោជនៈ បាន ៣ យ៉ាងគឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា និងសីលព្វតបរាមាស ;

ថ្នាក់ទី ២ លោកដែលបានសំរេចសកទាគាមិមគ្គនិងសកទាគាមិ-ផល ; លោកលះសំយោជនៈបាន ៣ យ៉ាង ដូចលោកដែលបាន

សំរេចសោតាបត្តិមគ្គនឹងសោតាបត្តិផលដែរ ប៉ុន្តែសំយោជនៈឯទៀតៗ លោកបានធ្វើឲ្យស្រាលស្តើងជាង, តាំងរាគៈ ទោសៈ មោហៈ លោកក៏បានធ្វើឲ្យខ្សោយទៅជាងសោតាបន្នបុគ្គល;

ថ្នាក់ទី ៣ លោកដែលបានសំរេចអនាគាមិមគ្គនឹងអនាគាមិផល; លោកលះសំយោជនៈ បាន ២ យ៉ាងថែមទៀត គឺកាមរាគៈ នឹងបដិឃៈ រួមជាសំយោជនៈ ៥ ;

ថ្នាក់ទី ៤ លោកដែលបានសំរេចអរហត្តមគ្គនឹងអរហត្តផល; លោកលះសំយោជនៈ បានទាំង ១០ ឥតមានសេសសល់ ។

ព្រះសង្ឃដែលរាប់ថាជាសង្ឃសរណៈក្នុងទីនេះ សំដៅយកព្រះសង្ឃទាំង ៤ ថ្នាក់ដែលសំដែងមកនេះ ។ លោកទាំងនេះជាតំណាងអង្គសម្តេចព្រះបរមសាស្តា, សូម្បីព្រះសម្ពុទ្ធព្រះអង្គបរិនិព្វានទៅជាអង្វែងហើយ ព្រះពុទ្ធសាសនកាលកន្លងទៅបាន ២៤៩៩ វស្សាហើយ; ព្រះពុទ្ធសាសនាក៏ឋិតនៅបរិបូណ៌ ដោយព្រះសង្ឃយកចិត្តទុកដាក់ថែរក្សាបានប្រៀនប្រដៅពុទ្ធសាសនិកជនតៗមក រហូតមកដល់សម្មតិសង្ឃ ។ ក៏បានទទួលរាប់រងធ្វើតាមនោះតមកទៀត ។ យើងរាល់គ្នាដែលកើតជាន់ក្រោយ បានដឹងស្គាល់ព្រះពុទ្ធសាសនា ដែលជាសាសនាល្អឯកក្នុងលោក ជាសាសនាត្រឹមត្រូវបំផុតក្នុងលោក ដោយសារតែព្រះសង្ឃទាំងនោះ ។

ចំណែកគុណព្រះសង្ឃនោះលោកអាងទុកថា:

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា

សាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។

ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា ។

ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ។

សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល, សមាធិ, បញ្ញា ។

យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃណា បើរាប់ជាគូមាន ៤ គូ អដ្ឋ បុរិសបុគ្គលា បើរាប់រៀងជាបុរសបុគ្គលមាន ៨ ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនេះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលបូជាចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា បាហុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម

ទីនផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

លោកដែលបាននាមថាព្រះសង្ឃ តោងទ្រទ្រង់គុណសម្បត្តិទាំងអម្បាលនេះ; ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានបុណ្យសុទ្ធតែទ្រទ្រង់នូវគុណសម្បត្តិយ៉ាងនេះទាំងអស់ ។ គុណរបស់ព្រះសង្ឃដែលសំដែងមកនេះ លោកពប់ថាព្រះសរង្ឃជាសរណៈរបស់សត្វលោក ។

សូមបញ្ចប់ធម្មទេសនា ដែលសំដែងអំពីសង្ឃសរណៈតែប៉ុណ្ណេះ ។

កាលបើចប់ហើយ ដោយអំណាចនៃធម្មទេសនានេះ សូមសេចក្តីសុខ-ចំរើន កើតមានដល់ប្រជាជនកូនដែនកម្ពុជាទាំងមូល កុំបីឃ្លៀងឃ្លាតឡើយ ។

---

## ប្រាជ្ញឯងឲ្យក្រែងប្រាជ្ញគេ

## ចាបការជារឿងពុទ្ធរូបបុរាណ

យុគអគ្គកោវិទ ជា-យ៉ឿវ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែបាកទស្សនាវដ្ដី ដំណឹងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(តមក)

ក្នុងសម័យរតនកោសិន្ទ្រ សម្ដេចព្រះមហាសមណៈក្រុមព្រះបរមា-នុជិតជិនោរស ទ្រង់និពន្ធតម្រាព្រះប៉ាង (តម្រាព្រះពុទ្ធរូបតាមសម័យ) ១ ដែរ, សម្ដេចព្រះចូឡចមក្លៅបិយមហារាជ ទ្រង់និពន្ធតម្រាព្រះពុទ្ធជិនរាជវៃទត្រពិស្ណុលោក, សម្ដេចក្រុមពញាតម្រង់រាជានុភាព ទ្រង់និពន្ធតម្រាប្រែនយ៉ាង តែដែលសំខាន់ជាងគេ គឺដំណាលព្រះពុទ្ធរូបសំខាន់ពោលដោយព្រះពុទ្ធរូបសំខាន់ផ្សេងៗ ដែលមាននៅក្នុងអាណាចក្រថៃទាំងអស់ ហើយតម្រាក្រោយបង្អស់ គឺដំណាលពុទ្ធចេតិយស្យាម តម្រាដែលប្រើជាគ្រឿងប្រកបក្នុងការសិក្សា ៗ អំពីដើមតម្រានេះរកបានដោយកម្រណាស់ ហើយអ្នកដែលរួបរួមព្រះពុទ្ធរូប ក៏ហៅឈ្មោះព្រះទាំងនោះតាមអំពើចិត្តថា ព្រះខមខ្លះ ព្រះខ្មែរខ្លះ ព្រះឥណ្ឌាខ្លះ គេហៅមិនត្រឹមត្រូវ, តែតាំងអំពីមានតម្រាដំណាលពុទ្ធចេតិយៈឡើង ទើបគេហៅបានដោយត្រឹមត្រូវ ៗ ព្រោះហេតុនោះ ការរៀនរឿងព្រះពុទ្ធរូប ទើបជាការកម្រដ៏ក្រៃលែង ដូចពាក្យមន្ត្រីម្នាក់និយាយប្រាប់ខ្ញុំមែន ៗ ក្នុងបណ្ដាអ្នកតែងតម្រា ដើម្បីធ្វើឲ្យការសិក្សាស្រួលឡើងនោះ សម្ដេចព្រះចូឡចមក្លៅ បានទ្រង់ធ្វើការដ៏សំខាន់ ជាងអ្នកតែងតម្រាទាំងនោះ គឺកាលទ្រង់កសាងវត្តបញ្ចមបពិត្រនេះជាព្រះអារាមហ្លួងឡើង ក្នុង ព. ស. ២៤៤២

ពេលដែលទ្រង់សាងរបៀងវិហារស្រេចហើយ ក៏ទ្រង់ចាត់ឲ្យដំកល់ព្រះពុទ្ធរូបសម័យផ្សេងៗ ដែលទ្រង់ស្វែងរកបានក្នុងអាណាចក្រថៃទីនានាប្រទេស ក្នុងរបៀងវិហារនោះ ធ្វើជាពិពិធភ័ណ្ឌព្រះពុទ្ធរូបឡើង ។ តែកិច្ចការទាំងនេះជាព្រះរាជបំណង ដែលមានជាប់តមក តាំងអំពីព្រះបាទសម្ដេចព្រះពុទ្ធយ៉តហ្វាចូឡាលោក គឺកាលទ្រង់សាងព្រះវិហារស្រេចហើយក៏ត្រូវសាងថែវជុំវិញសំរាប់ដំកល់ព្រះពុទ្ធរូបផ្សេងៗ ដូចជាវត្តពោធិ៍ ឬវត្តមហាធាតុ ដែលក្រុមព្រះរាជវាំងបវរទ្រង់សាង តែព្រះពុទ្ធរូបក្នុងថែវវិហារវត្តពោធិ៍នោះ ជាព្រះបុរាណនាំមកពីស្រុកលើនៅក្នុងរជ្ជកាលទី ១ តែបើព្រះអង្គណាតូចមិនប៉ុនគ្នា គេយកកំបោរបូកហើយលាបម្រ័ក្សណ៍បិទមាសឲ្យធំប៉ុនគ្នាឡើង តែការធ្វើដូច្នោះជាការលុបក្បាច់ក្បូរទីងចំដែងជាងបុរាណ ជាការទំនាស់ដល់ការសិក្សា ព្រោះដូច្នោះយើងទើបឃើញថាព្រះពុទ្ធរូបក្នុងថែវវិហារវត្តពោធិ៍នោះ ជាព្រះប៉ាំដោយកំបោរក្នុងសម័យរតនកោសិន្ទទាំងអស់ តែដែលពិតនោះជាព្រះលោហៈនឹងព្រះសិទ្ធ ដែលយកពីខេត្តក្រៅមកទាំងអស់ ហើយយកមកលាបម្រ័ក្សណ៍បិទមាសជាថ្មី ។ កាលសម្ដេចចូឡចមក្លៅទ្រង់សាងវត្តបញ្ចម-បពិត្រនោះ ដោយទ្រង់ប្រាថ្នានឹងធ្វើឲ្យល្អវិសេសជាងគេ ឲ្យជាស្ថានដែលសម្រាប់សិក្សាយ៉ាងពិតប្រាកដ ទើបទ្រង់ឲ្យធ្វើព្រះខាត់ (គឺព្រះពុទ្ធរូបដែលសិទ្ធដោយទង់ដែងជាដើម តែកាលណាមានពណ៌ស្រអាប់គេយកថ្នាំមកដុសខាត់ឲ្យមានពន្លឺភ្លឺផ្លេកឡើងវិញ ) ដំកល់ទុកមិនបាច់លាបម្រ័ក្សណ៍បិទមាស ព្រោះព្រះខាត់មានពន្លឺភ្លឺល្អស្រេចហើយ តែជាការ

ពិបាកដែរ បើជាងខាត់មិនប្រសប់ខាត់ នឹងខាត់ឲ្យខូច ដូចព្រះពុទ្ធរូប
មានព្រះកក្រុណាយ ក៏ខាត់ទាល់តែមានបង្កានោះស្រួច ឬបង្កាវិលរេច
រៀវតូចទៅ ចួនកាលព្រះពុទ្ធរូបដែលគ្មានដើងព្រះកេស គេក៏ខាត់ទាល់
តែមានដើងព្រះកេសឡើង, ដែលធ្វើដូច្នេះជាហេតុឲ្យរលុបគន្ធងដង
ជាន ជាការទំនាស់ក្នុងការសិក្សា ។ ដើម្បីមិនឲ្យទាស់ខុសក្នុងការសិក្សា
យើងត្រូវតែកុំខាត់ ព្រោះតាមរឿងដែលពិតព្រះពុទ្ធរូបក្នុងសម័យនីមួយៗ
គេធ្វើផ្សេងៗ ពីគ្នា ។ នៅក្នុងពិពិធភ័ណ្ឌព្រះពុទ្ធរូបរបស់សម្តេចព្រះ
បូឡុបមក្លៅ មានព្រះពុទ្ធរូបគ្រប់ត្រកូលជាងដែលមានមកក្នុងលោកដូច
ព្រះពុទ្ធរូបធ្វើទុករកិរិយា មានព្រះអង្គស្គមនោះ ជាព្រះសម័យគន្ធាររដ្ឋ
ព្រះសម័យអមរវតី គឺជាព្រះលង្កាចាស់ធ្វើពីថ្ម មាឌបិតជ្រួញ
អង្កាញ់ៗ ដំកល់ទុកនៅរបៀងប៉ែកខាងលិចជាន់ខាងក្រៅ ១ អង្គ, ១ អង្គ
ទៀតជាព្រះលោហៈ សិទ្ធពន្លឹកពីព្រះពុទ្ធរូបអមរវតី របស់សម្តេចក្រុម
ពញាតម្រង់ភជានុភាពនៅក្នុងពិពិធភណ្ឌស្ថាន ដំកល់ទុកក្បែរព្រះពុទ្ធរូប
ស្គមនោះ, ដល់មកសម័យគុប្ត: គេសិទ្ធពន្លឹកពីព្រះពុទ្ធរូបដែលពិតនៅ
ក្នុងពិពិធភណ្ឌស្ថាន ដំកល់ទុកក្នុងរបៀងខាងជើងបំផុតប៉ែកខាងកើត ។
នៅកន្លែងនោះមានព្រះពុទ្ធរូបទ្វារវតី គេដំកល់ទុកនៅរបៀងខាងក្រៅ
ប៉ែកខាងត្បូង ១ អង្គ នៅជ្រុងខាងលិច ១ អង្គ ធ្វើដោយថ្មខៀវ នៅខាង
ក្នុងមានព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនសម័យទ្វារវតី តែមិនមែនជាព្រះជាន់
ដើមទេ ជាព្រះដែលសិទ្ធពន្លឹកអំពីអង្គតូចៗ របស់សម្តេចក្រុមពញា
តម្រង់ភជានុភាព ដែលនៅក្នុងពិពិធភណ្ឌ; ព្រះសម័យស្រីវិជ័យក៏មាន

១ អង្គដែរ នៅក្នុងសាលាម៉មឈៀយ តែឥឡូវនេះគេយកទៅទុកនៅពិពិធភណ្ឌស្ថានទៅហើយ ។ កាលខាងដើមរដ្ឋកាលទី ៧ តពីសម័យស្រីវិជ័យមក ក៏មកដល់សម័យលពបុរី មានព្រះច្រើនអង្គទៀតអង្គដែលនៅក្នុងស៊ុមទ្វារក្រោយព្រះវិហារនេះ ក៏ចំពួកព្រះសម័យលពបុរីដែរ ។ តពីលពបុរី ក៏មកដល់ព្រះពុទ្ធរូបសម័យជៀងសែន មានច្រើនអង្គក្នុងរបៀងវិហារនេះ ។ តពីជៀងសែនក៏ដល់សម័យសុខោទ័យ ( សុខោថៃ ) គឺព្រះពុទ្ធរូបលីលា ដូចជាព្រះ ១ អង្គនេះ ជាអង្គដំធំហើយមានទ្រង់ទ្រាយល្អស្រស់បស់ ។ តពីសុខោទ័យមក ក៏មកដល់ព្រះសម័យអយុធ្យា មានទាំងអយុធ្យាជាន់ដំបូង គឺសម័យអ៊ូថង ទាំងអយុធ្យាជាន់ក្រោយគឺអយុធ្យាធម្មតា ។ ក្រៅពីព្រះដែលបានប្រទះឃើញនៅអាណាចក្រថៃ ទាំងព្រះដែលជាដើមវង្សមកពីឥណ្ឌាហើយ ក៏នៅមានព្រះដែលមកពីប្រទេសផ្សេងៗទៀត ដូចជាព្រះជប៉ុន ព្រះចិន ព្រះភូមា ក៏មាននៅក្នុងកន្លែងនេះដំបរិបូណ៌ ។ ព្រោះហេតុនោះពិពិធភ័ណ្ឌព្រះពុទ្ធរូបរបស់សម្ដេចព្រះចូឡចមក្លៅ ឃើញថាឲ្យប្រយោជន៍បានយ៉ាងពិតប្រាកដមែនដល់អ្នកសិក្សាលក្ខណៈព្រះពុទ្ធរូបបុរាណ ។ ព្រះពុទ្ធរូបបុរាណនោះយើងរៀនត្រឹមតែថ្នាក់បរិយត្តិ គឺរៀនត្រឹមតែមើលតម្រាប៉ុណ្ណោះមិនទាន់គ្រប់គ្រាន់ទេ ត្រូវរៀនឲ្យដល់ថ្នាក់ប្រតិបត្តិ គឺពិចារណារូបលក្ខណៈឲ្យឃើញពិតប្រាកដ ដូចលោកដែលមើលពិពិធភ័ណ្ឌព្រះពុទ្ធរូបគ្រប់ៗគ្នា លោកត្រូវយកចិត្តទុកដាក់មើលឲ្យដឹងថា ជាព្រះសម័យណា មានលក្ខណៈ

ដូចម្តេចជាគ្រឿងសង្កេត ហើយបើមានលក្ខណៈច្រើនសម័យមកប្រកបគ្នា ក៏ជាបញ្ហាឲ្យជជែកគ្នាបានយ៉ាងសប្បាយ ។

ខ្ញុំពោលមកទាំងនេះ ដើម្បីនឹងសំដែងឲ្យឃើញថា ព្រះពុទ្ធរូបរបស់យើងគួរយើងសិក្សា ព្រោះយើងជាពុទ្ធមាមកជន (អ្នកកាន់អានព្រះពុទ្ធសាសនា) គួរសិក្សារឿងព្រះពុទ្ធឲ្យចេះដឹងខ្លះទើបជាការគួរ តែដោយច្រើនគេមិនសូវយកចិត្តទុកដាក់សោះ បើមានពួកនានាជាតិគេមកសួរ យើងនឹងប្រាប់គេឲ្យដឹងរឿងរ៉ាវខ្លះមិនបាន សូម្បីតែក្នុងពួកអ្នកសិក្សាទៀត ក៏មិនមានអ្នកចេះប៉ុន្មាន ព្រោះដូច្នោះការដែលពុទ្ធ-សមាគមប្រទេសថៃ បាត់ឲ្យមានការប្រឡងព្រះពុទ្ធរូបឡើងក្តី សម្តេចព្រះបូព្វបមក្សៅទ្រង់សាងពិពិធភណ្ឌព្រះពុទ្ធរូបឡើង ជិត ៥០ ឆ្នាំមកហើយក្តី បានធ្វើឲ្យបណ្តាជនដែលមកទស្សនា ធ្វើទុកក្នុងចិត្តទាល់តែចូលចិត្ត ហើយបែរមកសិក្សាលក្ខណៈព្រះពុទ្ធរូបជាច្រើន ត្រូវតាមព្រះរាជបំណង នឹងត្រូវតាមបំណងនៃពុទ្ធសមាគម ដែលបានបាត់ឲ្យមានប្រឡងក្នុងគ្រានេះ ។

ខ្ញុំពោលមកទាំងនេះជារឿងបកិណ្ណកៈច្រើនណាស់ ឥឡូវនេះនឹងបែរមកពោលដល់រឿងដែលនាំឲ្យកើតមានព្រះពុទ្ធរូបតទៅ :

រឿងព្រះពុទ្ធរូបបុរាណនោះ យើងបានសិក្សាសៀវភៅ ១ ហៅថា "សៀវភៅជំណាលព្រះខ្ចឹមចន្ទន៍" តាមសៀវភៅនោះពោលថា :

"ក្នុងកាលដែលព្រះសម្មាសម្ពុទ្ធ ស្តេចទៅគង់ចាំវស្សានៅឯស្ថានតាវត្តិង្ស ដើម្បីទេសនាទូវព្រះអភិធម្មប្រោសព្រះពុទ្ធមាតា, ព្រះបាទ

បសេនទិកោសលទ្រង់មានព្រះទ័យរលឹកព្រះពុទ្ធអង្គជាខ្លាំង ព្រោះទ្រង់ធ្លាប់បានចូលទៅគាល់ជាញឹកញយ ទើបទ្រង់ព្រះបញ្ជាពួកជាងឲ្យយកឈើខ្លឹមចន្ទន៍មកឆ្លាក់ធ្វើជាព្រះពុទ្ធរូបដំកល់ទុកធ្វើសក្ការៈបូជា ចាំដល់ពេលចេញវស្សា ព្រះពុទ្ធអង្គទ្រង់ស្ដេចត្រឡប់មកវិញ ។ លុះដល់ចេញវស្សាហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់យាងត្រឡប់ចុះមកវិញ ហើយទ្រង់ពុទ្ធដំណើរមកកាន់ក្រុងកោសល ព្រះខ្លឹមចន្ទន៍នោះក៏រំកិលចុះមកពីលើពុទ្ធាសនៈ ព្រះពុទ្ធអង្គទ្រង់ត្រាស់ឲ្យដំកល់ព្រះពុទ្ធរូបនោះទុក” ។ តាមតម្រានេះសំដែងថា ព្រះពុទ្ធរូបនោះកើតមានឡើង តាំងពីកាលព្រះពុទ្ធអង្គទ្រង់ព្រះជន្មនៅឡើយ ហើយជាព្រះបរមពុទ្ធានុញ្ញាតផង យើងជឿមកដូច្នេះអស់កាលជាយូរអង្វែងណាស់មកហើយ ទាំងជឿថាព្រះពុទ្ធរូបនោះមានរូបរាងដូចព្រះពុទ្ធអង្គ ព្រោះហេតុថាគេបានសាងចំឡងពីព្រះរូបព្រះដ៏មានព្រះភាគយ៉ាងពិតប្រាកដ តែបើតាមរឿងដែលពិតនោះមិនមែនដូច្នោះទេ ព្រោះគេបានដើរពិនិត្យវត្ថុស្ថាន ដែលទាក់ទងដោយព្រះពុទ្ធសាសនាតាមគ្រោងការដ៏ធំនៅអាណាចក្រកណ្ដាល បានសេចក្ដីថា ក្នុងកាលដែលព្រះពុទ្ធអង្គទ្រង់ព្រះជន្មនៅ មិនដែលមានព្រះពុទ្ធរូបសោះឡើយ សូម្បីព្រះពុទ្ធសាសនាកន្លងមកជិតដល់ ៤០០ ឆ្នាំ ក៏នៅតែគ្មានព្រះពុទ្ធរូប ។ ឬជនីយដ្ឋានដែលព្រះបាទអសោកមហារាជ ជាពុទ្ធសាសនូបត្ថម្ភក៍ ១ អង្គដ៏សំខាន់ក្រៃលែង បានទ្រង់សាងទុកគ្រប់កន្លែង ក៏សុទ្ធតែគ្មានព្រះពុទ្ធរូបដែរ ។ តាមដែលពិតនោះ ព្រះបាទអសោកមហារាជ បានទ្រង់ធ្វើការគ្រប់យ៉ាង ដែលរាប់ថាជាបុណ្យ

កុសលក្នុងព្រះពុទ្ធសាសនា  រាប់តាំងពីទ្រង់ឲ្យធ្វើសង្គាយនាព្រះធម៌វិន័យ, បញ្ជូនព្រះសង្ឃឲ្យទៅប្រកាសព្រះពុទ្ធសាសនាក្នុងនានាប្រទេស, សាងស្តូបចេតិយប្រាំបីម៉ឺនបួនពាន់ សាងសសររៃគ្រប់កន្លែងនៅប្រទេសឥណ្ឌា  បញ្ជូនព្រះធាតុទៅបញ្ចុះក្នុងទីផ្សេង ៗ  តែស្តូបដែលសំខាន់ទីបំផុត  គឺសាញ្ចិស្តូបនៅស្រុកសាញ្ចិ  ដែលព្រះបាទអសោកទ្រង់សាងឡើងតាំងពីទ្រង់នៅជាព្រះអង្គម្ចាស់,  នៅអង្គព្រះស្តូបនោះគេឆ្លាក់ជារឿងពុទ្ធប្រវត្តិ  តែមិនឃើញមានព្រះពុទ្ធរូបសោះឡើយ ៗ  ទាំងនេះក៏ព្រោះក្នុងប្រទេសឥណ្ឌា គេប្រកាន់ជាច្រើនពាន់ឆ្នាំមកហើយថា មិនគួរសាងរូបដែលជាទីគោរពទុកទេ ៗ  ព្រោះដូច្នោះនៅកន្លែងត្រង់ណាដែលគេចង់ឲ្យយើងចូលចិត្តថាមានរូបព្រះពុទ្ធអង្គ  គេសាងរូបដទៃជំនួសគឺរូបប្រៀបសម្រាប់ឲ្យដឹងថាមានព្រះពុទ្ធអង្គដែរ  ដូចក្នុងកាលដែលស្ដេចចេញទ្រង់ផ្នួស គេធ្វើរូបសេះមានតែកែបទទេ  មិនមានមនុស្សជិះ  ឬបួនកាលធ្វើជាគន្ទងព្រះបាទ, ក្នុងកាលត្រាស់ដឹង  គេធ្វើជាបល្ល័ង្កក្រោមដើមពោធិព្រឹក្ស,  កាលទ្រង់ចូលបរិនិព្វាន  គេធ្វើជារូបស្តូបនៅទីនោះ ៗ

ចំណោរមកដល់រាជវង្សសុង្គៈបានគ្រប់គ្រងប្រទេសឥណ្ឌា  ក៏បានជួសជុលព្រះស្តូបនេះជាការធំមាំមួន  តែក៏មិនបានសាងព្រះពុទ្ធរូបដែរ  ទីត្រង់ណាដែលគួរមានព្រះពុទ្ធរូបគេសាងវត្ថុដទៃជំនួសគ្រប់កន្លែង, ចំណោរតមកជាន់ក្រោយទៀត ទើបគេបានប្រទះឃើញព្រះពុទ្ធរូបនៅក្រុងគន្ធារៈជាស្នាដៃជាងក្រិកសាង  មិនមែនស្នាដៃពួកឥណ្ឌា  ទាំងមិនមែនគំនិតពួកឥណ្ឌាដែរ ៗ

(មានត)

# ផ្នែកអក្សរសាស្ត្រ

## រឿងអ្នកស្នេហាជាតិ សាសនា មហាក្សត្រ

យុវបណ្ណាគុរ័ក្ស ប៊ូ-ប៉ូ ស្រង់ចាកតម្រាផ្សេង ៗ

(ត-ចប់)

បំណែកព្រះស្តេចកន បានជ្រាបសេចក្តីកងសំបុត្រដែលឧកញ៉ាកែវ ឲ្យមកនោះហើយ ក៏ត្រាស់បង្គាប់ឲ្យឧកញ៉ាចក្រី ចេញទៅកេណ្ឌពលខែត្រខាងលិចជាយ៉ាងប្រញាប់ឲ្យទាន់ការ លើកទៅកាន់ផ្លូវនៅខែត្រលង្វែក, ឲ្យចៅហ៊្វាកៅលើកទៅខាងផ្លូវកំពង់សៀមទៅជួយឧកញ៉ា-ចក្រី ៗ ចៅហ៊្វាកៅ លើកទៅដល់ខែត្រកំពង់សៀមបានជួបនឹងទ័ពឧកញ៉ាឧទ័យធិរាជ ប្រជុំកងទ័ពទាំង ២ លើកទៅដល់ខែត្រក្រង ទៅជួបប្រទះនឹងទ័ពឧកញ៉ាសួគ៌ាលោកមឿង ៗ

ពេលនោះ ឧកញ៉ាមឿង ឃើញទ័ពគេលើកមកដល់មានរេហ៍ពលច្រើន ក៏ចាត់កូនច្បងឲ្យធ្វើជាមេទ័ពកាន់ពល ២ ពាន់ ចេញច្បាំងនឹងទ័ពឧកញ៉ាឧទ័យធិរាជ ៗ ស្លាប់កងសង្គ្រាម ៗ កូនច្បងឧកញ៉ាមឿងដឹងថាពលខ្លួនតិច នឹងទ្រាំពុំបានក៏នាំពលដោះថយមកប្រាប់បិតាឲ្យថយទ័ពទៅខែត្រពោធិសាត់វិញ ៗ ឯឧកញ៉ាចក្រីនឹងចៅហ៊្វាកៅ ដឹងថា ឧកញ៉ាឧទ័យធិរាជស្លាប់ហើយ ក៏លើកទ័ពតាមទៅចោមព័ទ្ធបន្ទាយឧកញ៉ាមឿងនៅខែត្រពោធិសាត់គ្រប់ទិសទាំងបួន ៗ

ក្រានោះ ខុកញ៉ា មឿង ក្រាបទូលព្រះបទុកជាថាទ័ពគេលើកមកច្រើនណាស់ ៗ ទ្រង់ប្រឹក្សានឹងមេទ័ពទាំងអស់ថា យើងនឹងគិតធ្វើដូចម្ដេចឲ្យបានរួចពីចំណោមគេ ៗ ទើបខុកញ៉ាសួគ៌ាលោកមឿងក្រាបទូលថា "បើយើងនឹងគិតវាយទំលាយចេញទៅ ពលយើងតិចណាស់ ពលគេមានច្រើនជាង បើទុកជាចេញរួច ក៏គង់តែស្លាប់ទាំងសងខាង ទូលព្រះបង្គំជាខ្ញុំគិតឃើញគំនិតមួយ សុំទទួលអាសាទៅកេណ្ឌកងទ័ពបិសាចមកជួយវាយ យល់ជានឹងឈ្នះគេបានដោយងាយ, សូមទ្រង់ឲ្យជីករណ្ដៅនៅកណ្ដាលទីនេះ ជាធាប់នឹងបានគិតការថ្វាយ" ៗ

ព្រះបទុកជាទ្រង់ត្រិះព្រះសិរហើយត្រាស់ថា "តាំងពីបុរាណរៀងមកមិនដែលឮថាយកខ្មោចមកជួយច្បាំងដល់ម្ដង តាលែងគិតគំនិតនេះចេញទៅ" ៗ ខុកញ៉ាមឿងក្រាបទូលថា "បើទ្រង់ពុំព្រមអនុញ្ញាតទេ ទូលព្រះបង្គំជាខ្ញុំនឹងអារកឲ្យស្លាប់នៅទីនេះ" ទូលហើយក៏ចាប់អាវុធអារក ៗ ព្រះមហាក្សត្រទតឃើញស្ទុះទៅចាប់ដាវជាប់ ទ្រង់ត្រាស់អង្វរថា "តាកុំសម្លាប់ខ្លួនឡើយ បើតាគិតឃើញដូចម្ដេច ចូរធ្វើតាមគំនិតតាចុះ" ៗ ខុកញ៉ាមឿងបានឮត្រេកអរណាស់ ថ្វាយបង្គំលាមកក្រៅ បង្គាប់ឲ្យមនុស្សជីករណ្ដៅយ៉ាងជ្រៅ ដាក់គ្រឿងអាវុធនៅបាតរណ្ដៅជាច្រើន ហើយរៀបតាំងពលិការទាំង៨ទិស រួចប្រជុំកងទ័ពមកជួបជុំស្រេច ទើបងូតទឹកជម្រះកាយឲ្យស្អាតល្អ លើកប្រណម្យនមស្ការដល់គុណព្រះរតនត្រ័យនឹងទេវតា តាំងសច្ចាធិដ្ឋានថា "សូមជួយព្រះមហាក្សត្រកំចាត់អស់សត្រូវ" ក៏ឈរឡើងស្រែកប្រកាសថា "អស់អ្នកទាំងពួងចូរព្រួត

គ្នាធ្វើការឲ្យមាំមួនថ្វាយ កុំកោតញញើតអាក្សថឡើយ យើងលាអ្នកទាំងពួងទៅកេណ្ឌពលបិសាច មកជួយឲ្យទាន់ការក្នុងវេលាយប់នេះមិនខាន" ថារួចលោកចុះទៅក្នុងរណ្ដៅត្រូវនឹងគ្រឿងអាវុធស្លាប់ក្នុងវេលាយប់នោះទៅ ។ ឯកូនប្រុសទី ២-៣ ឃើញបិតាលោតទៅហើយ ទឹកក្នុងចិត្តថា "បិតាទៅកេណ្ឌកងទ័ពបិសាចជាការធំ ពុំមានអ្នកឯណាទៅជាកំដរ ក្រែងក៏គ្មានអ្នកណាជួយ យើងជាកូនគួរតាមបិតាយកអាសាម្ចាស់ផែនដីទើបគួរ" គិតព្រមគ្នាស្រេច ក៏អារកក្បែយជីវិតទាំង ២ នាក់ ។ ឯកូនច្បងនឹងកូនពៅស្ទុះទៅនឹងសម្លាប់ខ្លួនទៀត មេទ័ពព្រួតគ្នាចាប់ជាប់មិនឲ្យទៅបាន ហើយគោះគងខ្លួងស្គរ តាំងហ៊ោលប់ដីកប់ខ្មោចទាំង ៣ ពូនជាផ្នូរសន្ទតហៅថា អ្នកតាឃ្លាំងមឿង តាមបណ្ដាំគាត់ ស្រេចហើយនាំគ្នាទៅក្រាបទូលស្ដេច ។ ទ្រង់ជ្រាបកំសូតព្រះទ័យទ្រង់ព្រះកន្សែងសោកស្ដាយពន់ប្រមាណ ទើបត្រាស់ឲ្យនិមន្តព្រះសង្ឃសូត្រសត្តប្បករណ៍ ហើយទ្រង់ប្រោសប្រណីកូនច្បងរបស់ឧកញ៉ាមឿងឲ្យធ្វើជាឧកញ៉ាសួគ៌ាលោកជួសបិតា ឲ្យកូនពៅធ្វើជាឧកញ៉ាសេនាធិបតីចៅហ្វាយស្រុកខែត្រអមរៈគិរិទ្ធបូរណ៍ ជាមេទ័ពរក្សាប៉មបន្ទាយក្នុងវេលាយប់នោះ ។

លុះដល់ព្រឹកឡើង ព្រះរាជាឲ្យត្រួតត្រាមើលរហ័តពលនឹងលើកទៅលុកសត្រូវនៅវេលាយប់, ពេលនោះមានហ្មដំរីម្នាក់នាំដំរីស ឈ្មោល ១ រូបល្អបរិសុទ្ធកំពស់ ៦ ហត្ថមកថ្វាយ, ទ្រង់ព្រះរាជទាននាមដំរីនោះហៅ

ជា ព្រះពិជ័យកុញ្ជរ ជាព្រះទីនាំងគង់, ហ្វូងដំរីនោះទ្រង់តាំងឲ្យធ្វើជាចៅហ្វាយស្រុកខែត្រក្រង រួចយាងចេញទៅមុខព្រះពន្លា ។ រាស្ត្រប្រជានាំដំរីសេះមកថ្វាយ អ្នកខ្លះបាន ១ អ្នកខ្លះបាន ២ រួមបានដំរី ៣៥ សេះ ៣០ ទ្រង់ត្រេកអរណាស់ ប្រោសព្រះរាជទានយសសក្តិឲ្យធ្វើជាមន្ត្រីតាមសមគួរគ្រប់ខ្លួន ។

ព្រះបន្ទូលជាទ្រង់ចែកទ័ពជា ២ កង ឲ្យឧកញ៉ាសេនាធិបតីជាទ័ពមុខ ឲ្យឧកញ៉ាសួគ៌ាលោកជាមេទ័ពឃុំពល ៥ ពាន់ ទៅលុកទ័ពឧកញ៉ាបក្រី, ព្រះអង្គទ្រង់ពល ១ ហ្មឺនជាទ័ពហ្លួងលើកទៅវាយចៅហ្វាកៅ ព្រះយសរាជានឹងព្រះកិលៀងឃុំពល ៣ ពាន់នៅរក្សាបន្ទាយក្នុងយប់នោះ ។ លុះទ្រង់រៀបចំស្រេច ដល់ពាក់កណ្តាលអធ្រាត្រ ទ្រង់អុជទៀនធូបភ្ញីផ្កាធ្វើសក្ការបូជា ទ្រង់អធិដ្ឋានទឹករំលឹកគុណព្រះរតនត្រ័យនិងឥន្ទ្រព្រហ្មទេវតាដែលមានឫទ្ធិស័ក្តិសិទ្ធិនឹងអ្នកតាឃ្លាំងមឿង សុំឲ្យមានតេជះជោគជ័យ លុះទ្រង់តាំងអធិដ្ឋានរួចស្រេចហើយ ទ្រង់ឡើងគង់ព្រះទីនាំងគជេន្ទ្រស ឈប់ចាំឫក្សពារ ក៏ស្រាប់តែឮសូរសន្ធឹកក្រោមផែនដីព្រមទាំងស្រែកហោ៊សូរសព្ទកក្រើកកំរើកផែនដី ទ្រង់បានឮច្បាស់ទាំងមេទ័ពសេនាទីករក៏បានឮច្បាស់រាល់គ្នា ទើបទ្រង់ឲ្យគោះគងខ្ទួងស្គរហៅពលតាំងហោ៊ទ្រង់លើកទ័ពចេញទាំង ២ កងតម្រង់ទៅវាយបន្ទាយសត្រូវ ។

បំណែកចៅហ្វាកៅនឹងឧកញ៉ាបក្រីដឹងហើយ ក៏តឿនពលឲ្យចូលច្បាំង ។ វេលានោះ ដូចជាមានកងទ័ពមកព័ទ្ធពីក្រោយឮសូរសម្រែកស្រែកហោ៊ជាខ្លាំង សេនាទាហានខាងទ័ពសត្រូវពលសេះដំរីផ្អើលបោល

ជាន់ គ្នាតែយកតែជីវិតរៀងខ្លួន ៗ ខកញ្ញាសួគ៌ាលោកដេញទ័ពសត្រូវទៅដល់ខកញ្ញាចក្រី ៗ បរដំរីចូលប្រជល់គ្នា តែពុំទាន់បានប្រជល់ ស្រាប់តែដំរីខកញ្ញាចក្រីផ្អើល គេចរត់ដូចជាគេចាប់ត្រាត់ធ្លាក់ខកញ្ញាចក្រីទៅលើក្តុកដំរីនៃខកញ្ញាសួគ៌ាលោក ៗ ទទួលចាក់ខកញ្ញាចក្រីស្លាប់ ហើយកាត់យកក្បាលនាំមកថ្វាយព្រះរាជា ៗ ឲ្យដោតក្បាលអាក្បថនៅទីនោះ លុះព្រឹកឡើងចាប់បានគោក្របីដំរីសេះដាវកាំភ្លើងអាវុធផ្សេង ៗ និងស្បៀងអាហារជាច្រើន ៗ ព្រះបទុមរាជាបានច្បាំងឈ្នះទ័ពសត្រូវក្នុងគ្រានេះហេតុដល់ទីបំផុតទ្រង់ច្បាំងឈ្នះទ័ពព្រះស្តេចកនទៀត ទើបបានសោយរាជសម្បត្តិគង់នៅព្រះបរមរាជវាំងលង្វែកជាសុខរៀងមក ៗ

អាស្រ័យមានរឿងនេះហើយ បានជាអ្នកស្រុកពោធិសាត់តែងនាំគ្នាធ្វើបុណ្យឡើងអ្នកតាឃ្លាំងមឿងរៀងរាល់ឆ្នាំ ក្នុង ១ ឆ្នាំធ្វើម្តង ជាប់ជាទំនៀមទម្លាប់ត ៗ គ្នាមក ដើម្បីនឹករំលឹកគុណខកញ្ញាសួគ៌ាលោកហៅ-ហ្វាយស្រុកពោធិសាត់ ដែលជាអ្នកស៊ូប្តូរជីវិតនឹងព្រះមហាក្សត្រ ៗ

*
* *

## ៤ — រឿងអ្នកស៊ូប្តូរជីវិតជួយសង្គ្រោះគេ

រឿងទាហាន ហ៊ាន (១)

កាលពីព្រេងនាយ មានស្រីម្នាក់ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ៗ នាងនេះស្រឡាញ់ចានទាំង ១៤ ជាទីបំផុតចិត្ត ៗ ថ្ងៃមួយ មានខ្ញុំស្រី

---

១ រឿងនេះខ្ញុំសរសេរតាមពាក្យ លោកហង់-គិមសេង កាលធ្វើភូឈ្មួយទី ២ នៃពុទ្ធសាសនបណ្ឌិត្យបានដំណាលប្រាប់ខ្ញុំ ។

ម្នាក់ធ្វើឲ្យបែកចាននោះមួយ ។ ស្រីជាម្ចាស់ចានខឹងណាស់យកកាំភ្លើងបាញ់ខ្ញុំស្រីនោះស្លាប់មួយរំពេចទៅ ។

វេលានោះ មានទាហានម្នាក់ឈ្មោះ ហាំន បានដឹងរឿងនោះ ហើយក៏កាត់ចិត្តប្រថុយស្លាប់ចូលទៅនិយាយនឹងស្រីជាម្ចាស់ចានថា " សូមជំរាបអ្នកស្រី ខ្ញុំជាអ្នកចេះផ្សារចានដែលបែកហើយឲ្យជាប់គ្នាដូចដើមវិញបាន ខ្ញុំនឹងផ្សារចានដែលបែកនោះជូន ប៉ុន្តែខ្ញុំសុំចានទាំង ១១ ដែលនៅល្អមកមើលសិន ដើម្បីខ្ញុំនឹងធ្វើចានបែកនោះ ឲ្យជាប់ជិតស្និទ្ធដូចចានដែលនៅសល់ទាំងអស់ " ។ ស្រីម្ចាស់ចានឮដូច្នោះមានចិត្តត្រេកអរណាស់ ក៏ទៅលើកយកចានទាំង ១១ មកហុចឲ្យទាហានខទទួលយកចានទាំង ១១ នោះបានមកហើយ ក៏លើកបោកបែកខ្ទេចទាំងអស់ទៅនៅមុខនាងម្ចាស់ចាន ហើយប្រាប់ថា "សូមអ្នកស្រីយកកាំភ្លើងមកបាញ់សម្លាប់ខ្ញុំចុះ ត្បិតថាបែកចាន ១ អ្នកស្រីសម្លាប់ជីវិតមនុស្សម្នាក់ នៅសល់ចាន ១១ មុខជាអ្នកស្រីសម្លាប់ជីវិតមនុស្សអស់ ១១ នាក់ទៀត ហេតុនេះខ្ញុំសុខចិត្តយកជីវិតខ្ញុំមកស្លាប់ជួសជីវិតមនុស្សទាំង ១១ នាក់នោះ ។

ស្រីម្ចាស់ចានឮដូច្នោះ ក៏ស្ងួតស្ងាំងកាំងកាំងស្មារតីដួលសន្លប់ទៅលុះដឹងខ្លួនឡើងហើយប្រាប់ទាហានថា " ខ្ញុំខឹងខុសហួសទៅហើយពីកាលមុន ឥឡូវនេះខ្ញុំមិនខឹងនឹងអ្នកទេ ព្រោះអ្នកជាប់ចិត្តយកជីវិតខ្លួនមកស្លាប់ជួសគេ ដោយសារតែចង់ជួយសង្គ្រោះគេ ហេតុនេះខ្ញុំអរគុណអ្នកណាស់ សូមអ្នកអញ្ជើញទៅវិញចុះ " ។

ចប់

# រឿងព្រះចៅឧរុសក៉ាំងសាជ

និង

# ព្រះចាងសៅហោវស្តាធី

អ្នកស្រីពេជ្រ–សល់ ហៅ សារិះយ៉ាំង ប្រែរៀបរៀង

(តមក)

---

ថ្ងៃមួយ នៅពេលដែលពួកនាម៉ឺនត្រៀមខ្លួនត្រៀបត្រា ចាំគាល់ព្រះមហាក្សត្រនៅពេលជំនុំ ស្រាប់តែនាម៉ឺនហួងប្រាប់ថា មិនដឹងជាស្តេចយាងទៅឯណាបាត់ ព្រោះពីថ្ងៃម្សិលកន្លងពេលល្ងាចព្រះអង្គផ្ទំនៅលើព្រះខែន ប៉ុន្តែឥឡូវនេះ ព្រះអង្គមិនដឹងជាស្តេចយាងទៅទីណា យើងរកពេញក្នុងព្រះបរមរាជវាំងហើយមិនឃើញសោះ ។ ប៉ុន្មានថ្ងៃក្រោយមកក៏នៅតែរកព្រះមហាក្សត្រមិនឃើញទៀត ពួកចៅជិតចៅបមម៉ឺនម៉ែនាងក៏នាំគ្នាលាបមុខល្បឿង យកផ្កាកូឡាបទៅបាចសាចពាសពេញមុខស្វេត-ច្ឆត្រ ហើយនាំគ្នាយំសោកស្តាយតែពល់រូប ។

ក្នុងចំណោមអ្នកទាំងនោះ លោកមុយអេស៊ីនសោកសង្រេងជាងគេ ព្រោះមិនដឹងជាម្ចាស់ខ្លួនទទួលទុក្ខឬសុខយ៉ាងម្តេច លោកយំរៀបរាប់ថា ៖

— ឱ ! ព្រះមហាក្សត្រ តើព្រះអង្គស្តេចយាងទៅណា? ម្តេចបានជាស្រាប់តែបាត់ស្ងាត់ឈឹង? ឬមួយព្រះអង្គចង់យាងទៅដោយព្រះទ័យព្រះអង្គទេ? ទេ ប្រាកដជាមិនមែនដូច្នេះទេ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថាយើងទាំងអស់គ្នាស្រឡាញ់ព្រះអង្គណាស់ ម្តេចក៏ព្រះអង្គ

ធ្វើឲ្យយើងកើតទុក្ខដូច្នេះ, ប្រហែលជាអំពើរបស់ពួកធ្មប់ទេដឹង ដែលលួចលាក់ព្រះអង្គនេះ ។

ពាក្យលោកមុយអេស៊ុនខាងក្រោយនេះ ហាក់ដូចជាមើលឃើញព្រោះព្រះនាងសោហោរិស្តាទី ដែលនៅគង់ឯកោះសោហោរិស្តង់បានប្រើបំរើឲ្យមកនាំព្រះអង្គចេញពីព្រះបរមរាជវាំងទៅ ។ ព្រះមហាក្សត្រកំពុងតែសព្វព្រះរាជហឫទ័យរកអ្វីប្រៀបគ្មាន ឯពួកនាម៉ឺននៅក្នុងព្រះនគរគិតតែនាំគ្នាយំទៅវិញ ។

នៅពេលដំបូងដែលព្រះនាងឡើងគ្រងរាជ្យស្នងព្រះបិតា ព្រះនាងរវល់តែការផែនដី ។ ក្រោយមក ដោយព្រះនាងនៅតែនឹកស្រឡាញ់ព្រះបាទរុសក៏នសាដ ហើយនឹងទ្រង់ជ្រាបថា ព្រះអង្គស្មោះត្រង់នឹងព្រះនាងពិត ព្រះនាងក៏ប្រើឲ្យគេទៅនាំព្រះអង្គមកថ្វាយព្រះនាង ។

ព្រះមហាក្សត្រលុះទ្រង់ទតឃើញព្រះនាង ក៏ទ្រង់សោមនស្សជាអនេក ហើយក៏មានព្រះបន្ទូលទៅកាន់ព្រះនាងថា ៖

— ឱ ! ព្រះនាងអាទិទេពអើយ ! មួងនេះខ្ញុំបានមកជួបព្រះនាង ! កាលពីមុនខ្ញុំអស់សង្ឃឹមទៅហើយ ព្រោះខ្ញុំស្មានថាព្រះនាងក្បត់ខ្ញុំ ។

— ទេព្រះអង្គ ! នៅស្ថានយើងនេះការព្រាត់ប្រាសគ្នាជាការធម្មតាទេ មិនមែនជាការបង្កឲ្យមានទុក្ខឡើយ ហើយយើងគ្មានព្រួយបារម្ភអ្វីសោះ ។

— ចិត្តរបស់ខ្ញុំក៏នៅនឹងដដែលដូចជាព្រះនាងដែរ, ខ្ញុំគ្រាន់តែជាមនុស្សលោក ក៏ប៉ុន្តែពេលដែលយើងបែកគ្នានោះដូចជាយូរពេកណាស់ ខ្ញុំទន្ទឹងចាំតែពេលនឹងបានជួបព្រះនាង ។

— ខ្ញុំម្ចាស់ដឹងច្បាស់ហើយរឿងនេះ ព្រោះឃើញថាព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់មែន គ្មានជាកលល្បិចទេ ។ បើដូច្នេះ យើងត្រូវរួមរ៉ាស្នានឹងគ្នា ។

ព្រះមហាក្សត្រទ្រង់អរគុណ ចំពោះព្រះទ័យដ៏វិសេសនៃព្រះនាងសេហេរិស្ដាទី ហើយទ្រង់សន្យាអំពីសេចក្ដីស្នេហាគ្មានទីបញ្ចប់ចំពោះព្រះនាង ។ ក្រោយមកព្រះនាងទ្រង់បង្គាប់ឲ្យពួកបណ្ដាក្សត្រក្នុងកោះនោះមកប្រជុំ ហើយព្រះនាងប្រកាសថា:

— អាទិទេពធំ-តូចទាំងឡាយ ដែលបានអញ្ជើញមកស្ដាប់ខ្ញុំក្នុងពេលនេះ ខ្ញុំសូមជំរាបថា ក្រោយដែលព្រះវរបិតាខ្ញុំទ្រង់សុគតទៅ អ្នកបានប្រគល់រាជសម្បត្តិឲ្យខ្ញុំព្រមទាំងបានសច្ចាថា នឹងស្ដាប់បង្គាប់ខ្ញុំផង ឥឡូវនេះ ខ្ញុំសូមជំរាបអស់លោកថា ខ្ញុំនឹងរៀបអាពាហ៍ពិពាហ៍ខ្លួនខ្ញុំជាមួយនឹងព្រះមហាក្សត្រក្រុងចិន ហើយខ្ញុំសូមឲ្យអ្នកកល់គ្នាទុកស្ដេចអង្គនេះជាចៅហ្វាយនាយដូចជាខ្លួនខ្ញុំដែរ ។

ពួកអាទិទេពទាំងឡាយនាំគ្នាទះដៃ ទទួលអរសាទរនឹងការជ្រើសរើសរបស់ព្រះនាង ហើយព្រះបាទរុសវ៉ានសាដក៏ទទួលអភិសេកជាស្ដេចនៅកោះសេហេរិស្ដង់ ។ ប៉ុន្តែមុននឹងបានរួមរ៉ាស្នាជាមួយនឹងព្រះនាង ។ ទូលព្រះអង្គថា ៖

— ព្រះមហាក្សត្រដ៏ប្រសើរ, ដើម្បីសម្រេចសុភមង្គលដល់យើងទាំងពីរនាក់ ខ្ញុំសូមព្រះអង្គសច្ចានឹងខ្ញុំម្ចាស់ ហើយសូមទ្រង់កាន់ពាក្យនោះឲ្យ

ផាប់, បើកាលណាព្រះអង្គមិនគោរពដល់ពាក្យសច្ចារបស់ព្រះអង្គទេ យើងទាំងពីរនាក់នឹងមានទុក្ខ ។

– ឱ ! ព្រះនាងខ្ញុំមបណ្ដូលចិត្តខ្ញុំអើយ ! ឲ្យតែព្រះនាងនិយាយមកចុះ បងបេះតែធ្វើតាមប្អូនទាំងអស់ សុំឲ្យតែប្អូនសប្បាយចិត្ត ។

– ការដែលខ្ញុំម្ចាស់សុំឲ្យព្រះអង្គកាន់គងពេលនេះ ជាការដែលព្រះអង្គត្រូវចំអត់ទ្រាំយ៉ាងពិបាកក្នុងព្រះទ័យណាស់ ខ្ញុំម្ចាស់ខ្លាចក្រែងព្រះអង្គទប់ព្រះទ័យពុំបាន, ព្ហកអាទិទេពដូចជារូបខ្ញុំម្ចាស់មានអារម្មណ៍ផ្សេងអំពីមនុស្សលោក ហើយយើងប្រព្រឹត្តផ្សេងអំពីមនុស្សលោកទៀតដោយយើងមានទម្លាប់នឹងច្បាប់បញ្ញត្តិពិសេសផ្សេងៗ រួមសេចក្ដីទៅគឺថាបើព្រះអង្គពុំសព្វព្រះរាជហឫទ័យនឹងទទួលធ្វើតាមខ្ញុំម្ចាស់ ទាំងងនឹតងងល់ទេនោះ ខ្ញុំម្ចាស់មិនអាចនឹងនៅរួមរក្សានឹងព្រះអង្គបានយូរឡើយ ។

– យី ! ស្អី? តែប៉ុណ្ណឹងទេ ការដែលថាឲ្យខ្ញុំប្រឹងនោះឬ ខ្ញុំទំតែធ្លាប់ បើដូច្នេះប្អូនមានមន្តិលស្អប់ពោះមនុស្សលោកផង ហើយប្អូនជឿច្បាស់ចុះថា ពីថ្ងៃនេះទៅបងគ្មានធុរៈអ្វីក្រៅអំពីធ្វើតាមបង្គាប់របស់ប្អូនទាំងអស់ទេ ព្រោះបងត្រូវនៅក្រោមអំណាចប្អូន ។

– បើដូច្នេះ កាលណាទ្រង់ឃើញខ្ញុំម្ចាស់ធ្វើអ្វីទាស់នឹងព្រះទ័យព្រះអង្គ សូមទ្រង់កុំបន្ទោសខ្ញុំម្ចាស់ឲ្យសោះ ។

– ពិតហើយប្អូន ! តើប្អូនធ្វើអ្វីដែលបងមិនត្រូវចិត្ត ?

– ទោះជាការដែលខ្ញុំម្ចាស់ប្រព្រឹត្តខុសពីធម្មតាលោកយ៉ាងណា ក៏សូមទ្រង់យល់ថាជាការចាំបាច់ទាំងអស់ តើទ្រង់ព្រមសន្យាជាដាក់បឬ?

— ជាជកប ! ជូនសំឡាញ់ !

ក្រោយពីចុះខសន្យានោះមក គេក៏រៀបចំអភិសេកព្រះរាជាទាំងពីរព្រះអង្គ ៗ ព្រះបាទទ្រុសរាំនសាង សោយសុខអស់រវាងមួយឆ្នាំគត់ជាមួយនឹងព្រះនាងសោហេរិស្តានី ក្នុងពេលនោះព្រះអង្គក្តោបព្រះរាជធានីចិន ក្តោបបណ្ដាជនចិន ៗ ព្រះនាងសោហេរិស្តានីទ្រង់ប្រសូតបានព្រះរាជបុត្រមួយព្រះអង្គប្រកបដោយរូបឆោមល្អគ្មានពីរ នៅពេលនោះព្រះមហាក្សត្រទ្រង់យាងចេញទៅបរបាញ់សត្វ ៗ លុះពួកអាមាត្យទៅទូលទ្រង់ថាព្រះនាងទ្រង់ប្រសូតបានព្រះរាជបុត្រា ទ្រង់ត្រេកអរពន់ពេកហើយក៏ទ្រង់ត្រឡប់ចូលមកព្រះបរមរាជវាំងភ្លាម, ដល់ហើយទ្រង់ទតយល់ព្រះនាងគង់ក្បែរភ្នក់ភ្លើងមួយឆេះរន្ទាល បីទាំងព្រះរាជបុត្រានៅនឹងព្រះហស្តផង ៗ ព្រះមហាក្សត្រទ្រង់យកព្រះរាជបុត្រមកបីថ្នមថើបហើយក៏ទ្រង់ហុចទៅឲ្យព្រះរាជទេវីវិញ ... ស្រាប់តែព្រះនាងលើកព្រះរាជបុត្រនោះបោះទៅក្នុងភ្លើង ហើយស្រាប់តែបាត់ទាំងភ្លើងទាំងកូនតូចនោះទៅ ៗ ព្រះមហាក្សត្រទ្រង់ស្លុតព្រះទ័យដោយឃើញការដ៏ចំឡែកយ៉ាងនេះ តែទ្រង់នឹកឃើញកិច្ចសន្យារបស់ព្រះអង្គ ទ្រង់ខំសង្កត់ព្រះទ័យហើយក៏ទ្រង់ថយទៅក្នុងក្រឡាបន្ទំ, ទ្រង់សោកស្ដាយព្រះរាជបុត្រតែមួយព្រះអង្គឯង,ថា ៖

ឱ ! ចុះខ្ញុំមានបាបកម្មអ្វី មកធ្វើឲ្យខ្ញុំវេទនាយ៉ាងនេះ ! ទេវតាលោកបានធ្វើឲ្យខ្ញុំមានកូនប្រុសមួយ ហើយម្ដាយយកកូនទៅបោះក្នុងភ្លើងហើយទោះជាឃើញនូវអំពើដ៏សាហាវយ៉ាងនេះហើយ ក៏នៅតែនិយាយ

ពុំបានទៀត ។ ឱ! លោកអើយ ចុះម្ដាយអីក៏ខុសគេដូច្នេះ! ម្ដាយអីក៏កាចម៉្លេះ? ប៉ុន្តែ ណ្ហើយចុះ អញត្រូវស្ងៀម, ការដែលគេធ្វើយ៉ាងនេះប្រហែលជាមានហេតុផលរបស់គេទេដឹង! ។

លុះទ្រង់គិតដូច្នេះហើយក៏ទ្រង់នៅស្ងៀម, តោះជាទ្រង់ចង់ជ្រាបហេតុយ៉ាងណាក៏ទ្រង់ពុំហ៊ានសួរ ។

មួយឆ្នាំក្រោយមក ព្រះនាងទ្រង់ប្រសូតបានព្រះរាជបុត្រីមួយព្រះអង្គល្អលើសព្រះអង្គម្ចាស់ច្បងទៅទៀត ។ ទ្រង់ក៏ប្រទានព្រះនាមថាបាល់តីស ។ រូបឆោមឆើតឆាយនៃព្រះរាជបុត្រីធ្វើឲ្យព្រះបាទរុសាំងសាជរីកពេញព្រះហឫទ័យពន់ពេក ព្រះអង្គមិនទៀយណាយនឹងគយគន់ព្រះរាជបុត្រីនោះ នាំឲ្យទ្រង់ភ្លេចព្រះរាជបុត្រាច្បង ។ ក៏ប៉ុន្តែមិនយូរប៉ុន្មាន ស្រាប់តែមានឆ្កែញីមួយធំសម្បុះ ហាមាត់ជន្ទ្រឹងដើរចូលទៅក្នុងព្រះបរមរាជវាំង ព្រះនាងសេហេរ៉ាស្តាទីទ្រង់ត្រាស់ហៅឆ្កែថា:

— នែ ចូរឯងយកកូនស្រីនេះទឹងអន្ទឹងរបស់វាទៅ ។

ឆ្កែក៏ស្ទុះក្លុតទៅជិតអន្ទឹងកូនហើយក៏ខាំពាំយកចេញបាត់ទៅ ។ យើងពិបាកនឹងថ្លែងអំពីទុក្ខនៃព្រះមហាក្សត្រ ដែលទ្រង់យល់ឆ្កែពាំយកព្រះរាជបុត្រីនោះទៅណាស់ ។ ការដែលទ្រង់បានសច្ចាចំពោះព្រះនាងរួចទៅហើយនោះ នាំឲ្យព្រះអង្គទំទប់ស្ទើរតែក្លាយព្រះទុក ។ ព្រះអង្គទ្រង់តែទៅពួនសោកសង្រែងតែមួយព្រះអង្គឯងក្នុងបន្ទប់ ហើយទ្រង់នឹកឃើញដល់ទៅក្ដីស្នេហ៍នៃព្រះរាជបុត្រាព្រះអង្គផង ។ ទ្រង់ព្រះកន្សែងរៀបរាប់ថា៖

- យី ! នាងសេហេរិស្តាសាទី ! នាងគ្មានចិត្តធម៌កងខ្លួនសោះ គឺអ៊ីនាងហ៊ានធ្វើកម្មកូនខ្លួនដូច្នេះ, តែថាបើគ្មានការប្ដូក ពួកអាទិទេពមិនធ្វើទេ, នាងបាននិយាយប្រាប់យើងដែរពីដំបូង ថាមានតែការបំពានបាប់ទេដែលប្រើឲ្យនាងបំពេញកិច្ចនីមួយៗបាន, ប៉ុន្តែការបំពានបាប់យ៉ាងនេះដូចជាផ្ដេសផ្ដាស, អ៊ីក៏រលាស់ទៅបង្គាប់ឲ្យម្ដាយលះបង់កូនបង្កើតរបស់ខ្លួន ទាល់តែ... ឱ ! ខ្ញុំនឹកឃើញហើយ : តែកាលណាអាទិទេពយកមនុស្សលោកធ្វើជាប្ដី ប្រហែលជាមានច្បាប់ថាឲ្យបំបាត់ផលដែលបានមកអំពីការរួមរ័ករនោះ, យីអ៊ីក៏សម្ញៀមម្ល៉េះ!... ឱ ! ព្រះនាង ! ទោះជាខ្ញុំស្រឡាញ់ព្រះនាងយ៉ាងណា ក៏ខ្ញុំពុំអាចនឹងទាំទៅជាមួយនឹងព្រះនាងតទៅទៀតបានឡើយ ។

ព្រះមហាក្សត្រជាបុគ្គលមួយរូបដែលមានសតិរឹង ទ្រង់មិនបង្ហាញទឹកព្រះភក្ត្រឲ្យព្រះនាងជ្រាបទេ ប៉ុន្តែវៃមួយព្រះអង្គមានបន្ទូលប្រាប់ទៅព្រះនាងថា ៖

- ព្រះនាង ! បងចង់ទៅមើលនគរបងណាស់ ប្រហែលក្រុងចិនបង់ស្រេចឲ្យតែបងត្រឡប់វិលវិញ សូមព្រះនាងបើកឲ្យបងទៅមើលក្រុងបងវិញផង ។

ព្រះនាងទ្រង់តបវិញថា ៖

- ខ្ញុំម្ចាស់សុខចិត្តបំពេញព្រះរាជហឫទ័យព្រះអង្គ នឹងបំពេញចិត្តក្រុងព្រះអង្គ ។ ម្យ៉ាងទៀត ក្នុងខណៈនេះព្រះរាជធានីព្រះអង្គត្រូវការព្រះអង្គជាដាច់ខាត ខ្ញុំម្ចាស់ដឹងច្បាស់ថាពួកមុនគោលលើកទ័ពមួយ

កង់យ៉ាងពូកែមកច្បាំងនឹងព្រះអង្គ សូមស្ដេចយាងទៅការពារអាណាចក្រព្រះអង្គផង បើទុកជាពួកសេនាទាហានព្រះអង្គពូកែប៉ុនណាក៏ដោយ តែកាលណាព្រះអង្គនាំមុខ ពួកនោះនឹងមានសេចក្ដីក្លាហានជាជាងទៅច្បាំងតែឯង ខ្ញុំម្ចាស់នឹងទៅតាមមើលព្រះអង្គដែរ ។

ត្រាស់ហើយព្រះនាងទ្រង់មានបន្ទូលហៅទូតអាទិទេពមួយរូបមកហើយបង្គាប់ឲ្យជូនព្រះរាជាទៅទីរាំងនៅប្រទេសចិនមួយរំពេច ។ ការត្រឡប់ទៅនគរវិញនៃព្រះបាទរុស្សកាំទសាដនោះធ្វើតែមួយភ្លែតក៏ដល់ភ្លាម ។

លោកមុយអេស៊ីនគ្រាន់តែក្រឡេកឃើញព្រះអង្គភ្លាម ក៏ត្រេកអរឥតឧបមា លោកតែទៅក្រាបថ្វាយបង្គំព្រះអង្គ អោនក្បាលទាល់តែដល់ដីហើយពោលថា ៖

— ឱ ! ព្រះគុណម្ចាស់អើយ ! ព្រះលោកជួយខ្ញុំមែន ! ហើយព្រះលោកប្រគល់មហាក្សត្រមកដល់ប្រជាជនរបស់លោកវិញ, កង់ពេលដែលព្រះអង្គយាងទៅបាត់ ទូលព្រះបង្គំជាខ្ញុំបានកាន់ការអាណាចក្រជំនួសព្រះអង្គ, ហើយដល់យូរមក ដោយគ្មានបានដំណឹងអ្វីអំពីព្រះអង្គសោះ ក៏អស់សង្ឃឹមថាទ្រង់នឹងយាងត្រឡប់មកវិញ ពួកនាម៉ឺនសព្វមុខមន្ត្រីទាំងប៉ុន្មាននាំគ្នាលើករាជសម្បត្តិប្រគល់ឲ្យទូលព្រះបង្គំ ទោះជាទូលព្រះបង្គំប្រកែកយ៉ាងណាក៏គេពុំសុខចិត្ត ។ ឥឡូវនេះទ្រង់យាងមកដល់ហើយ ឱ ! ព្រះករុណាជាម្ចាស់ជីវិតខ្ញុំអើយ សូមព្រះអង្គឡើងគង់លើស្វេតច្ឆត្រ ដែលខ្ញុំព្រះអង្គបានអង្គុយជំនួសព្រះអង្គជាយូរណាស់មកហើយ ។

(មានត)

# សុភាសិតរាជនីតិ

ពាក្យកាព្យ

## អ្នកឧកញ៉ាមហាវិធិប្ល័យ នៅ

### រៀបរៀង

(តមក)

---

អធិប្បាយប្រាយប្រែកែតាមប្រៀប លោកធៀបរៀបរាប់តាមតម្រា
គឺព្រះរាជបុត្រទ្រង់ជេដ្ឋា សញ្ញាសន្មតប្រាកដឈ្មោះ ៗ
ជាធ្នង់បង្គំព្រះនគរ ព្រោះអាចទ្រង់ទ្រវង្សខ្ពង់ខ្ពស់
បុរោហិតបណ្ឌិតពិតចំពោះ នោះលោកពិគ្រោះសន្មតថា ៗ
ជាក្អែកព្រះនគរពិតប្រាកដ កំណត់ដ្បិតចេះក្បួនតម្រា
ឥសីមុនីមានរឹទ្ធិក្លា ឈ្មោះថាទង់ជ័យដែនភពការ ៗ
សេដ្ឋីគហបតីដ៏មានទ្រព្យ លោករាប់ជាពោះនគរ
បុត្រីបុត្រាស្រ្តីប្រជា ដូចនាកញ្ចក់ឆ្លុះវិស័យ ៗ
បិតាមាតាលោកប្រៀបទុក ដូចមណ្ឌលមុខកែងអាស្រ័យ
កញ្ចក់ឆ្លុះស្វាងក្លីសត្វថ្ងៃ ឧបមេយ្យដូច្នេះទើបចាត់ថា ៗ
កូនប្រុសកូនស្រីជនទាំងឡាយ អធិប្បាយឈ្មោះមុខរាជសីមា
យោធាទាហានដ៏ក្លៀវក្លា ឈ្មោះថាដៃជើងព្រះនគរ ៗ
ហេតុនោះគួរទ្រង់កុំឃ្លានពាន ទន្ទ្រានរានរំបឲ្យរីករ
ទឹងបានក្សេមក្សាន្តស្មោះសាទរ ដោយព្រះភូធរទ្រង់ប្រណី ៗ
ន័យមួយទៀតក្សត្រទឹងអមាត្យ គប្បីឧហាតជាប្រក្រតី

ប្រជុំប្រឹក្សាការក្រែក្រៃ　　គឺបីវេលានាមួយថ្ងៃ ។
ហើយទ្រង់ប្រកបព្រមដោយអង្គ　　ប្រាំពីរត្រឹមត្រង់អចិន្ត្រៃយ៍
ប្រព្រឹត្តពិនិត្យតាមនិស្ស័យ　　អធ្យាស្រ័យមិនលាក់មិនលះលា ។
មួយគឺញុំាងកិច្ចការទាំងឡាយ　　សប្បាយក្សេមក្សាន្តវឌ្ឍនា
រាបទាបព្រមព្រៀងក្នុងភាព　　ឥតមានកយាជាសៅហ្មង ។
មួយគឺយកខ្ជាត់បាត់ជាសួយ　　មិនឲ្យរាស្ត្រព្រួយដល់ប៉ុនល្អង
នឹងដាក់អាជ្ញាទោសាផង　　តាមសមគួរហោងត្រឹមត្រូវល្អិត ។
មួយគឺគប់អានចាស់ព្រឹទ្ធា　　ប្រព្រឹត្តធម្មាជាសុចរិត
មួយមិនបៀតបៀនគិតស្នេហ៍ស្និទ្ធ　　រិតត្បិតបុត្រអ្នកនគរ ។
មួយគឺធ្លាប់គប់អានទេវតា　　បូជាពលីការដោយសាទរ
ឲ្យធ្វើតាមធ្លាប់ជាប់វេរ　　សូមពរទេវរិទ្ធិប្រសិទ្ធិស័ក្តិ ។
មួយទ្រង់រក្សាសមណព្រាហ្មណ៍　　មាននាមទ្រង់សីលស្មោះស្មើស្ម័គ្រ
ឧបត្ថម្ភគាំពារមិនឲ្យអាក់　　សំណាក់អាស្រ័យព្រះទ័យស្មើ ។
ធម៌ប្រាំពីរនេះគួរមហាក្សត្រ　　ប្រតិបត្តិជានិច្ចដ៏ប្រសើរ
ទ្រង់គ្រប់សព្វសុសតាមដំណើរ　　កុំឲ្យសើរើធ្វេសខាតខាន ។
សទ្ទញ្ញោណយោសមហោ　　ក្សត្រឧត្តមោត្រង់រាជហាន
គប្បីជ្រាបកិច្ចគិតប្រមាណ　　សម្រួលចិត្តក្សាន្តរាស្ត្រប្រជា ។
ហើយធ្លាស់ក្នុងទីពិចារណា　　កាត់ការសទ្ធិះរាស្ត្រនានា
ដោយព្រះយោបល់យល់ពុះពារ　　ឲ្យរាស្ត្រលាកលាការសង្ស័យ ។
ខ្ពុនានៈប្រៀនប្រាប់រាស្ត្រគ្រប់ប្រាណ　　ឲ្យបានស្មោះស្មានពន់ពេកក្រៃ

ត្រេកអរទានសីលអចិន្ត្រៃយ៍ អធ្យាស្រ័យស្រោចស្រង់ទ្រង់មេត្តា ។
ញញឹមជាមុនទើបទ្រង់ត្រាស់ តម្រាស់ការសិតគិតកិច្ចការ
តាមព្រះយោបល់យល់ក្តីថ្លា ដល់ខ្ញុំបរិវារពលបរិស័ទ ។
យហាវុត្តហិគុណោហិ គតិអធិប្បាយតាយថែងតាត់
ថាព្រះបមពង្សវង្សមហាក្សត្រ គប្បីប្រតិបត្តិប្រកបយក ។
នូវគុណទាំងឡាយលោកសំដែង តាំងតែងថ្លែងទុកពីមុនមក
គួរទ្រង់ត្រេកត្រាប់តាប់រំរក លៃលកឲ្យត្រូវគ្រប់ប្រការ ។
ទើបនឹងប្រាប់ប្រាមហាមប្រដៅ អស់ពស្ត្រក្នុងក្រៅក្រុងរអា
ខ្ជុបខ្ជាបអំណាចព្រះបេស្តា សុខាក្សេមក្សាន្តទាំងផែនដី ។
ហើយនឹងចំរើនព្រះកិត្តិយស ខ្ពង់ខ្ពស់ដោយរិទ្ធិបុណ្យរាសី
មង្គលវិមលសុខសិរី សុវត្ថិថេរថិតតាមប្រាថ្នា ។
និប្ពុស្សុត្តធរោបញ្ញោ ខត្តិយវង្សា អគ្គឯណា
ទ្រង់មានព្យាយាមដ៏ក្លៀវក្លា ឧស្សាហ៍តែងត្រាប់ស្តាប់ព្រះធម៌ ។
ជានិច្ចកាលជាប់ប្រក្រតី ជ្រាបអត្ថលោកិយលោកុត្តរ
ព្រះទ័យមោះមុតមិនញាប់ញ័រ ទូទៅឥតទាល់សល់ចំពាក់ ។
ហើយមានព្រះទ័យមិនប៉ុស្សា ឥច្ឆាសម្បត្តិជនជាតិជាក់
គួរទ្រង់សមាគមភិរម្យរ័ក្ស សំណាក់អាស្រ័យគ្រូអាចារ្យ ។
លោកជាអ្នកប្រាជ្ញអាចចេះដឹង អត្ថធម៌ផ្សេងៗគ្រប់ប្រការ
ជាទីកាត់បង់ក្តីកង្ខា ឈ្វេងយល់បញ្ហាអត្ថធម៌ផង ។
បើបានប្រកបព្រមដោយអង្គ ប្រាំពីរត្រឹមត្រង់ត្រូវឥតហ្មង

ព្រមទាំងកដវត្ថុប្រាំពីរកង　　បុរាណចែងចងពណ៌នាថា ។
ក្សត្រអង្គនោះនឹងបរិបូណ៌　　ឥស្សូរិយសុខសក្កា
ព្រមទៅដោយយសបរិវារ　　ល្បារពទ្ធិកអធិកក្រៃ ។
នឹងបានបំរើនគ្រប់ប្រការ　　រដ្ឋាប្រសើរអចិន្ត្រៃយ៍
ប្រកបសុវត្ថិសុខសព្វថ្ងៃ　　អាស្រ័យដោយទ្រង់យុត្តិល្អ ។
អំណាចអាចឈ្នះបច្ចាមិត្រ　　ឆ្ងាយជិតពិតពុំហ៊ានតាំងត
មូលមកកត្តិសមោសរ　　អំណរសាន្តសុខទាំងផែនដី ។
មហាក្សត្រទ្រង់ធម៌ទសពិធ　　បណ្ឌិតសរសើរគុណបារមី
ស្មើគុណទេវតាទាំងប្រាំបី　　មានអង្គកោសីជាប្រធាន ។
យថាសក្កោទេវរាជា　　សម្តេចឥន្ទ្រាទ្រង់រិះធ្យាន
សង្គ្រោះទេវតាដោយទូន្មាន　　ប្រិតប្រៀនគុណទោសប្រោសប្រដៅ ។
ដូចព្រះមហាក្សត្រទ្រង់មេត្តា　　ដល់ខ្ញុំពលការទាំងក្នុងក្រៅ
លើកលើកទោសតាមលួងខ្លៅ　　ប្រោសហៅហាមប្រាមដូចឆ្ពោះឯង ។
អដ្ឋមាសំយថាកិច្ចោ　　រឺព្រះសុរិយោរះចាំងចែង
ញុាំងទឹកឲ្យស្ងួតរីងហួតហែង　　ដោយសែងរស្មីប្រាំបីខែ ។
នេះដូចជាអង្គមហាក្សត្រ　　នឹងយកសួយខាត់ប្រយ័ត្នថែ
បារម្ភថប់ក្រស្តព្រួយប្រាណប្រែ　　សង្គ្រោះយកតែតាមសមគួរ ។
យថាបិយំអបិយំវា　　ព្រះយមរាជានឹងសាកសួរ
បុណ្យបាបសត្វនរកឲ្យគ្រប់គួរ　　មិនមួរើសមុខស្អប់ស្រឡាញ់ ។

នេះដូចអគ្គក្សត្រខត្តិយវង្ស ទ្រង់ទឹងវិនិច្ឆ័យមិនគ្មានខ្មាញ់
ប្រៀបផ្ទឹមសេចក្តីតាមឈ្នះចាញ់ គិតកាញ់ឲ្យគួរតាមត្រិត្យា ។
មិនរើសមុខថាស្អប់ស្រឡាញ់ ទោះចាញ់ទោះឈ្នះដូចម្តេចម្តា
ព្រះទ័យតាំងស្មើបរិសុទ្ធថ្លា សត្យាដូចអគ្គព្រះយមពិត ។
យថាបុគ្គិខទុកា ធម្មតាសមុទ្រធំពំនិត
មិនមានព្រាថ្នាប៉ងគន់គិត ប្រព្រឹត្តយកគុណប្រយោជន៍ផល ។
ពីស៊ីងតូច ៗ ផងនានា ហើយអាចធានាហូរឲ្យដល់
សព្វស៊ីងបឹងបួរជោរស្ងប់ស្ងល់ ពោរពេញមិនសល់ដោយជលសា ។
ប្រៀបដូចមហាក្សត្រខត្តិយវង្ស គ្មានព្រះបំណងប៉ងព្រាថ្នា
សម្បត្តិផងរាស្ត្រខ្ញុំរាជការ ទ្រង់មានមេត្តាជាប្រធាន ។
សង្គ្រោះបំពោះដោយសាធារណ៍ បរិច្ចាគទ្រព្យាឲ្យជាទាន
ដល់រាស្ត្រប្រជាណាដែលគ្មាន មិនឲ្យអត់ឃ្លានអនាថា ។
បរិបុណ្ណំយថាបន្ទុំ វាក្យំ ជាប់បទពាក្យឧបមា
បិតុជនប្រុសស្រីក្នុងលោកា បានឃើញចន្ទ្រាពេញបូណ៌មី ។

(មានត)

# ពេជ្រព្រះរាជា

លោក ស៊ិន - ហ៊ាន ប្រែរៀបរៀង

លោក ឃៀវ - អ៊ិន ពិនិត្យកែសម្រួល

(តមក)

---

មើលៗទៅ ឃើញគួរឱ្យតក់ស្លុតពន់ពេក, មាណពឃើញដូច្នោះ ក៏មានសេចក្ដីវេទនាចំពោះមេគោនិងកូនគោយ៉ាងក្រៃលែង ដោយឃើញអាការរបស់កូនគោដែលត្រូវគេវាយរត់ត្រឡប់ទៅនោះ ក៏កើតសេចក្ដីតក់ស្លុតទាល់តែហូរទឹកភ្នែកចេញប្រោកៗ ព្រោះបានគិតដល់ខ្លួនឯងដែលមានម្ដាយ តើសេចក្ដីស្រឡាញ់របស់ម្ដាយដែលមានមកលើខ្លួននោះប៉ុនណា ? មាណពទើបសម្រេចក្នុងចិត្តថា “ស្រួលហើយ ! អាត្មាអញនឹងចូលទៅគាល់ព្រះរាជា ទូលទាស់មិនឱ្យព្រះរាជាធ្វើពិធីបូជាយញ្ញ សូម្បីខ្លួនឯងត្រូវអស់ជីវិត ក៏ព្រមទទួលតាមហេតុការណ៍” ហើយក្រោកឡើងចាកទីដែលខ្លួនអង្គុយ ទើបប្រាប់អមាត្យបាលិតថា ៖

“សំឡាញ់ហាស់ ! ខ្ញុំនឹងអត់ទ្រាំមើលនូវសភាពខ្មនានចិត្តតាមរបៀបនេះមិនបានទេ ខ្ញុំនឹងទូលទាស់នូវការធ្វើពិធីរបៀបនេះឱ្យបាន” ។

អមាត្យបាលិតឃើញអាការរបស់មាណព រឹងរូសដូច្នោះហើយ ក៏ធ្លាក់ទឹកចិត្តជាខ្លាំង ទាញដៃមាណពឱ្យអង្គុយវិញ មាណពក៏មិនព្រមព្យាយាមរលាស់ចេញ អមាត្យបាលិតមិនព្រមបណ្ដោយ ។ អាការចាប់ប្រទន់ប្រទាញគ្នាទៅវិញទៅមក នៃជនទាំង ២ នាក់នេះ ធ្វើឱ្យ

ព្រះរាជាបែរព្រះភ័ក្ត្រមកឃើញ ទើបទ្រង់បង្គាប់ឲ្យភ្នាក់ងារចូលមកចាប់ខ្លួនមាណពយកទៅ ។

អមាត្យបាលិតព្រមបណ្ដោយមាណពឲ្យទៅតាមភ្នាក់ងារ ព្រោះមិនអាចការពារបាន តែក្នុងចិត្តនឹកវិតក្កជំនួសមាណពយ៉ាងក្រៃលែង ។ ពួកប្រជាជនដែលឃើញហេតុការណ៍ដូច្នោះក៏នឹកថា ប្រហែលមាណពនេះ បង្កហេតុអ្វីមួយឡើង ដែលនាំឲ្យព្រះរាជាដាក់ទណ្ឌកម្មយ៉ាងធ្ងន់ ។

មាណពចូលមកថ្វាយបង្គំព្រះរាជាហើយអង្គុយស្ងៀម ព្រះរាជាទ្រង់ទតសម្លឹងដោយព្រះនេត្រដ៏តឹងព្រោះមានព្រះពិរោធយ៉ាងខ្លាំង ៖

“នែមាណព! ហេតុអ្វី ឯងចូលមកធ្វើចលាចលក្នុងពេលពិធីបូជាយញ្ញរបស់អញ? ទាំងមានកិរិយាទីងសំលៀកបំពាក់ទំនងដូចជាមិនមែនមនុស្សក្នុងក្រុងរបស់អញ, ឯងដឹងឬទេថាឯងមានទោសត្រូវប្រហារជីវិត!” ។

មាណពថ្វាយបង្គំព្រះរាជាម្ដងទៀត មិនសំដែងអាការតក់ស្លុតញាប់ញ័រក្នុងព្រះតម្រាស់របស់ព្រះរាជាបន្តិចបន្តួចសោះ ហើយទូលថា ៖

“សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះរាជតេជះតំកល់លើត្បូង! ព្រះអង្គធ្លាប់ដាក់ព្រះរាជអាជ្ញាដល់នរណា ៗ បានជានិច្ច, តែមុននឹងដាក់ព្រះរាជអាជ្ញានោះ ព្រះអង្គទ្រង់បើព្រះប្រាជ្ញាត្រិះរិះគប់គ្រាន់ហើយឬ? ជីវិតរបស់ព្រះអង្គមានតម្លៃរកអ្វីប្រៀបពុំបាន, ចំណែកជីវិតរបស់ខ្ញុំព្រះអង្គឥតតម្លៃសោះ, តែខ្ញុំព្រះអង្គស្រឡាញ់ជីវិតខ្ញុំព្រះអង្គណាស់, ប្រសិន

បើខ្ញុំព្រះអង្គមានជីវិតខ្ពង់ខ្ពស់ដូចព្រះអង្គហើយ ខ្ញុំព្រះអង្គក៏មិនប្រាថ្នានឹងមានជីវិតរស់នៅតទៅទៀតឡើយ" ។

ពាក្យតបដូច្នេះ ជាពាក្យតបដែលពោលប្រៀបធៀបដល់ការរស់នៅនៃព្រះរាជា ប្រហែល ៗ នឹងថារកតម្លៃគ្មាន ជាពាក្យដែលធ្វើឲ្យព្រះរាជាខឹងរឹតតែខ្លាំងឡើង ព្រះរាជាទើបទ្រង់សន្ទាប់ដោយព្រះសូរសៀងយ៉ាងខ្លាំង៖

"នែអាបុរសអប្បល័ក្ខណ៍! ឯងហ៊ានមើលងាយការរស់នៅនៃអញថាទាបថោកជាងការរស់នៅរបស់ឯង! ល្អហើយ បើឯងមិនអាចឲ្យអមាត្យទាំងឡាយយល់ឃើញពិត តាមដែលឯងថាបានទេ អញនឹងប្រហារជីវិតឯងពុំខាន" ។

"បពិត្រព្រះសម្មតិទេព! នរណាសោតនឹងអាចហ៊ានមើលងាយបន្ថុបបន្ថោកព្រះបរមតេជានុភាពព្រះអង្គបាន, ការរស់នៅរបស់ព្រះអង្គប្រសើរបំផុត, ឥឡូវនេះ ខ្ញុំព្រះអង្គបានសម្លឹងឃើញនូវភាពជាព្រះរាជារបស់ព្រះអង្គ ត្រូវសេចក្ដីល្ងង់ខ្លៅទំលាយហោល, សូមព្រះអង្គទ្រង់ជ្រាបចុះ" ។ មាណពព្យាយាមរកពាក្យក្រាបទូលជាស់ព្រះស្មារតីនៃព្រះរាជាសន្សំ ៗ បន្តិច ៗ ព្រោះដឹងថាបើធ្វើឲ្យព្រះរាជាខ្លាំង អ្នកធ្វើនឹងដល់នូវសេចក្ដីស្លាប់ ។

ព្រះរាជាបានទ្រង់ព្រះសណ្ដាប់ ក៏ទ្រង់ព្រះសម្រួលក្អាកក្អាយ ៖ "ហ៍ស ៗ ហ៍ នែបុរសកម្លោះ! ឯងសំគាល់ឃើញអញថាជាមនុស្សល្ងង់ខ្លៅទៀតហើយ; ដែលឯងថាយ៉ាងនេះ ព្រោះឯងខ្លាចអញដាក់អាជ្ញា

ជាទមូន់, តែណ្ហើយចុះមិនអ៊ីទេ អញនឹងបង្អង់ការពិឃាតឯងក្នុងថ្ងៃនេះសិនចុះ, តែទោះបីយ៉ាងណាក៏ដោយ បើឯងនិយាយមិនល្អក៏មិនរួចពីសេចក្តីស្លាប់ដែរ ដូច្នេះ ត្រូវតែឯងនិយាយមកចុះ" ។

មាណពសំគាល់ឃើញបានការខុះហើយ ទើបក្រាបទូលថា:

"បពិត្រព្រះករុណាថ្លៃវិសេស! សូមព្រះអង្គទ្រង់ជ្រាបថា ព្រះរាជាទាំងឡាយសុទ្ធតែជាអ្នកប្រាជ្ញ, វត្ថុអ្វីដែលព្រះអង្គមិនទាន់ជ្រាប ព្រះអង្គតែងទ្រង់ស្វែងរកដើម្បីនឹងឲ្យជ្រាប, វត្ថុអ្វីដែលព្រះអង្គទ្រង់ជ្រាបហើយតែងទ្រង់ជ្រាបច្បាស់ថា នេះខុស នេះត្រូវ, ខ្ញុំព្រះអង្គដឹងបានយ៉ាងនេះ, ព្រោះហេតុនេះ ទើបខ្ញុំព្រះអង្គមកមើលកម្មពិធីរបស់ព្រះអង្គដែលខុសប្លែកអំពីកម្មពិធីទាំងឡាយដែលខ្ញុំព្រះអង្គធ្លាប់បានឃើញមក, ឯកម្មពិធីបែបនេះ ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គមានព្រះទ័យប្រសើរខ្ពស់ជាងមនុស្សទាំងឡាយ ទ្រង់បានប្រកាសថាជាកម្មមានទោសដ៏ធ្ងន់របស់អ្នកប្រកប ព្រោះធ្វើជីវិតសត្វចំនួនច្រើនឲ្យស្លាប់ ហើយព្រះអង្គបានទ្រង់ហាមព្រះរាជាក្នុងអតីតសម័យមកហើយថា មិនឲ្យធ្វើកម្មពិធីបែបនេះទៀតទេ, កម្មពិធីយ៉ាងនេះគេក៏បានលើកលែង ឈប់ធ្វើទៅហើយ, ខ្ញុំព្រះអង្គពុំទាន់បានដឹងអំពីយោបល់ឈ្វេងយល់របស់ព្រះអង្គ តើទ្រង់ជ្រាបហេតុនិងផលនៃកម្មពិធីនេះ ពិតប្រាកដហើយឬទេ? ដោយខ្ញុំព្រះអង្គនឹកឃើញយ៉ាងនេះឯង សូមព្រះអង្គទ្រង់ព្រះរាជតាននូវព្រះកម្រាស់តបឲ្យខ្ញុំព្រះអង្គបានដឹងផង" ។

ពាក្យរបស់មាណពនេះជាពាក្យកំប៉ាំងគំនិត ដែលអាចផ្ដេះព្រះទ័យនៃព្រះពជាទីងផ្ដេះគំនិតប្រជាជន នៅក្នុងទីនោះឲ្យនឹកឃើញបំឡែកជាពន់ពេក ។ កាលព្រះពជាបានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់បែកព្រះប្រាជ្ញា ជ្រាបនូវវត្ថុផ្សេង ៗ នឹងរឿងរ៉ាវទាំងអស់ ជាហេតុនាំឲ្យទ្រង់រិះគិតឃើញ ដោយព្រះអង្គធ្លាប់សិក្សាមកយ៉ាងជ្រៅជ្រះដែរ តែមិនធ្លាប់បានទ្រង់ជ្រាបរឿងរ៉ាវរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ឡើយ ។

បរិយាកាសក្នុងខណៈនេះកំពុងស្ងប់ស្ងៀម អមាត្យបាលិតអង្គុយស្ដាប់ព្រះពជាដែលទ្រង់សន្ទនាទីងមាណពដោយរំភើបក្នុងចិត្ត ខំនឹករកផ្លូវនឹងជួយមាណពអស់កាលដ៏យូរ ហើយក៏ចាប់ក្ដុកនឹកឃើញភ្លាមថា "ព្រះពជាអង្គនេះធ្លាប់ស្ដេចទៅគាល់ព្រះធម្មបតីពជាម្ដងមកហើយ ឯខ្ញុំអញក៏ធ្លាប់បានគាល់ព្រះអង្គមកយ៉ាងជិតស្និទ្ធ អំពីពេលនោះដែរ រាប់ជាវេលាយូរមកហើយ ស្ទើរតែភ្លេចអស់ទៅ ទើបតែនឹងនឹកឃើញបានក្នុងពេលនេះឯង លុះឃើញហេតុការណ៍ក្នុងឋានៈដែលព្រះពជាទ្រង់មានព្រះទ័យជឿទៅតាមពាក្យមាណពហើយ ទោះបីយ៉ាងណាក៏ដោយ ក៏ត្រូវតែចូលទៅគាល់ក្នុងពេលនេះកុំខាន ទាន់មាណពកំពុងមានឱកាសនៅក្នុងទីនោះនៅឡើយ, បើមិនចូលទៅជួយមាណពក្នុងពេលនេះទេ មាណពក៏មិនអាចផុតភ័យបាន ហើយអាចមានផ្លូវដែលមាណពនឹងសូមឲ្យព្រះពជាលើកលែងធ្វើពិធីបូជាយញ្ញបញ្ចប់បាន" កាលគិតយ៉ាងនេះហើយ ទើបរ៉ារចូលទៅហម្បចំពោះព្រះភក្ត្រព្រះពជាជិតមាណព ។

ព្រះរាជាកំពុងតែទ្រង់ទឹកភ្លៀង ក្នុងពេលដែលទ្រង់ទតឃើញអមាត្យបាលិត, ឯអមាត្យបាលិតក៏ក្រាបបង្គំទូលឡើង:

"សូមព្រះរាជតេជះដ៏កល់លើត្បូង! ខ្ញុំព្រះអង្គជាទូតនឹងជាអមាត្យធំនៃព្រះធម្មបតីរាជា, សូមចូលគាល់, សូមទ្រង់ប្រោសព្រះរាជទានអភ័យទោសចំពោះការណ៍ដែលខ្ញុំព្រះអង្គចូលមកគាល់ខុសកាលវេលានេះ" ។

ព្រះរាជាបែរព្រះភ័ក្ត្រដោយចំឡែកក្នុងព្រះទ័យថា "យី! មានទូតបរទេសចូលមកគាល់ផង" ហើយទ្រង់ញាក់ព្រះភ័ក្ត្រទទួល, ទ្រង់ទតស្ងួនមួយស្របក់, ទើបការស្គាល់ក៏ប្រាកដឡើងបាន ។

"ឱ! លោកជាអមាត្យបាលិតឬ? ប្រហែលមានការរាជការទាក់ទងនឹងខ្ញុំជាប្រញាប់ ទើបព្រះរាជាទ្រង់បញ្ជូនលោកមកទេដឹង?

"មិនមែនទេព្រះករុណា! ដែលខ្ញុំព្រះអង្គមកនេះ មិនមានការរាជការជាប់ទាក់ទងនឹងព្រះអង្គទេ, ខ្ញុំព្រះអង្គមកនេះដោយបំណងនៃមាណពម្នាក់នេះ" ថាហើយក៏ចង្អុលទៅមាណព" ។

"ឱ! មាណពនេះឬ! មាណពនេះហ៊ានមើលងាយយើងខ្លាំងពេក វាមានទោសគ្រាន់នេះធ្ងន់ណាស់ ត្រូវដល់ប្រហារជីវិត តែយើងទុកឱកាសឲ្យ បើមិនអាចលុបលាងពាក្យមើលងាយបានទេ យើងនឹងឲ្យគេប្រហារជីវិតបង់" រួចទ្រង់បែរទៅខាងមាណព សួរមាណពថា:

"មើលឯងថាទៅ!" ។

មាណពទូលថា:

«ក្រាបទូល ! ការបូជាយ័ញ្ញដោយសត្វរស់ ដើម្បីព្រះរាជធីតា ដែលកំពុងប្រឈួននឹងដើម្បីឲ្យរោគរប័ក្យវិនាសទៅនេះ ពុំសមហេតុផលទេ ព្រះករុណា !» ។

«ពុំសមហេតុផលដូចម្ដេច» ព្រះរាជាត្រាស់សួរផ្ទួនថា «ឯងមានអ៊ីមកអាងឲ្យល្អវិសេសជាងនេះទៅទៀត ចូរថាមកចុះ !» ។

«បពិត្រព្រះករុណាថ្លៃវិសេស ! វត្ថុគ្រប់យ៉ាងក្នុងលោករមែងកើតមកតែអំពីហេតុ, កាលវត្ថុនោះនឹងរលត់ទៅវិញ ក៏ត្រូវរលត់ត្រង់ដើមហេតុជាមុន ព្រះអង្គ !» ។

«ខ្ញុំចង់ដឹងណាស់ ហេតុដូចម្ដេច ព្រះរាជធីតារបស់យើងប្រឈួនពេលនេះ ទាំងរោគរប័ក្យក៏កើតមាន? តើឯងនឹងកំណត់ត្រង់ណាថាជាហេតុផលដូច្នេះ? សូម្បីនរណា ៗ ក៏មិនអាចដឹងបាន, មនុស្សក្នុងនគរយើងនេះដែលជាពេទ្យពូកែ ៗ ក៏ពុំគប់ណោះនឹងកែខបាន យើងទើបយល់ឃើញថាត្រូវតែធ្វើទៅតាមប្រពៃណីដើមដែលធ្លាប់ធ្វើមក ក្នុងពេលដែលមានសេចក្ដីវិបត្តិកើតឡើង ដើម្បីនឹងកែខនូវហេតុអាក្រក់នេះឲ្យស្ងប់រម្ងាប់ បានជាធ្វើពិធីនេះឡើងនៅគ្រាចុងបំផុត» ។

«ខ្ញុំព្រះអង្គនឹងជាអ្នកអង់អាចបាន ក្នុងពេលដែលគ្មាននរណាអាច, ហើយខ្ញុំព្រះអង្គសូមទទួលយកអាសា ដោយវាចាសត្យរបស់ខ្ញុំព្រះអង្គ, សូមព្រះអង្គទ្រង់ប្រោសព្រះរាជទានឱកាសឲ្យខ្ញុំព្រះអង្គផង» ។

ដោយសេចក្ដីទឹកសង្ឃឹមក្នុងចិត្តជាមុន មាណពទើបក្រាបបង្គំទូលថា «បើព្រះអង្គទ្រង់បញ្ឈប់នូវពិធីយ័ញ្ញនេះ, ខ្ញុំព្រះអង្គនឹងធ្វើឲ្យរោគរប័ក្យ

នឹងព្រះអង្គម្ចាស់ក្សត្រីបាត់ប្រឈ្មួនក្នុងវេលា ៧ រាត្រីខាងមុខ, បើមិនដូចពាក្យដែលខ្ញុំព្រះអង្គក្រាបបង្គំទូលទេ ខ្ញុំព្រះអង្គសូមថ្វាយជីវិត" ។

"ពិតប្រាកដឬ, ឲ្យតែពិតប្រាកដចុះ មាណព!" ព្រះរាជាទ្រង់រារែកព្រះទ័យ ត្រាស់ផ្ទួនៗ នឹងមាណព តែព្រះសូរសៀងអន់ខ្សោយតិចៗ ។

"ខ្ញុំព្រះអង្គសូមរ៉ាប់រង ព្រះករុណា!" អមាត្យបាលិតជរណ្តើមក្រាបទូលព្រះរាជា រួចក្រាបទូលម្តងទៀតថា "សូមព្រះអង្គទ្រង់ព្រះរាជបញ្ជាឲ្យបញ្ឈប់នូវពិធីបូជាយញ្ញនេះចេញទៅ" ។

ព្រះរាជាទ្រង់រារែកព្រះទ័យមួយស្របក់ធំ ទើបទ្រង់ព្រះតំរិះឃើញថា "សូម្បីមាណពមិនអាចធ្វើឲ្យសម្រេចបានតាមពាក្យដែលបានទូលមកហើយ ក៏ទ្រង់នឹងផ្តើមធ្វើពិធីនេះឡើងវិញក្នុងកាលជាខាងក្រោយ" ហើយទ្រង់ព្រះតម្រិះតទៅទៀតថា "អមាត្យបាលិតជាមនុស្សរបស់ព្រះធម្មបតីកជាហានទទួលអះអាងដូច្នេះ កាលបើមាណពធ្វើមិនបានសម្រេចតាមពាក្យដែលទូលនោះ ព្រះធម្មបតីកជាក៏នឹងត្រូវអាប់ព្រះភក្ត្រ នឹងសាបសូន្យព្រះកិត្តិយសនៃព្រះអង្គជាអនេកប្បការ" ។

ដោយវិស័យក្សត្រិយ៍ ទើបទ្រង់ផ្អឹបព្រះរាជអំណាចទុក ។

"បានព្រួថា មាណពម្នាក់នេះជាទីត្រូវព្រះទ័យនៃព្រះធម្មបតីកជា, យើងនឹងល្បងមើល" ព្រះរាជាទ្រង់ព្រះចិន្តាដូច្នេះហើយក៏ទ្រង់ព្រះបញ្ញាឲ្យបញ្ឈប់នូវការធ្វើពិធីបូជាយញ្ញនោះមួយគ្រាសិន ។

(មានត)

# រឿងសាមកុក

## ភាគទី ២៨

ឧកញ៉ាវិបុលរាជសេនា ង្វ-ហុង ប្រែរៀបរៀង

(តមក)

---

**រឿងសាមកុកទុកជាយុទ្ធសាស្ត្រ**
**អ្នកផងវៃឆ្លាសបើបានអាន**
**នឹងចេះឧបាយកលបំណាន**
**ទាំងមានសន្ដានស្នេហាជាតិ ។**

បូច្ចូក៏ស្រែកគំហកឲ្យស្ទួយ៉ិនថា ដែលគួនអ៊ូទៅនេះព្រោះមានចិត្តកតញ្ញូនឹងឡេវពីជានាយចៅហ្វាយ ប្រការ ១ យើងក៏បានទទួលពាក្យបេជ្ញាឲ្យគេហើយ គេក៏បានជូនសំបុត្រតះកលាយើងតាមគួរសម ហេតុម្ដេចមកថា គេលួចរត់ដូច្នេះ អ្នកទាំងឡាយចូរមើលបែបយ៉ាងគួនអ៊ូចុះ ត្រូវឲ្យមានចិត្តស្រឡាញ់នាយចៅហ្វាយដូចគេនេះ ។ ឆៀយុកឆ្លើយថា មហាឧបរាជចិញ្ចឹមរក្សាគួនអ៊ូក៏ដល់ខ្នាតហើយ គួនអ៊ូក៏នៅមើលងាយមិនបានគោរពក្រាបលា ហ៊ានសរសេរសំបុត្រមកឲ្យដូច្នេះមិនគួរសោះ បើនឹងលែងគួនអ៊ូឲ្យទៅដល់អ៊ួនសៀវ ចូលនៅនឹងអ៊ួនសៀវកាលណាក៏មានចិត្តកំរើកឡើងទៀត ឧបមាដូចជាលែងខ្លាឲ្យមានកំឡាំង សុំឲ្យលោកកៃណ្ហទាហានលើកតាមទៅចាប់គួនអ៊ូមកសម្លាប់ចេញ តទៅមុខទើបមិនមានចំរូងចំរះ ។

ចូចួតបថា "យើងបានទទួលបេជ្ជានឹងគេទុកមកហើយ បើនឹងឲ្យទៅតាមនាំយកខ្លួនមកវិញ ក៏នឹងខូចអសារពាក្យសំដីដែលនិយាយ, ប្រការ ១ ចិត្តគួនអ៊ូជាមនុស្សស្មោះសត្យស្មុចរិតពិតត្រង់ណាស់ អំណើះទៅមុខគង់នឹងមិនធ្វើអន្តរាយដល់យើងជាប្រាកដ" ហើយចូចួតនិយាយនឹងទៀវលៀវថា យើងទំនុកបំរុងគួនអ៊ូដល់ខាតប៉ុណ្ណោះហើយ គួនអ៊ូក៏មិនឃើញដល់យសបណ្តាស័ក្តិនឹងទ្រព្យសម្បត្តិ តាំងចិត្តស្មោះសេចក្តីសត្យពិតត្រង់នឹងរកនរណាស្មើគ្មាន យើងក៏មានចិត្តកោតខ្លាចគួនអ៊ូ ហេតុនេះអ្នកចូរស្រូតទៅតាមប្រាប់គួនអ៊ូចុះ ថាយើងស្រឡាញ់សេចក្តីសត្យស្មុចរិតចិត្តគួនអ៊ូដែលត្រង់ល្អដូច្នេះ យើងក៏សុំជូនដំណើរទៅដល់ពាក់កណ្តាលផ្លូវ ហើយនឹងឲ្យរង្វាន់ជាគ្រឿងសម្លៀកបំពាក់មាសប្រាក់ ដល់គួនអ៊ូជាគុណថែមទៀត យូរទៅ មុខជាគួនអ៊ូនឹងនឹកគុណយើងមិនខានទេ ។

ទៀវលៀវក៏លាចូចួតឡើងសេះស្រូតបញ្ជាប់តាមទៅ ចូចួតក៏រៀបចាត់ចែងទាហានមានយកទាំងមាសប្រាក់ទ្រព្យរបស់ ឡើងសេះនាំទាហានប្រមាណ ៣០ នាក់មិនបានកាន់គ្រឿងអាវុធ ស្រូតទៅតាមជាក្រោយ ។

ឯគួនអ៊ូនោះ លុះបានឮសំឡេងសេះស្រូតហៅពីក្រោយថាឲ្យឈប់សិន គួនអ៊ូឮហើយក៏និយាយឲ្យទាហានរបស់ខ្លួនឃុំនាំរទេះទៅមុន ខ្លួនគួនអ៊ូនៅការពារពីខាងក្រោយ ព្រោះមានទាហានចូចួតស្រែកហៅឲ្យឈប់មិនដឹងជាជាឬកាច ហើយគួនអ៊ូក៏ញាក់សេះឈប់ក្រឡេកទៅឃើញទៀវលៀវ គួនអ៊ូក៏សួរទៅទៀវលៀវថា អ្នកតាមមកនឹងចាប់យើងឬ? ទៀវលៀវ

គបថា មិនមែនទេ ដ្បិតមហាឧបាសិកាប្រាប់ថា អ្នកនឹងទៅផ្លូវដាច់ស្រយាលឆ្ងាយណាស់ លោកមានចិត្តអាណិតអ្នកទើបប្រើខ្ញុំឲ្យស្រែកតាមមកឃាត់ឲ្យអ្នកឈប់សិន មហាឧបាសិកានឹងតាមមកជូនដំណើរផង គួនអ៊ុំព្យហើយក៏មានសេចក្ដីសង្ស័យ ថយរទេះមកក្រោយបញ្ឈប់នៅលើស្ពានសិន ក្រឡេកទៅឃើញបួចូរលើកអាហារឯកប្រហែល ៣០ នាក់ លុះបួចូរទៅដិតទីដល់ ក៏ឲ្យអាហារជំរៀបគ្នាឈរជាប៉ែកធ្វើងស្ដាំ គួនអ៊ុំព្យឃើញអាហារបួចូគ្មានកាន់គ្រឿងអាវុធនៅដៃ ក៏អស់សេចក្ដីសង្ស័យ ៗ

បួចូក៏សួរគួនអ៊ុំព្យថា ហេតុម្ដេចបានជាអ្នកឯងចេញមកមិនឲ្យយើងដឹង? គួនអ៊ុំព្យក៏បន្ទន់ខ្លួនគំនាប់ជំរាបថា ពីដើមឡើយខ្ញុំបាទក៏ជំរាបមហា-ឧបាសិកាទុកដោយវាចា សូមប្រោស ៣ ខ ប្រសាសន៍ក៏បានព្រមល្មមតាមបដិញ្ញាណ លុះខ្ញុំបាទបានដឹងដំណឹងឡើតហើយបានចូលទៅជំរាបលាប្រកាសន៍ដល់ ២ - ៣ ដង ក៏មិនបានជួបប្រាជ្ញាសោះ ព្រោះអ្នកចាំទ្វារឃាត់ហាម ហើយមានទាំងបំរាមបិទទុកនៅមាត់ទ្វារទៀតថា ប្រសាសន៍ហាមមិនឲ្យចូល ខ្ញុំបាទក៏មានសេចក្ដីវិតក្កជាទុក្ខ បង្អៀតចិត្តគិតទឹកដល់ឡើតពីជាទីបំផុត បានជាសរសេរសំបុត្រគំនាប់លាប្រគល់ឲ្យអ្នកចាំទ្វារទុកជូនប្រសាសន៍ ឯរបស់ទ្រព្យជាគ្រឿងមាសប្រាក់ដែលប្រសាសន៍បានឲ្យមានខ្ញុំបាទ ហើយនឹងត្រាសម្រាប់ផាររនោះ ខ្ញុំបាទក៏បានប្រគល់ឲ្យស្រីបំរើទុកជូនប្រសាសន៍ទាំងអស់ ដែលខ្ញុំបាទរំដោះស្រែកមកនេះប្រាជ្ញានឹងឲ្យបានឃើញមុខឡើតដែលនិកសគ្នាជាយូរហើយនោះ ហេតុ

នេះសូមប្រសាសន៍មានសេចក្ដីករុណាគិតដល់ពាក្យប្ដេជ្ញាពីបឋម បើក
ឲ្យខ្ញុំបាទទៅដោយស្រួលចុះ ។

ចូចូថា "យើងធ្វើការសព្វថ្ងៃនេះ ដោយតាំងចិត្តប្រាថ្នារកអ្នកណា
ដែលកាន់ពាក្យសត្យសុចរិតត្រង់ ឲ្យដូចខ្លួនអ្នកមានចិត្តស្រឡាញ់ទៀតពី
នោះណាស់ដែរ តែកម្រប្រទះ ទើបមកឃើញអ្នកល្អត្រង់ណាស់ យើងក៏
មានចិត្តស្មោះសរស្រឡាញ់, ដែលយើងបានទទួលពាក្យប្ដេជ្ញាទុកនឹងអ្នក
នោះមិញ យើងក៏រក្សាពាក្យនោះឲ្យគង់នៅមិនត្រូវឲ្យប្រែប្រួលទៅជា
ពាក្យ ២ បាន អ្នកនឹងទៅហើយយើងក៏មិនត្រូវឃាត់ទាំងឲ្យឈប់ខានទេ
តែយើងក្រែងផ្លូវដែលទៅនោះឆ្ងាយស្រយាល ខ្វះស្បៀងអាហារ
មិនគ្រប់គ្រាន់បានជាយើងតាមមកឲ្យទាន់នឹងជូនដំណើរ ហើយដើម្បី
នឹងយករបស់មកធ្វើជាស្បៀងថែមទៀត" ចូចូនិយាយហើយក៏ឲ្យ
ទាហានយកមាសមួយសំពៀតដាក់លើថាសមួយ ឲ្យទៅគួនអ៊ូ ៗ ក៏មិន
ព្រមទទួលយកមាសនោះ ដំកបតបទៅចូចូវិញថា ប្រាក់បៀវត្សរ៍ដែលខ្ញុំ
បាទបានទទួលព្រះរាជទាននោះ ក៏នៅមានល្មមប្រើចាយគ្រប់គ្រាន់
ហើយ សូមមហាឧបរាជកុំព្រួយរវល់ឡើយដល់ខ្ញុំបាទចុះ សូមទុកមាស
នោះនឹងចែកឲ្យទាហានដែលបានធ្វើការនឿយហត់តទៅ ។ ចូចូក៏ថា
កាលអ្នកធ្វើការនឹងយើង អ្នកក៏មានសេចក្ដីតប់ប្រសើរច្រើនណាស់
ដែលយើងឲ្យមាស ១ ថាសនេះ ក៏មិនទាន់ជួនល្មមនឹងគុណបំណាច់អ្នក
ទេ ហេតុម្ដេចបានជាអ្នកមិនទទួល? ។

គួនអ៊ូតបថា ខ្ញុំបាទនៅដេកគោននឹងមហាឧបរាជ ក៏មិនបានធ្វើ

ការគាប់ប្រសើរណាស់ណាប៉ុន្មានទេ គ្រាន់តែបានយកអាសាចេញទៅធ្វើការសង្គ្រាមម្ដងពីរដងប៉ុណ្ណោះ មិនគួរនឹងរាប់ថាគាប់ប្រសើរប៉ុន្មាន ៗ ចូចូបានឮគួនអ៊ូថាដូច្នោះក៏ឆ្លើយថា "ខ្លួនអ្នកជាទាហានមានថ្វីដៃខ្លាំងពូកែ ព្រមទាំងសេចក្ដីសត្យកតញ្ញូនឹងគេនរណាស្មើមិនមាន ខ្លួនយើងជាមនុស្សវាសនាទន់ បុណ្យគ្មាន ទើបមិនបានខ្លួនអ្នកទុកឲ្យដូចសេចក្ដីប្រាថ្នា មាសនេះបើអ្នកមិនត្រូវការក៏ពាំហើទៅចុះ ចូរទទួលយកតែអាវលាយមាសនេះទុកជាទីរលឹកកប់អាន បំណាច់យើងជូនដំណើរមកកុំឲ្យបង់ពេលា" ហើយចូចូក៏ឲ្យទាហានយកអាវនោះហុចទៅឲ្យគួនអ៊ូ ៗ លុះនឹងចុះពីលើសេះទទួលយកអាវពីទាហានក៏មិនបានទុកចិត្តចូចូទេ ទើបបង្អោនខ្លួនចុះហើយក៏ហុចចុងដាវទៅទទួលយកអាវ មកពាក់គ្របលើខ្លួនហើយក៏ថា "ព្រះតេជព្រះគុណមហាឧបរាជ ដែលមានលើខ្លួនខ្ញុំបាទពីមុនមកក៏ច្រើនលើសលប់នឹងប្រៀបប្រាណពុំអស់ ថែមវេលានេះលោកក៏បានមកតាមជូនដំណើរហើយឲ្យទាំងអាវថែមទៀត ប្រសិនបើជីវិតខ្ញុំបាទរស់នៅ ខ្ញុំបាទក៏ត្រូវចាំគិតផ្ចៀតមកតបស្នងសងគុណមហាឧបរាជមិនភ្លេចឡើយ" គួនអ៊ូគំនាប់ហើយក៏លាចូចូបរសេះចេញទៅ ៗ

ខៅធូជំរាបចូចូថា គួនអ៊ូនេះព្រហើនមើលងាយមហាឧបរាជណាស់ លោកបានឲ្យអាវទៅហើយក៏ហុចចុងដាវមកទទួល ធ្វើដូច្នេះ ជាទីមាក់ងាយហួសពេក ហេតុម្ដេចបានជាលោកមិនយកទោស? ៗ ចូចូថា "ដែលនឹងប្រកាន់ទោសគួនអ៊ូនោះមិនបានទេ ព្រោះគេតែម្នាក់ឯង យើងគ្នាច្រើនជាងគេ ៗ មិនទុកចិត្តយើង ៗ បានចេញពាក្យថា ឲ្យគេទៅហើយកុំយក

ទោសគេឡើយ" ហើយចូឆូក៏នាំទាហានទាំងពួងត្រឡប់ទៅក្រុងហ្វូគោវិញ ចេះតែសរសើរគួនអ៊ូថា មានសេចក្ដីសត្យពិតត្រង់មិនដាច់ពីមាត់ ។

ឯគួនអ៊ូទៅចម្ងាយផ្លូវប្រហែល ៣០០ សិន (១២ គ.ម.) មិនឃើញរថបងថៃសោះ គួនអ៊ូក៏ភ័យស្លុតចិត្តក្រឡេកមើលទៅខាងណាក៏មិនឃើញ ទទួលឮសំឡេងស្រែកមកពីលើភ្នំថា គួនអ៊ូឈប់សិន ! ។ គួនអ៊ូក្រឡេកទៅឃើញទាហានកំឡោះតូចជួតក្បាលលឿង ពាក់អាវលាយមាស ជិះសេះកាន់ទួនយកក្បាលមនុស្សចងកសេះ នាំបក្សពួកប្រហែល ១០០ ប្លាយ ចុះមកទទឹមមុខគួនអ៊ូ សួរថា អ្នកឯងឈ្មោះអ្វី ។ មកពីណា ? ឈ្មោះនោះចុះពីលើសេះបោះទួនចេញ ហើយលុតជង្គង់គំនាប់គួនអ៊ូថា "ខ្ញុំបាទឈ្មោះលៀវហ្វូនៅស្រុកសុងយ៉ុង កាលគ្រាបោរជួតក្បាលលឿង ខ្ញុំបាទក៏បែកមកនៅក្នុងភ្នំនេះ ប្រមូលទាហានបានប្រហែល ៤០០ ប្លាយ រាយដណ្ដើមយកស្បៀងចំណីអាហារគេបរិភោគចិញ្ចឹមជីវិត តៅអ៊ួននាយបោរជាសំឡាញ់ខ្ញុំបាទ លើកពួកម៉ាកចុះមករាយដណ្ដើមយកបានស្រី ២ នាក់ ខ្ញុំបាទសាកសួរមនុស្សដែលធ្វើដំណើរមកជាមួយ គេប្រាប់ថា ភរិយាឡៅពីមកជាមួយនឹងលោក ខ្ញុំបាទថានឹងយកជូនឲ្យលោក, តៅអ៊ួនមិនព្រម ខ្ញុំបាទក៏សម្លាប់តៅអ៊ួនចេញ កាត់ក្បាលនាំយកមកជូនលោក, ភរិយាឡៅពីទាំង ២ នោះ ខ្ញុំបាទឲ្យទាហានយុំនាំមកជាក្រោយ." ទទួលពួកបោរនាំរថមកដល់ ។

គួនអ៊ូក៏ចុះពីលើសេះទៅគំនាប់បងថៃទាំង ២ ហើយថាដែលអ្នកជាបងមានសេចក្ដីភ័យខ្លាច នោះទោសខ្ញុំបាទខុសធ្ងន់ណាស់ ។ បងថៃ

ទាំង ២ ក៏និយាយថា កាលចោរវាំនាំបងទៅលើភ្នំនោះ បើកុំតែលៀវហួមកជួយ បងក៏នឹងមានសេចក្តីអន្តរាយ ។ គួនអ៊ូក៏សួរទៅទាហានដែលធ្វើដំណើរជាមួយថា កាលចោរនាំទៅនោះ ហេតុម្តេចបានជាលៀវហួមកជួយ? ។ ពួកទាហានឆ្លើយថា កាលខ្ញុំបាទឃុំនាំរថទៅនោះ ឃើញតៅអ៊ួនឃុំនាំពួកចោរចុះមកនាំយករថឡើងទៅលើភ្នំ ហើយប្រាប់លៀវហួថា បានស្រីមក ២ នាក់ នឹងចែកឲ្យជាភរិយាលៀវហួម្នាក់ លៀវហួសួរខ្ញុំថា ស្រី ២ នាក់នេះជាភរិយាអ្នកឯណា ? ខ្ញុំបាទប្រាប់ថា ជាភរិយាទៀតតី គួនអ៊ូជាប្អូនឃុំនាំមកនឹងទៅរកទៀតតីឯស្រុកគីជីវ លៀវហួក៏និយាយនឹងតៅអ៊ួនថា ឲ្យនាំអ្នកស្រីមកជូនលោកវិញ តៅអ៊ួនមិនព្រមធ្វើតាម លៀវហួខឹងក៏សម្លាប់តៅអ៊ួនស្លាប់ ហើយឲ្យពួកម៉ាកឃុំនាំរថចុះមកនេះ ។

គួនអ៊ូបានស្តាប់ហើយក៏មានចិត្តត្រេកអរណាស់ ក៏នាប់លៀវហួហើយថា ដែលអ្នកបានធ្វើគុណទុកដល់យើងគ្រានេះ យើងមានសេចក្តីត្រេកអរពន់ប្រមាណណាស់ បើជីវិតយើងមិនស្លាប់ យើងបានជួបប្រទះនឹងអ្នកវេលាណា យើងនឹងជួយឧបត្ថម្ភតបស្នងសងគុណអ្នកវិញ ។

លៀវហួនិយាយនឹងគួនអ៊ូថា ដែលលោកនឹងទៅឯមុខនោះជាផ្លូវឆ្ងាយដាច់ស្រយាលណាស់ ខ្ញុំបាទសុំលើកទាហានតាមជូនលោកទៅត្រាតែផុតដែនស្រុកហ៊ូតោ ។ គួនអ៊ូឮហើយក៏គិតតែក្នុងចិត្តថា "លៀវហួនេះជាចោរជួតក្បាលលឿង បើយើងឲ្យវាឃុំនាំបក្សពួកជូនយើងទៅ អ្នកស្រុកតាមផ្លូវនឹងតិះដៀលនិន្ទាថា យើងគប់នឹងពួកចោរ" គួនអ៊ូក៏និយាយ

នឹងលៀវហួថា ដែលអ្នកនឹងជូនយើងទៅ យើងក៏អរគុណណាស់ហើយ កុំឲ្យអ្នកព្រួយ នឹងជូនយើងទៅឲ្យលំបាកឡើយ ។ លៀវហួក៏យកមាសទៅឲ្យគួនអ៊ូ ៗ មិនព្រមទទួល តបថា របស់នេះអ្នកយកទុកចុះ ។

លៀវហួក៏លាគួនអ៊ូនាំពួកចោរត្រឡប់ទៅទីលំនៅលើភ្នំនោះវិញ ។ គួនអ៊ូក៏អធិប្បាយឲ្យបងថ្លៃទាំង ២ ស្តាប់ អំពីបុច្ឆតាមមកជូនដំណើរនោះ ហើយក៏បន្តឲ្យបររថទៅតាមផ្លូវ លុះពេលរសៀលល្ងាចឃើញផ្ទះនៅតំបន់ ១ គួនអ៊ូក៏នាំបងថ្លៃចូលទៅសុំសំណាក់ ។ ឈ្មោះហោហួជាម្ចាស់ផ្ទះនោះអាយុចាស់ជរា សក់នឹងពុកមាត់ពុកចង្កាសរទាំងអស់ លុះឃើញគួនអ៊ូទៅដល់ក៏ចេញទៅទទួលដោយសប្បុរសហើយសួរថា អ្នកឈ្មោះអ្វីមកពីណាទៅណា ? ។ គួនអ៊ូប្រាប់ថា ខ្ញុំឈ្មោះគួនអ៊ូ ជាប្អូនឡៅពី ខ្ញុំនឹងទៅរកបងឯស្រុកគីជីវ ។

ហោហួសួរថា ខ្លួនអ្នកនេះហើយឬ? ដែលសម្លាប់ង៉ាន់លៀង ប៊ុនធីវ តាហោតានឯកអ៊ូនសៀវ? ។ គួនអ៊ូឆ្លើយថា បាទខ្ញុំនេះឯង ។ ហោហួបានស្តាប់ ក៏មានចិត្តត្រេកអរណាស់ ទើបថា អញ្ជើញអ្នកចូលទៅក្នុងផ្ទះចុះ ។ គួនអ៊ូថា បងថ្លៃខ្ញុំទាំង ២ នៅឯក្រៅ ។ ហោហួក៏ហៅបុត្រនឹងភរិយាឲ្យចុះទៅទទួលគួរសម នាំភរិយាឡៅពីឡើងមកហើយក៏នាំចូលទៅខាងល្វែងក្នុង ហោហួក៏អញ្ជើញគួនអ៊ូនឹងនាងទាំង ២ ឲ្យបរិភោគអាហារជាមួយគ្នា ។ គួនអ៊ូថា ខ្ញុំនឹងអង្គុយទន្ទឹមនឹងបងថ្លៃនោះមិនគួរ ។ ហោហួក៏ឲ្យអញ្ជើញនាងទាំង ២ ចូលទៅបរិភោគខាងក្នុង រៀបឲ្យគួនអ៊ូនឹងហោហួនៅបរិភោគខាងក្រៅ ។

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតំណាល

## លោកសមិន មូត្យ៉ូនជឹមៈតែង

## លោករ៉ាយ-ប៊ុក ក្រមការ ដើមខ្សែប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ២១

មានកាលមួយថ្ងៃ រូបទេពនិម្មិតទី ២១ បានឃើញព្រះបាទភោជៈស្តេចចូលទៅជិតបល្ល័ង្កទិព្វ ក៏ក្រាបបង្គំទូលថា: បពិត្រមហារាជភោជៈ សូមទ្រង់ព្រះសណ្តាប់ នូវព្រះមហាសប្បុរិសធម៌នៃព្រះបាទវិក្រមាទិត្យ ដែលទ្រង់មានព្រះរាជសមត្ថភាព អាចគង់នៅលើព្រះបល្ល័ង្កទិព្វនេះបាន ដូចតទៅនេះ ៖

"ក្នុងថ្ងៃមួយ ដើម្បីនឹងទ្រង់ទតនូវវត្ថុជាអច្ឆរិយភាពឯប្រទេសនានា ព្រះបាទវិក្រមាទិត្យទ្រង់ព្រះសុពណ៌បាទរ័ត្ន ទ្រង់ស្តេចហោះធ្វើព្រះរាជទស្សនាការតាមស្រុកនិគមជនបទនៅក្នុងព្រះរាជអាណាចក្រ ៗ ទ្រង់ស្តេចយាងទៅដល់នគរមួយ ទ្រង់ក៏ឈប់ប្រថាប់នៅទីនោះ ត្រង់ខាងមុខបូជនីយដ្ឋានមួយ ៗ ក្នុងពេលនោះ ទ្រង់កំពុងធ្វើអញ្ជលីកម្ម ប្រទក្សិណជុំវិញបូជនីយដ្ឋាននោះ ក៏ស្រាប់តែមានជនបរទេសម្នាក់ទៅដល់ទីនោះដែរ ៗ ជនបរទេសបានឃើញព្រះបាទវិក្រមាទិត្យ ក៏ក្រាបបង្គំទូលថា 'បពិត្រព្រះមហាសប្បុរស, ទូលព្រះបង្គំបានយល់ឃើញថាទ្រង់ជាមហារាជប្រកបដោយព្រះគុណសម្បត្តិជាសុក្រិតភាព; បានជាទូល

ព្រះបន្ទូលថា ទ្រង់ប្រាកដជាពូជស្តេច ។ បើព្រះមហាក្សត្រអង្គណា ដែលមានព្រះរាជតម្រិះដល់ព្រះរាជអាណាចក្ររបស់ព្រះអង្គ ហើយទ្រង់ស្តេចយាងក្រសាលនៅប្រទេសដទៃ ព្រះរាជអាណាចក្រនៃព្រះមហា-ក្សត្រនោះនឹងមិនបានឋិតថេរថេរកាលទៅអនាគតឡើយ ។ ព្រះរាជ-ករណីយកិច្ចគ្រប់យ៉ាងសម្រាប់ព្រះមហាក្សត្រក៏ទ្រង់លះបង់ ទ្រង់គ្រាន់តែមានព្រះរាជតម្រិះទៅកាន់សម្បូណ៌ភាព ឬ ហាយនភាព នៃព្រះអាណាចក្រប៉ុណ្ណោះ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះសណ្ដាប់នូវពាក្យពោលរបស់ជនបរទេសនោះ ទ្រង់ក៏មានព្រះរាជឧត្តរតបវិញថា: " ឱ បុរស ! បើគ្មានច្បាប់ទេ, ព្រះមហាក្សត្រអង្គណា បើទុកជាទ្រង់ព្រះតម្រិះទៅកាន់សម្បូណ៌ភាព ឬ ហាយនភាពនៃព្រះរាជអាណាចក្រយ៉ាងណាក៏ដោយ, ព្រះរាជអាណាចក្រនៃព្រះហាក្សត្រនោះក៏មិនអាចឋិតថេរថេរកាលបានឡើយ ។ មួយទៀត បើព្រះមហាក្សត្រអង្គណាមិនព្រមប្រតិបត្តិតាមបទបញ្ញត្តិច្បាប់ទេ បើទុកជាទ្រង់មានព្រះតម្រិះទៅកាន់សម្បូណ៌ភាព ឬ ហាយនភាពនៃរដ្ឋព្រះអង្គក៏ដោយ ក៏ព្រះរាជតេជានុភាពនៃព្រះមហា-ក្សត្រអង្គនោះ ឬ ព្រះរាជអាណាចក្ររបស់ព្រះអង្គ នឹងមិនអាចឋិតថេរបាន ។ តាមសភាពផ្ទុយទៅវិញ, បើព្រះមហាក្សត្រអង្គណា បានប្រតិបត្តិតាមច្បាប់ដោយក្រិដ្ឋ, ទ្រង់មិនចាំបាច់ព្រះតម្រិះពីសម្បូណ៌ភាព ឬ ហាយនភាពនៃអាណាខេត្រក្នុងប្រទេសទេ ព្រះរាជអាណាចក្រនៃព្រះមហាក្សត្រនោះនឹងអាចឋិតថេរទៅបានដោយពលភាពនៃច្បាប់ ។ ព្រោះហេតុនេះ . ដើម្បីនឹងធ្វើព្រះរាជអាណាចក្រឲ្យមានសភាពរឹងប៉ឹង

ឡើង, ត្រូវព្រះមហាក្សត្រអនុវត្តន៍តាមបទបញ្ញត្តិច្បាប់, គឺច្បាប់នេះឯង ហើយដែលព្រះមហាក្សត្រត្រូវប្រតិបត្តិ ។ ចំណែកខាងយើង ដែលធ្វើដំណើរមកកាន់ទីនេះក៏ដោយហេតុបទបញ្ញត្តិច្បាប់, យើងអាចដឹងបានថាអ្នកឯងមកនេះដើម្បីនឹងប្រព្រឹត្តនូវសកម្មភាពអ្វីមួយជាប្រាកដ" ។

ជនបរទេសបានស្ដាប់នូវព្រះរាជឧង្ការព្រះបាទវិក្រមាទិត្យ ក៏ក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព, ទ្រង់មានព្រះរាជហឫទ័យខ្ជាប់ខ្ជួននឹងច្បាប់ជាយ៉ាងខ្ពង់ខ្ពស់, ល្អហើយ ! ទ្រង់បានមានព្រះឧង្ការថាទូលព្រះបង្គំដែលមកកាន់ទីនេះ ដើម្បីនឹងប្រព្រឹត្តសកម្មភាព នោះត្រូវហើយ !" ។ ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះបន្ទូលនឹងជនបរទេសថា: "ចូរអ្នកនិយាយមកចុះ តើឲ្យយើងធ្វើអ្វី ?" ។ បុរសក៏ក្រាបបង្គំទូលថា: "បពិត្រព្រះបរមពល នៅលើភ្នំនិល (Nila) មាននាងទេវធីតាមួយអង្គនាម កាមខ្យា (Kamakbya), ទូលព្រះបង្គំជាខ្ញុំបានសូត្រមន្តថ្វាយបង្គំព្រះនាងកាមខ្យានេះអស់រយៈវេលា ១២ ឆ្នាំ ដើម្បីឲ្យបានសម្រេចនូវសេចក្ដីស្នេហានឹងមនោសញ្ចេតនាផ្សេងៗ តែមិនបានដូចបំណងសោះ ព្រោះហេតុនេះបានជាទូលព្រះបង្គំមានចិត្តព្រួយជាខ្លាំង" ។

ព្រះបាទវិក្រមាទិត្យទ្រង់ព្រះសណ្ដាប់នូវពាក្យបុរសហើយ ទ្រង់ក៏មានព្រះតម្រិះក្នុងព្រះរាជហឫទ័យថា "បុរសនេះបានសូត្រមន្តជាច្រើនលើកហើយមិនបានសម្រេច ប្រហែលជាមានហេតុអ្វីមួយជាឧបសគ្គ" ។

ដល់ទ្រង់ព្រះតម្រិះយ៉ាងនេះហើយ, ទ្រង់ក៏នាំបុរសនោះហោះទៅកាន់ភ្នំនិលជាមួយព្រះអង្គ, ជិតបូជនីយដ្ឋាននៃនាងទេវធីតា "កាមខ្យា"

ហើយ ទ្រង់ឈប់ប្រថាប់នៅទីនោះ ។ ដល់ពេលយប់ ទ្រង់ក៏ផ្ទុំលក់ ទ្រង់បានសុបិននិមិត្តឃើញនាងទេវធីតា "កាមខ្សា" មកក្រាបបង្គំទូល ព្រះអង្គថា "បពិត្រមហាពជ, ហេតុដូចម្ដេចបានជាព្រះអង្គទ្រង់ស្ដេច យាងមកកាន់ទីនេះ? បើទ្រង់ស្ដេចយាងមកនេះដោយហេតុមនោ-សញ្ចេតនានៃបុរសនោះ ដែលសុំព្រះសព្ទសាធុការឲ្យបានសម្រេចដូចបំណង, សូមទ្រង់ធ្វើពលិកម្មចំពោះទូលព្រះបង្គំ នូវមនុស្សម្នាក់ដែលមាន រូបលក្ខណៈ ជារូបទង់ជ័យពេជ្រ, ជន្លួញ ... ល ... គឺបុរសមានរូប លក្ខណៈម្ភៃយ៉ាង ដែលបានចារិកទុកក្នុងគម្ពីរសាមុទ្រកសាស្ត្រ (Sâmu-drakacâstra), ពេលនោះទើបនឹងបានសម្រេចទៅតាមបំណងមិនខាន" ។ ព្រះបាទវិក្រមាទិត្យ. ក្រោយដែលទ្រង់ព្រះសុបិននិមិត្ត, ទ្រង់តើនឡើង ពីក្រឡាព្រះបន្ទំ ទ្រង់ព្រះពស្ត្រ ហើយទ្រង់ព្រះពជតម្រិះថា: "ក្រៅ តែពីខ្លួនអញចេញ, គ្មានបុរសណាមានរូបលក្ខណៈទាំង ២០ ប្រការ នេះសោះឡើយ គឺព្រះនាងសំដៅយកអញនេះឯងធ្វើពលិកម្ម ដើម្បី នឹងអនុគ្រោះដល់បុរសនោះ" ។

កាលទ្រង់ព្រះតម្រិះដូច្នោះហើយ, លុះដល់ពេលបច្ចុសសម័យ ទ្រង់ស្ដេចយាងទៅស្រង់ព្រះទឹក: ទ្រង់សូត្រមន្តធ្វើអញ្ជលីកម្មសព្វ គ្រប់ ហើយទ្រង់កាន់ព្រះខ័នថ្វា ទើបទ្រង់ស្រែកប្រកាសជាខ្លាំងឡើង ថា សូមយកទ្រង់ធ្វើពលីកម្មចំពោះព្រះនាងទេវធីតាចុះ ។ ព្រះនាងក៏ បង្ហាញនូវរូបជាក់ច្បាស់ ចំពោះព្រះភក្ត្រទ្រង់, ព្រះនាងបានកាន់ព្រះ ហស្តព្រះអង្គទាំងពីរ រួចទូលថា: "បពិត្រព្រះអធិរាជ, ព្រះអង្គទ្រង់

ជាមហាបុរសប្លែកពីជនធម្មតា, ទ្រង់មានព្រះរាជហឫទ័យខ្ជាប់ខ្ជួនចំពោះច្បាប់ ដោយគ្មានអ្នកណាមួយដូចព្រះអង្គ, ខ្ញុំម្ចាស់ចង់ដឹង តើពលីកម្មរបស់ព្រះអង្គត្រឹមណា, បានជាខ្ញុំម្ចាស់មកសំដែងអាការៈក្នុងសុបិននិមិត្តចំពោះព្រះអង្គ; ឥឡូវខ្ញុំម្ចាស់បានដឹងសព្វគ្រប់ហើយ, ព្រះអង្គមិនបាច់យកព្រះរូបព្រះអង្គធ្វើមហាយញ្ញៈទេ ខ្ញុំម្ចាស់សូមព្រះអង្គមានព្រះរាជឱង្ការចុះ តើទ្រង់សព្វព្រះរាជហឫទ័យចង់បានអ្វី?" ។ មហារាជទ្រង់មានព្រះបន្ទូលតបថា: "ឱនាងទេវធីតា, បើនាងសប្បាយចិត្តនឹងខ្ញុំ ។ សុំឲ្យនាងសម្រេចនូវមនោសញ្ចេតនានៃបុរសនេះឲ្យបានតាមបំណងចុះ" ។ ព្រះនាងទ្រង់សណ្ដាប់នូវព្រះបន្ទូលរបស់ព្រះអង្គហើយ ក៏បានញុំាងបុរសនោះឲ្យសម្រេចទៅតាមបំណង ហើយព្រះនាងក៏បាត់ខ្លួនពីទីនោះទៅ ។ ដោយសេចក្ដីអនុគ្រោះព្រះនាងទេវធីតា, មនោសញ្ចេតនាទាំង ៩ ប្រការក៏បិតខ្ជាប់ខ្ជួននៅក្នុងចិត្តបុរស គឺ ស្នេហា ១, វីរភាព ១, មុទិតា ១, ការឆ្ងល់ ១, ការសប្បាយ ១, ការភ័យខ្លាច ១, ការខ្ពើមរអើម ១, ទោមនស្ស ១, សោកៈ ១ ។ ចំណែកឯមហារាជ, ទ្រង់ក៏ស្ដេចវិលត្រឡប់ទៅកាន់ព្រះរាជនិវេសនដ្ឋានវិញ ។

រូបទេពនិម្មិតទី ២១ ទូលបន្ថែមថា: "មហាក្សត្រិយ៍គោជៈ បើទ្រង់មានព្រះរាជហឫទ័យអនុគ្រោះអ្នកដទៃបែបនេះ ទ្រង់អាចនឹងគង់នៅលើព្រះបល្ល័ង្កទិព្យនេះបាន" ។

ព្រះបាទគោជៈ ទ្រង់ព្រះសណ្ដាប់នូវព្រះបន្ទូលនៃរូបទេពនិម្មិតទីម្ភៃមួយហើយ ទ្រង់ក៏ស្ដេចចេញពីទីនោះទៅ ។ (មានត)

*
* *

# កំណត់ដឹង ប្រវត្តិការណ៍

## សេចក្តីកត់ហេតុ

អំពីគ្រោងការបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា ដែលត្រូវធ្វើក្នុង ថ្ងៃ ១៥ កើតខែពិសាខ ឆ្នាំរកានព្វស័ក (១៣ ឧសភា ១៩៥៧)

## របស់ក្រសួងធម្មការ

---

ឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំមួយ ខែមករា ថ្ងៃទីម្ភៃប្រាំ ត្រូវនឹងថ្ងៃដប់បីកើត ខែមាឃ ឆ្នាំមមែ ព.ស. ពីរពាន់បួនរយកៅសិបប្រាំបី វេលាម៉ោងប្រាំពីរ សាមសិបនាទី ។

នៅមន្ទីរស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ, សមាជិកគណៈកម្មការដែលកើតឡើងដោយអំណាចប្រកាសក្រសួងនាយករដ្ឋមន្ត្រីលេខ ៤.៨៥៨ ចុះថ្ងៃទី ១៣ ខែធ្នូ គ.ស. ១៩៥៥ បានមកប្រជុំក្រោមអធិបតីភាពនៃលោក ទ្រិញ-ហ៊ាញ រដ្ឋលេខាធិការក្រសួងធម្មការ សាសនសិក្សាធិការ ។ សមាជិកដែលបានមកប្រជុំក្នុងពេលនោះមានសមាសភាពដូចតទៅនេះ :

— លោក ទ្រិញ-ហ៊ាញ រដ្ឋលេខាធិការក្រសួងធម្មការជាប្រធាន;

— សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ ជាសមាជិក;

— ព្រះធម្មត្រៃលោកាចារ្យ បិតសីលោ តំណាងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្ត ជាសមាជិក;

– លោក ក៉យ-លុត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ តំណាងពទ្ធិកសមាគមកម្មជរដ្ឋ ជាសមាជិក;

– លោក ក៉យ-ប៊ុក នាយប៉ុយរ៉ូក្រសួងឃោសនាការតំណាងសមាគមមិត្តពុទ្ធិកវិទ្យាល័យ ជាសមាជិក;

– លោក ម៉ុន-សាអឿន អនុមន្ត្រី តំណាងក្រសួងមហាផ្ទៃ ជាសមាជិក;

– លោក ឡាំថាញ់-ស៊ី នាយការិយាល័យក្រសួងហិរញ្ញវត្ថុ តំណាងក្រសួងហិរញ្ញវត្ថុ ជាសមាជិក;

– លោក លឿង-ណាល់ កូឈួយខែត្រសៀមរាប តំណាងឯកឧត្តមរាជប្រតិភូប្រចាំខែត្រសៀមរាប ជាសមាជិក;

– លោក ហែម-បំរើន នាយកជាតិមន្ទីរទេសចរ ជាសមាជិក;

– លោក អំ-ម៉ន ហៅ ហំសុង តំណាងរដ្ឋមន្ត្រីក្រសួងការបរទេស ជាសមាជិក;

– លោក ទន់ កាន់ តំណាងឧបាសកខាងគណៈធម្មយុត្តិ ជាសមាជិក;

– លោក ម៉ី-នាង តំណាងឧបាសកខាងគណៈមហានិកាយ ជាសមាជិក;

– លោក មៅ-កាអុន នាយការិយាល័យក្រសួងធម្មការ ជាលេខាធិការ ។

លុះជួបជុំហើយ លោក ទ្រឹញ-ពាញ ប្រធានបានបើកពេលប្រជុំដោយមានថ្លែងអំណរគុណ ចំពោះសម្តេចនឹងអស់លោកជាសមាជិកជាមុន រួចហើយ លោកមានប្រសាសន៍រៀបរាប់អំពីរបៀបវារៈដែលត្រូវយកមកជូនសន្និបាតពិភាក្សា ដោយបានលើកយកអត្ថន័យនៃប្រកាសក្រសួងនាយករដ្ឋមន្ត្រី លេខ ៤.៨៥៨ ខាងលើមកពិតទូល ជំរាបសម្តេចនឹងអស់លោកជាសមាជិកតាមន័យដូចតទៅនេះ:

សូមពិត ទូល សម្តេច !

សូមជំរាប អស់លោក !

តាមអត្ថន័យនៃប្រកាសខាងលើនេះ កើតឡើងក្នុងជំនាន់រដ្ឋាភិបាលសម្តេចព្រះឧបយុវរាជ ព្រះអង្គបានផ្តួចព្រះរាជហ្ឫទ័យ ថានឹងរៀបចំធ្វើពិធីបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅទឹកន្លែងអង្គរវត្ត ខេត្តសៀមរាប ហើយសុំឲ្យគណៈកម្មការគ្រោងការអំពីមុខច្បាក់ចំណាយ នឹងការអញ្ជើញអ្នកបរទេស ពីប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា នឹងប្រទេសជាមិត្តភក្តិឲ្យមកជាភ្ញៀវយើងក្នុងពេលបុណ្យនេះ ។

## អំពីទីកន្លែងបុណ្យ

នៅខាងដើមនៃសេចក្តីពិភាក្សានេះ ខ្ញុំព្រះករុណា-ខ្ញុំសូមឲ្យទីប្រជុំពិភាក្សាអំពីកន្លែងសម្រាប់ធ្វើបុណ្យជាមុន តើគួរយកអង្គរវត្តតាមព្រះរាជបំណងនៃសម្តេចព្រះឧបយុវរាជឬយ៉ាងណា ?

លោក លៀង-ណាល់ថា ទីកន្លែងនេះប្រពៃណាស់ហើយ ព្រោះ

ជាគោលចារិកនៃប្រទេសខ្មែរសម័យឯករាជ្យសម្បូណ៌, តែមានសេចក្តីលំបាកយ៉ាងខ្លាំងក្នុងការទទួលភ្ញៀវ ព្រោះខ្លះផ្ទះជាកន្លែងទទួលភ្ញៀវ ខ្លះទឹកប្រើប្រាស់ ខ្លះភ្លើង ហើយមានឧបសគ្គមួយទៀត គឺថាពួកខ្មែរយើងពីខេត្តដទៃ ដែលត្រូវការទៅមើលបុណ្យនោះ មិនដឹងជានៅអាស្រ័យកន្លែងណា ព្រោះខេត្តសៀមរាបនេះ ខ្ញុំតែងប្រទះឃើញក្នុងពេលបុណ្យចូលឆ្នាំម្តងៗ នូវពួកអ្នកពីខេត្តក្រៅដែលទៅមើលអង្គរហើយគ្មានស្គាល់គេ តែងឃើញអាស្រ័យដំណេកក្រោមម្លប់ឈើកាត់ច្រើន ឃើញថាលំបាកក្រៃលែងក្នុងការទទួលភ្ញៀវ តែស្រេចលើសម្តេចនិងអស់លោកពិចារណាតទៅទៀតចុះ ។

លោក ទ្រឹញ-វ៉ាញ មានប្រសាសន៍ថា បើដូច្នេះ សូមសម្តេចនិងអស់លោកពិចារណាម្តងទៅទៀត នូវកន្លែងសម្រាប់ធ្វើបុណ្យ ។

សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ និងលោកប៉ាយ-លុត បានមានយោបល់ស្របគ្នាថា បើគិតពីសេចក្តីលំបាកឃើញថាពិតមែនហើយ តែគួរគោរពតាមព្រះរាជបំណងនៃសម្តេចព្រះឧបយុវរាជដែលព្រះអង្គបានផ្តាំផ្ញើមកហើយ ។

លោកប្រធានសួរថា បើដូច្នេះ អស់លោកយល់ដូចម្តេច?

អស់លោកជាសមាជិកទាំងអស់មានយោបល់ស្របតាមសម្តេច និងលោកប៉ាយ-លុត បានអនុមតិយកអង្គរ ខេត្តសៀមរាបជាទីកន្លែងបុណ្យ ។

# អំពីការតាំងគណៈកម្មាធិការនាយករៀបពិធីបុណ្យ

លោកប្រធានថា គួរយកកន្លែងណា នៅអង្គរធ្វើជាកន្លែងបុណ្យ? ។

លោកហែម - ចំរើនថា ត្រូវយកអង្គរវត្តជាកន្លែងធ្វើបុណ្យ ព្រោះមានទឹកជិតផង ស្អាតល្អផង ជិតទីក្រុងសៀមរាបផង ។ សមាជិកទាំងអស់យល់ស្របតាមលោក ហែម - ចំរើន ។

លោកប្រធានសួរថា បើមានយោបល់ស្របគ្នាថាយកកន្លែងអង្គរវត្តដូច្នេះហើយ សូមអស់លោកទាំងសម្តេចមេត្តាជ្រើសរើសរូបស្សរជន ឬបុគ្គលិក ដើម្បីជ្រើសតាំងជាសមាជិកគណៈកម្មាធិការនាយក ១ ក្រុម សម្រាប់ចាត់ការបុណ្យនេះ តើគួរយកប៉ុន្មានរូប?

សម្តេចព្រះសង្ឃនាយកថា គួររើសតាំងចំនួន ២០ រូប ហើយត្រូវរើសតែតស្សរៈជនបុគ្គលិកកជការដែលមានសមត្ថភាព ព្រមទាំងមានសេចក្តីព្យាយាមឲ្យបានមុឺងម៉ាត់ល្អ កុំឲ្យឈរតែឈ្មោះទទេហើយមិនព្រមជួយធ្វើការនោះមិនកើតទេ ។

ក្រុមសន្និបាតយល់ស្របតាមសម្តេច ។ បន្ទាប់តទៅទៀត ក្រុមសន្និបាត បានពិភាក្សាអំពីការជ្រើសរើសរូបស្សរជនឲ្យធ្វើជាសមាជិកគណៈកម្មាធិការនាយកសម្រាប់ចាត់ការបុណ្យនេះ ។ ក្រុមសន្និបាតបានសម្រេចជ្រើសរើសរូបស្សរជនមានសមាសភាពដូចតទៅនេះ :

១– លោករដ្ឋមន្ត្រីក្រសួងធម្មការ ជាប្រធាន;

២– សម្តេចព្រះសង្ឃនាយកទាំង ២ គណៈ ជាអនុប្រធានកិត្តិយស;

៣- លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្តីណាន់ ជាអនុប្រធាន;

៤- លោករដ្ឋមន្ត្រីក្រសួងសាធារណការប្តីណាន់ ជាអនុប្រធាន,

៥- លោកហែម-ចំរើន នាយកជាតិមន្ទីរទេសចរ ជាអនុប្រធាន,

៦- លោករដ្ឋមន្ត្រីក្រសួងឃោសនាការប្តីណាន់ ជាសមាជិក,

៧ លោករដ្ឋមន្ត្រីក្រសួងការបរទេសប្តីណាន់ "

៨- លោករដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុប្តីណាន់ ជាសមាជិក

៩- លោករដ្ឋមន្ត្រីក្រសួងសិក្សាធិការប្តីណាន់ "

១០- លោករដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មប្តីណាន់ "

១១- លោករដ្ឋមន្ត្រីក្រសួងសុខាភិបាលប្តីណាន់ "

១២- លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្តីណាន់ "

១៣- នាយកខេត្តសៀមរាបប្តីណាន់ "

១៤- ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ "

១៥- ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ "

១៦- ខាងក្រុមគង្គារក្រោនីងប្រមាញ់ "

១៧- ខាងព្រះបរមរាជវាំង ១ រូប "

១៨- ខាងក្រុមសុំយោជី ១ រូប "

១៩- យកខាងអ្នកជំនួញ ៤ រូប គឺខាងគណៈធម្មយុត្តិ

២ រូប ខាងគណៈមហានិកាយ ២ រូប "

២០- ខាងតំណាងរាស្ត្រ ២ រូប "

២១– ខាងក្រុមប្រឹក្សាព្រះរាជាណាចក្រ ២ រូប សមាជិក ។

អំពីការជ្រើសតាំងសមាជិកគណៈកម្មាធិការនាយកដែលបានតម្រូវទៅលើគ្រប់ក្រសួងរដ្ឋមន្ត្រីខាងលើនេះ ក្រុមសន្និបាតបានសម្រេចប្រគល់ការៈឲ្យលោករដ្ឋមន្ត្រីក្រសួងធម្មការ ដែលមានឋានៈជាប្រធានតាមប្រកាសក្រសួងនាយករដ្ឋមន្ត្រីខាងលើនេះ ទទួលភារៈធ្វើចុតហ្មាយទៅគ្រប់ក្រសួងសុំតំណាង ១ រូប ដែលមានសមត្ថភាពគ្រប់គ្រាន់ទីងមានសេចក្ដីព្យាយាមជួយបំពេញមុខការគណៈកម្មាធិការនាយក ឲ្យបានចំរើនលឿនទៅមុខតាមគ្រោងការដែលត្រូវចាត់ ។ តមកទៀតក្រុមសន្និបាតបានសម្រេចមូលមតិថា ទីងតាំងគណៈកម្មការរងមួយក្រុមទៀត ដើម្បីជួយចាត់ការគណៈកម្មាធិការនាយក, គណៈកម្មការរងនេះ ត្រូវយកលោកចៅហ្វាយខេត្តនីមួយ ៗ ឲ្យធ្វើជាប្រធាន, ឯសមាជិកត្រូវរើសកងខែត្រតាមយោបល់យល់ឃើញនៃចៅហ្វាយខែត្រ ដែលតម្រូវលើបុគ្គលិកក្រោមឱវាទឲ្យធ្វើជាសមាជិក ។

## អំពីចេតិយនៅមុខស្ថានីយ៍រាជអយស្ម័យយាន និងព្រះសារីរិកធាតុ

បន្ទាប់មកទៀតសម្ដេចព្រះសង្ឃនាយកគណៈមហានិកាយបានមានថេរដីកាថា "ការធ្វើបុណ្យនេះទីងធ្វើតែនៅអគ្គិរតែមួយមិនបានទេ ត្រូវធ្វើនៅកន្លែងព្រះចេតិយ៍អនុស្សាវរីយ៍ ដែលតាំងនៅមុខស្ថានីយ៍អយស្ម័យ-យានកុំពេញផង ព្រោះព្រះចេតិយ៍នេះ ពួកអ្នកនគរគេនាំគ្នាបូលបុណ្យ

បានប្រាក់ប្រហែល ៦០ ម៉ឺនយកមកបំពេញការកសាងព្រះចេតិយ៍នេះ ។ មួយទៀត មុននឹងប្រារព្ធធ្វើបុណ្យនេះ ត្រូវក្រសួងធម្មការសុំព្រះសារីរិកធាតុពីប្រទេសសិរីលង្កាទាំង ៣ ប្រគេន មកដំកល់ទុកនៅប្រទេសយើង ព្រោះកាលបុណ្យព្រះបរមសារីរិកធាតុរួចហើយ គេបានសន្យានឹងយើងថា គេនឹងឲ្យព្រះបរមសារីរិកធាតុមកប្រទេសយើង បើជាយើងត្រូវការសុំគេយកមកធ្វើសក្ការបូជា ។ នាកាលបានព្រះសារីរិកធាតុមកហើយ យើងនឹងចាត់ការឲ្យពួកជាងសាលារចនាធ្វើបុស្បកដំកល់លើរថយន្តពីក្រុងភ្នំពេញ ទៅប្រតិស្ឋានធ្វើសក្ការបូជានៅអង្គរ លុះរួចពិធីបុណ្យនេះហើយ យើងនឹងនិមន្តព្រះសារីរិកធាតុនេះមកប្រតិស្ឋាននៅកងព្រះចេតិយ៍អនុស្សាវរីយ៍នាក្រុងភ្នំពេញវិញ តាមកម្មវិធីបុណ្យដែលគណៈកម្មាធិការនាយកបានចាត់ ។ ឯការសុំព្រះបរមសារីរិកធាតុពីប្រទេសសិរីលង្កាមកប្រទេសយើងនេះ ត្រូវប្រគល់ឲ្យក្រសួងធម្មការចាត់សុំកងនាមនៃព្រះរាជរដ្ឋាភិបាល ” ។

លោកប្រធានបានទទួលថានឹងធ្វើតាមសម្ដេច តែចាំទូលស្នើដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សុំព្រះរាជយោបល់ព្រះអង្គជាមុនសិនទើបចាត់ការតទៅ ។ សមាជិកទាំងអស់យល់ព្រមតាមយោបល់សម្ដេចនិងលោកប្រធាន ដោយបានអនុមតិជាឯកច្ឆន្ទ ។

## អំពីគ្រោងប្រាក់ចំណាយ

មធ្យោបាយរកប្រាក់សម្រាប់ចំណាយធ្វើបុណ្យ, លោកក៏យ-លុត

បានមានប្រសាសន៍ថា ត្រូវរកប្រាក់ដោយវិធានការ ២ យ៉ាង គឺ

១) ដោយសុំព្រះរាជរដ្ឋាភិបាល ចំណាយនូវប្រាក់ថវិកាជាតិតាមចំនួនដែលគណៈកម្មាធិការនាយកបានគ្រោងទុក ហើយសុំតាមមុខការ ។

២) ដោយពិធីអំពាវនាវអ្នកស្រុកជាពុទ្ធបរិស័ទឲ្យជួយផ្គត់ផ្គង់តាមធនធានដោយមធ្យោបាយគ្រប់បែបគ្រប់យ៉ាង មានធ្វើសលាកសញ្ញាដើរលក់ជាដើម ។ សម្ដេចថា គួរធ្វើសលាកសញ្ញាទ្រង់ទ្រាយសណ្ឋានដូចកោដ្ឋដំកល់ព្រះបរមសារីរិកធាតុ ។ លោកហែម-ចំរើនថា គួរធ្វើសលាកសញ្ញានេះ ដោយវត្ថុ៣ប្រការគឺ មាស, ប្រាក់, ស្ពាន់ លក់ឲ្យពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដែលមានសទ្ធាជ្រះថ្លាជួយឧបត្ថម្ភបុណ្យនេះ ។ ក្រុមសន្និបាតបានយល់ព្រមជាឯកច្ឆន្ទ ។

## អំពីអញ្ជើញភ្ញៀវបរទេស

ការអញ្ជើញជនបរទេសឲ្យមកជាភ្ញៀវក្នុងពិធីបុណ្យនេះ ក្រុមសន្និបាតបានមូលមតិគ្នាស្រេចអញ្ជើញភ្ញៀវបរទេសដូចខាងក្រោមនេះ :

– ប្រទេសឥណ្ឌាដែលជាកន្លែងអ្នកកាន់ព្រះពុទ្ធសាសនា
– ប្រទេសសិរីលង្កា
– ប្រទេសភូមា
– ប្រទេសនេប៉ាល់
– ប្រទេសថៃ
– ប្រទេសលាវ

- ប្រទេសយួនខាងជាតិនិយម
- ប្រទេសជប៉ុន
- ប្រទេសអូស្ត្រាលី
- ប្រទេសឥណ្ឌូណេស៊ី
- ប្រទេសបារាំង
- ប្រទេសអាមេរិក
- ប្រទេសម៉ាឡេស៊ី ។

ចំនួនភ្ញៀវគ្រប់ប្រទេសដូចមាននាមខាងលើនេះ,យើងត្រូវអញ្ជើញតែត្រឹម ២ រូបក្នុងប្រទេសមួយ ៗ ហើយយើងត្រូវទទួលភារៈម្ហូបអាហារ, យានជំនិះ កន្លែងសំណាក់នឹងដឹកនាំជូនដំណើរទស្សនាទីកន្លែងផ្សេង ៗ ក្នុងប្រទេសយើង តាមកម្មវិធីដែលនឹងរៀបចំទៅថ្ងៃមុខ ។ ឯភ្ញៀវដែលមកលើសពីចំនួនដែលយើងត្រូវអញ្ជើញ គឺភ្ញៀវដែលគេត្រូវការមកមើលបុណ្យនេះ យើងត្រូវបើកសិទ្ធិឲ្យគេមកតាមចិត្ត តែត្រូវសុំឲ្យគេបញ្ជូនបញ្ជីចំនួនភ្ញៀវទាំងនេះមកឲ្យយើងដឹងមុន ៣ ខែ ឯការគ្រប់យ៉ាងមានអាហារគោជនទីសំណាក់ជាដើម ត្រូវការៈគេរកខ្លួនឯង យើងគ្រាន់តែបើកសិទ្ធិឲ្យមកជាភ្ញៀវធម្មតា ។

## អំពីកាលបរិច្ឆេទដែលធ្វើបុណ្យ

លោកប្រធានបានថ្លែងថា ពុទ្ធសករាជប្រទេសឥណ្ឌា, លង្កា នឹងភូមា លឿនជាងពុទ្ធសករាជខ្មែរ, ថៃ, លាវ មួយឆ្នាំ គេនឹងរៀបចំ

ធ្វើពិធីបុណ្យពាក់កណ្ដាលព្រះពុទ្ធសាសនា នៅខែ ឧសភា ១៩៥៦ នេះ, ចំណែកប្រទេសខ្មែរយើងនឹងធ្វើនៅឆ្នាំក្រោយ (១៩៥៧) គឺក្រោយផលោះ ១ ឆ្នាំ ។ ចំពោះការបរិច្ឆេទនេះ សម្ដេចព្រះសង្ឃនាយកបានថ្លែងថា ពុំដឹងជាខាងណាខុសខាងណាត្រូវទេ, តែកាលបរិច្ឆេទកំណត់ពាក់កណ្ដាលព្រះពុទ្ធសាសនា សម្រាប់ប្រទេសខ្មែរយើងគឺនៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំរកាឆព្វស័ក ព. ស. ២៥០០ គត់ត្រូវនឹងថ្ងៃទី ១៣ ឧសភា ១៩៥៧, គឺថ្ងៃទី ១៣ ឧសភា ១៩៥៧ នេះឯងប្រទេសកម្ពុជាយើង កំណត់ធ្វើបុណ្យរំលឹកពាក់កណ្ដាលព្រះពុទ្ធសាសនាព្រមទាំងធ្វើបុណ្យសម្ពោធព្រះចេតិយ ១ ដែលកំពុងសាងនៅមុខស្ថានីយ៍រថភ្លើងភ្នំពេញសព្វថ្ងៃទុកជាអនុស្សាវរីយ៍ ។

## អំពីចំនួនថ្ងៃដែលត្រូវធ្វើបុណ្យ

អំពីចំនួនថ្ងៃដែលធ្វើបុណ្យនេះ, សមាជិកក្រុមសន្និបាតមានយោបល់ផ្សេងៗ គ្នា លោកខ្លះថាធ្វើ ៣ ថ្ងៃ លោកខ្លះថា ៧ ថ្ងៃ លោកខ្លះថា ១៥ ថ្ងៃ; ក្រុមសន្និបាតបានអនុម័តកំណត់បុណ្យនេះចំនួន ១៥ ថ្ងៃ ឲ្យសមតាមការដែលយើងបានរៀបចំអស់ប្រាក់ច្រើនផង សមតាមយោបល់សម្ដេចព្រះសង្ឃនាយកផង ដែលសម្ដេចបានធ្វៀតជូនន័យដល់សមាជិកក្រុមសន្និបាត ដោយលើកពិធីបុណ្យដែលបានធ្វើក្នុងកាលព្រះអង្គបរិនិព្វានមានកំណត់ ១៥ ថ្ងៃដែរ គឺដកល់ព្រះបរមសព ៨ ថ្ងៃ រើសព្រះ

បរមធាតុរួចហើយ គេធ្វើ ៧ ថ្ងៃតមកទៀត គំរប់ជា ១៥ ថ្ងៃ; ឯពិធីបុណ្យយើង ១៥ ថ្ងៃនេះ គិតទាំងនៅភ្នំពេញ - អង្គរផង ។

## ការសំអាតក្រុងសៀមរាប

បន្ទាប់ពីនោះមកទៀត លោកលឿង - ណាល់ បានឆ្លៀតឱកាសនេះសុំក្រុមសន្និបាតជួយសុំដល់ព្រះរាជរដ្ឋាភិបាលចំណាយថវិកា សំអាតក្រុងសៀមរាប គឺធ្វើថ្នល់ពីខែត្រទៅអង្គរ - ទៅភ្នំក្រោម - ទៅបារាយណ៍ទឹកថ្លា ផ្លូវបន្ទាយស្រី ដើម្បីឲ្យសមរម្យដល់ពួកបរទេស ដែលគេត្រូវការទៅទស្សនាបុរាណវត្ថុទាំងនោះ ។ ក្រុមសន្និបាតយល់ព្រមថានឹងសុំឲ្យគណៈកម្មាធិការនាយកស្ថាពរជួយសុំដល់រាជរដ្ឋាភិបាល តាមសេចក្ដីសុំនៃលោកលឿង - ណាល់ ។

ទីបំផុត លោកប្រធានបានមានប្រសាសន៍ទូល - ជំរាបទីប្រជុំថា ការជំនុំនេះនឹងចុះក្នុងសេចក្ដីកត់ហេតុ ហើយធ្វើបុតហ្មាយថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យយ៉ាងណា យើងនឹងចាត់ការជ្រើសរើសរូបសមាជិកគណៈកម្មាធិការនាយកឲ្យសម្រេចការតាមព្រះរាជយោបល់តទៅ ។

ការបិទពេលប្រជុំនៅវេលាម៉ោង ១០. ព្រឹក ។

បានលើកពេលប្រជុំនៅវេលាម៉ោង ១០ កាលបរិច្ឆេទដូចមានខាងលើ ។

# ពិធីសម្ពោធឆ្លងមន្ទីរពេទ្យព្រះសង្ឃ

ពុទ្ធសាសនបណ្ឌិត្យ

វេលាព្រឹកថ្ងៃទី ២១ កុម្ភៈ ១៩៥៦, នៅខាងត្បូងស្ពានយោមរាជ មានធ្វើបុណ្យមួយដ៏ឧឡារិក ហៅថា "ពិធីសម្ពោធឆ្លងមន្ទីរពេទ្យព្រះសង្ឃ" ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

ក្នុងកំពែងនៃមន្ទីរពេទ្យនោះ មានបារាំធំៗសម្រាប់ទទួលព្រះសង្ឃ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, វរជនខាងប្រទេសក្រៅ ក្នុងប្រទេស និងពុទ្ធបរិស័ទទាំងឡាយឯទៀតៗ ព្រមទាំងមានវេទិកាខ្ពស់តូចមួយនៅចន្លោះបារាំធំៗ និងមន្ទីរពេទ្យសម្រាប់ធ្វើសក្ការៈ ។ បារាំទាំងនោះ គេប្រក់ដោយសំពត់, នៅជាយជុំវិញ គេចងក្រងស្លឹកក្រុកជាតិពណ៌ខៀវខ្ចីស្រស់, គេដោតទង់ជាតិនិងទង់សាសនាជាចន្លោះៗ ព្រោងព្រាត ព្រមទាំងក្រាលកម្រាលរំលេចពណ៌ក្រហមស តាមផ្លូវពីបារាំដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ប្រថាប់រហូតដល់ទ្វារនៃមន្ទីរពេទ្យ ។

រីឯមន្ទីរពេទ្យនេះមានទំហំនិងកំពស់សមរម្យតាមសម័យ នាំឲ្យពួកជនដែលបានទស្សនាកោតស្ញប់ស្ញែងយ៉ាងក្រៃលែង គឺគេធ្វើដោយគ្រឿងសម្ភារៈបេតុងអារម៉េនិងឥដ្ឋ មានបណ្ដោយ ៨២ ម៉ែត្រ, ទទឹងត្រង់កន្លែងធំ ២០ ម៉ែត្រ ត្រង់កន្លែងតូច ១០ ម៉ែត្រ, កំពស់ ១៦ម៉ែ៨០ ត្រឹមលាន មានបន្ទប់សម្រាប់ព្រះសង្ឃសឹង ៣០, ចំណុះបាន ១៥០ គ្រែ ។

នៅថ្នាក់ក្រោមគេចែកជាបន្ទប់ៗ បន្ទប់មួយចំណែកសម្រាប់ធ្វើជាឃ្លាំង,

មួយចំណែកជាការិយាល័យក្រុមអភិបាល, មួយចំណែកជាការិយាល័យក្រុមបច្ចេកទេស (តិចនិក), មួយចំណែកទៀតជាសាលពិគ្រោះ ។

នាថ្នាក់លើបំផុត (លានខាងលើ) គេរចនាចាក់ក្រាលដោយបេតុងអារម៉េហើយក្រាលដោយឥដ្ឋ ៤ ជ្រុង ធ្វើជាលានលាតឥតមានដំបូល, គេដាំដើមផ្កាផ្សេង ៗ ព័ទ្ធជុំវិញឲ្យរាងទ្បើងព័ទ្ធពីលើ ដើម្បីបំបាត់កំដៅថ្ងៃដល់គិលានសមណៈ ដែលឡើងទៅលំហើយកាយម្តងមួយកាល, ប៉ុន្តែត្រង់ជាយខាងលិចខាងកើតនឹងខាងជើង មានបន្ទប់តូច ៗ មានដំបូលគួរជាទីជ្រះថ្លា ។

ក្នុងពិធីសម្ពោធនោះ យើងសង្កេតឃើញពុទ្ធបរិស័ទ ជាព្រះសង្ឃខ្លះ ជាគ្រហស្ថខ្លះ; ខាងព្រះសង្ឃ មានសម្តេចព្រះមហាសុមេធាធិបតីជួន - ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណព្រះអរិយកស្សប អ៊ូច តំណាងព្រះសង្ឃនាយកគណៈធម្មយុត្តិ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ព្រះតេជព្រះគុណព្រះមហាព្រហ្មមុនី ទេព - អ៊ូ ចាងហ្វាងរងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នឹងភិក្ខុសង្ឃឯទៀតជាច្រើន; ខាងគ្រហស្ថ មានសម្តេចក្រុមព្រះស៊ីសុវត្ថិ - មុនីរ៉េត, ព្រះអង្គម្ចាស់ប៉េងប៉ោះ - យុគន្ធរ, ប្រធានសភាទាំងពីរ, លោកអ៊ុំ-ឈាងស៊ុន នាយករដ្ឋមន្ត្រី, លោកហ៊ុយ-កន្थុល អតីតនាយករដ្ឋមន្ត្រី, លោកមៀច - គន្ធ ចៅហ្វាយក្រុងភ្នំពេញ, អគ្គទូតនឹងនាយទាហានខ្មែរគប់ក្រុម ព្រមទាំងក្រុមពុទ្ធសាសនិកឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយមិនបានពប់នាម

ទាំងអស់គ្នាទីនេះ ។

ក្រោយពីព្រះករុណាជាម្ចាស់ជីវិតលើត្បូង បានស្តេចយាងទៅដល់មុខបាំ ដែលមានទាហានរក្សាព្រះអគ្គីរង្វើការវកិច្ច ទីងក្រុងព្រះរាជទ្រព្យ បន្ទីបទទួលគោរពជាព្រះរាជកិត្តិយសហើយ មានពុទ្ធសាសនិកម្នាក់ឡើងលើវេទិកា ថ្លែងរាយនាមពុទ្ធសាសនិកដែលមានបសាទសទ្ធាយ៉ាងខ្លាំងក្លាបានបរិច្ចាគបច្ច័យក្នុងការកសាងមន្ទីរពេទ្យនោះ ចំពោះតែអ្នកដែលមានសទ្ធាបរិច្ចាគ ច្រើនជាងពុទ្ធសាសនិកឯទៀត ៗ ។ តមកលោកយូន-ណៃ អធិបតីសមាគមគិលានសង្គ្រោះ ថ្លែងសុន្ទរកថា, បន្ទាប់មកលោកកែ-ណុល អគ្គលេខាធិការខាងក្រុមប្រឹក្សាចាត់ការរបស់សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ ប្រែសុន្ទរកថារបស់លោកយូន-ណៃ ទៅជាភាសាបាលី ។ តមកទៀត សម្តេចព្រះមហាសុមេធាធិបតីជួន-ណាត សង្ឃនាយកគណៈមហានិកាយ តំណាងព្រះសង្ឃគណៈមហានិកាយក្នុងប្រទេសកម្ពុជាទាំងមូល បានថ្លែងសុន្ទរកថាដោយឥតបានព្រាងទុកជាមុន មានសេចក្តីយ៉ាងទូលំទូលាយ ។ បន្ទាប់ពីសម្តេចព្រះមហាសុមេធាធិបតីមក ព្រះតេជព្រះគុណព្រះអរិយកស្សប អ៊ុច តំណាងព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ ថ្លែងសុន្ទរកថា ។ បន្ទាប់មកទៀត លោកមាស-យ៉ង់ រដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល ថ្លែងសុន្ទរកថាយ៉ាងក្បោះក្បាយ ។ បន្ទាប់ពីលោក មាស-យ៉ង់ មកលោកទ្រឹញ-ហ៊ាញ រដ្ឋលេខាធិការក្រសួងធម្មការថ្លែងសុន្ទរកថា ។

លុះចប់សុន្ទរកថា នៃព្រះសង្ឃនិងវរជនទាំងនោះហើយ ព្រះករុណាជា

ម្ចាស់ជីវិតលើត្បូង ស្ដេចយាងទតមន្ទីរពេទ្យ ដោយមានអង្គទូតទីងវរជន ទាំងឡាយហែហមទៅផង រួចស្ដេចបានយាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារដែលហែព្រះរាជដំណើរផង ទីងទាហានធ្វើគារវកិច្ចដូចកាលយាងមកដល់ចំណែកអង្គទូតទីងវរជនឯទៀតក៏អញ្ជើញទៅកាន់គាសយដ្ឋានរៀងខ្លួនដែរ ។

ឯសុន្ទរកថា នៃព្រះសង្ឃទីងវរជនទាំងនោះ យើងដកស្រង់យកមកចុះក្នុងខាងមុខនេះ ។

ដល់វេលាយប់ថ្ងៃដែល ម៉ោង ១៩,៣០ នាទី គេបាននិមន្តសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ សំដែងធម៌ទេសនា ។ បន្ទាប់មក គេបញ្ចាំងភាពយន្តជាការបង្ហើយពិធីបុណ្យនេះត្រឹមប៉ុណ្ណោះ ។

*
* *

## សុន្ទរកថាលោកឃួន-ណៃ
## ប្រធានសមាគមគិលានសង្គ្រោះ

សូមព្រះតេជះដ៏កល់លើត្បូង !

សម្ដេច ! ព្រះថេរានុត្ថេរគ្រប់ព្រះអង្គ !

ឯកឧត្តម !

លោកអ្នកសប្បុរសទាំងឡាយ !

តាងនាមនៃសមាគមគិលានសង្គ្រោះ ចំពោះព្រះសង្ឃពុទ្ធសាសនិកទីងក្នុងនាមផ្ទាល់ខ្ញុំព្រះអង្គ, ទូលព្រះបង្គំជាខ្ញុំ សូមទទួលអំណរព្រះគុណ

ដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ដែលទ្រង់ស្តេចមកជាអធិបតីតំកើងពិធីបុណ្យនេះ ឲ្យបានថ្លៃថ្លាថ្កើងថ្កាន ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំព្រះករុណាសូមទទួលអំណរគុណសម្តេច និងព្រះថេរានុត្ថេរៈ គ្រប់អង្គ, ខ្ញុំបាទសូមអរគុណសម្តេច, ឯកឧត្តមអគ្គទូតទាំងអស់, ឯកឧត្តមរដ្ឋមន្ត្រីក្នុងងារនិងអតីត ព្រមទាំងអស់លោក-អ្នកដែលបាននិមន្ត បានអញ្ជើញមកជាកិត្តិយស ជួយឲ្យពិធីបុណ្យសម្ពោធរុងរឿងយ៉ាងក្រៃលែង ។

សូមទ្រង់មេត្តាប្រោស ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់សំដែងថា សត្វលោកទាំងអស់មិនមានសេសសល់ ដែលមានជាតិហើយតែងប្រកបដោយសភាវធម៌ ៣ ប្រការ គឺ ជរា ព្យាធិ និងមរណៈ ។

ប្រសិនបើសត្វលោកមានដំណើរតាមធម៌នេះ ជាលំដាប់មុនក្រោយ សត្វទាំងនោះអាចដឹងបានថា កំណត់មរណកាល អាត្មាអញមិនទាន់ដល់ នៅសល់ប៉ុណ្ណេះប៉ុណ្ណោះទៀតទើបដល់ និងបានប្រកបការចិញ្ចឹមជីវិតតាមកំណត់ពេល ដែលសល់ខាងតទៅ សេចក្តីទុក្ខសោកក៏មានកំណត់ ហើយស្រាលផង ។

តែការពិតពុំបានដូច្នោះឡើយ យើងគ្រាន់តែដឹងថាធម៌ ៣ ប្រការនេះមានប្រាកដមែន ប៉ុន្តែយើងពុំអាចដឹងថា នឹងមានមកនៅកាលបរិច្ឆេទពេលម៉ោងណាឡើយ ព្រោះជួនកាលអ្នកកើតមុន ទទួលមរណភាពមុន ជួនកាលអ្នកកើតក្រោយ ក៏ត្រឡប់ជាទទួលមរណភាពមុនអ្នកកើតមុនទៅវិញក៏មាន ។ យ៉ាងនេះហើយដែលបណ្តាលឲ្យកើតសេចក្តីសោក

សង្រេងសង្រែងខ្សឹកខ្សួល ព្រោះជាការព្រាត់ប្រាស់និរាសចាកបុត្រធីតា-ស្វាមី-ភរិយា ដែលកំពុងស្នេហាក្នុងចិត្ត មច្ចុរាជឥតមានទទួលអង្វរបន្ធូរបន្ថយពេលវេលាបន្តិចបន្តួចសោះឡើយ ។

ព្រះសម្មាសម្ពុទ្ធបានសំដែងទៀតថា ដែលនឹងរំលត់ទុក្ខទាំងឡាយដែលមានកំណើតពីធម៌ ៣ ប្រការ (ជរា ព្យាធិ-មរណៈ) នេះបាន តោងរំលត់ជាតិ ដែលជាឫសជាគល់នៃធម៌ទាំង ៣ ប្រការនេះ ។ ដែលយើងរំលត់ជាតិបាន មានតែធម៌ ១ គឺព្រះនិព្វាន ប៉ុន្តែព្រះនិព្វានជាធម៌វិសេសបំផុតមិនងាយនឹងបាន ហើយមុននឹងទៅដល់ព្រះនិព្វាននោះសោត សត្វ-លោករមែងគប់ប្រសប់នឹងទុក្ខសោកគណនាពុំបាន, កាលបើដូច្នេះ, តើមានមធ្យោបាយណាមួយ ដើម្បីបញ្ចៀសឬបន្ធូរបន្ថយនូវទុក្ខសោកទាំងឡាយនោះបានដែរឬទេ ? បើយកធម៌ខាងដើមមកពិចារណា គង់ឃើញថាសេចក្តីសោក អាឡោះអាល័យ មកពីសេចក្តីព្រាត់ប្រាសនិរាសដែលជាបច្ច័យនៃមរណៈ ។ មរណៈមកពីព្យាធិគឺការឈឺចាប់ដោយរោគគ្របសង្កត់ លុះត្រាតែបែករលាយរូប ។

កាលបើដូច្នេះ, ការសង្គ្រោះដល់សត្វលោក ដោយការចែកថ្នាំកែរោគឲ្យសះស្បើយចាកជម្ងឺឲ្យបានធូរថយនូវទុក្ខវេទនាទាំងឡាយ នេះហើយដែលជាកុសលកម្មគប្បីធ្វើ តែថាការចែកចាយថ្នាំទូទៅមិនរើសមុខចំពោះជនក្រីក្រទាំងឃរាវាសទាំងបព្វជិតនោះ ព្រះរាជរដ្ឋាភិបាលបានធ្វើហើយ, មានមន្ទីរព្យាបាលរោគគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ; ប៉ុន្តែព្រះសង្ឃ ដែលមានវិន័យហាមឃាត់មិនឲ្យសឹងជាមួយអនុបសម្បន្ន

គឺបុគ្គលដែលមិនមែនជាភិក្ខុដូចគ្នា មិនអាចចូលទៅសីមាព្យាបាលទោសត្រូវអាបត្តិបានឡើយ, កាលបើដូច្នេះ ព្រះសង្ឃជាពពួកពុទ្ធបរិស័ទមួយដែលពុំបានទទួលអំណោយទាន ដូចជនសាមញ្ញ គប្បីសាងសង់អាគេយ្យសាលាដោយឡែក សម្រាប់ព្យាបាលជម្ងឺរោគាព្យាធិព្រះសង្ឃឱ្យបានធូរថយពីទុក្ខវេទនាទាំងឡាយ ។

ការធ្វើទានខុសប្លែកចំពោះព្រះសង្ឃបែបនេះ មានព្រឹត្តិការណ៍តាំងពីសម័យពុទ្ធកាល គឺកាលដែលព្រះពុទ្ធអង្គគង់ធរមាននៅឡើយ ។

មានដំណាលថាព្រះបាទពិម្ពិសារជាព្រះមហាក្សត្រសោយរាជ្យក្នុងក្រុងរាជគ្រឹះដែនមគធៈ ទ្រង់បានសាងគិលានសាលាសម្រាប់ព្រះសង្ឃសាវ័កនៃព្រះសម្មាសម្ពុទ្ធមិនឱ្យព្រះសង្ឃដែលមានអាពាធចូលទៅលាយឡំក្នុងគិលានសាលាសម្រាប់គ្រហស្ថ ។ ទ្រង់បានចាត់តាំងគ្រូពេទ្យធំម្នាក់ឈ្មោះកោមារភច្ច ឬហៅថាកុមារពេទ្យដូច្នេះក៏បាន ។ កោមារភច្ចនេះ ជាគ្រូពេទ្យធំក្នុងមន្ទីរពេទ្យ ដែលព្រះបាទពិម្ពិសារទ្រង់កសាងនោះ ។ កាលបើព្រះសម្មាសម្ពុទ្ធទ្រង់ប្រឈួនមួយដងមួយកាល ក៏ត្រូវគ្រូពេទ្យកោមារភច្ចពិនិត្យមើលរោគប្រឈួននៃព្រះអង្គដែរ ។

សម័យដែលព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ មានព្រះមហាក្សត្រមួយព្រះអង្គទ្រង់ព្រះនាមថា "ធម្មាសោករាជ" ឬព្រះបាទអសោករាជសោយរាជ្យក្នុងក្រុងបាតលិបុត្រដែនមគធៈ (ប្រទេសឥណ្ឌា) មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទ្រង់បានជួយឧបត្ថម្ភទំនុកបំរុងព្រះពុទ្ធសាសនាដោយពេញព្រះកំឡាំង បានសាងអាគេយ្យសាលាជាច់

ដោយឡែក សម្រាប់ព្រះសង្ឃចូលព្យាបាលរោគបានដោយស្រួល ឥតទាស់នឹងវិន័យ ។

ក្រោយតមកទៀត នៅលង្កាទ្វីបមានព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាមទុដ្ឋគាមិនីអភ័យ បានកសាងមន្ទីរពេទ្យមួយសម្រាប់ព្យាបាលរោគព្រះសង្ឃដោយឡែកនៅក្នុងក្រុងអនុរាធបុរី ។ មន្ទីរពេទ្យនោះ បាក់បែកអស់ទៅហើយ នៅសល់តែគ្រឿងដំណែលមកដល់សព្វថ្ងៃ ។

ក្នុងចំណោមពួកប្រទេសដែលព្រះពុទ្ធសាសនាសាយភាយមកដល់ប្រទេសកម្ពុជា កាលសម័យនគរធំមានព្រះមហាក្សត្រមួយព្រះអង្គ មានព្រះកិត្តិសព្ទល្បីល្បាញខ្ទរខ្ទាយក្នុងលោក គឺព្រះបាទជ័យវរ្ម័នទី ៧, ព្រះបរមក្សត្រអង្គនេះ មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាលើសលុប បានកសាងអារោគ្យសាលាដោយឡែក សម្រាប់ព្រះសង្ឃដូចកាលព្រះបាទធម្មាសោកដែរ ។

មន្ទីរពេទ្យព្រះសង្ឃនេះ តែងមានទុកតាំងពីអតីតកាលដូចរៀបរាប់ដោយសង្ខេប តែពុំបានឋិតថេរចិរកាល រៀងរហូតមកតែងដាច់ពីគ្នាយ៉ាងយូររាប់រយឆ្នាំ, ដូចជាក្នុងប្រទេសកម្ពុជានេះ តាំងពីសម័យនគរធំមកទល់សព្វថ្ងៃ ទើបមានលេចឡើងក្នុងរជ្ជកាលនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងព្រះអង្គនេះ ។

មន្ទីរពេទ្យព្រះសង្ឃនៃប្រទេសកម្ពុជាដែលស្ថាបនាទើបនឹងហើយនេះ បានរចនាតាមផែនទីរបស់លោកវិស្វករ ជី ជាភ្នាក់ងាររាជការខ្មែរធ្វើឲ្យ

ដោយអនុញ្ញាតព្រះរាជរដ្ឋាភិបាល ដែលបានជួយឧបត្ថម្ភតាំងពីដំបូងរៀងមក ។

មន្ទីរពេទ្យនេះធ្វើដោយគ្រឿងទព្វសម្ភារៈបេតុងអារម៉េទីងឥដ្ឋ មានបណ្ដោយ ៨២ ម៉ែត្រ, ទទឹងត្រង់កន្លែងធំ ២០ ម៉ែត្រ ត្រង់កន្លែងតូច ១០ ម៉ែត្រ, កំពស់ ១៦ ម៉ែ ៨០ ត្រឹមពនហាល មានបន្ទប់ព្រះសង្ឃសឹង ៣០, បំណុះ បាន ១៥០ គ្រែ ។

នៅថ្នាក់ក្រោមចែកជាបន្ទប់ៗ បន្ទប់មួយចំណែកធ្វើជាឃ្លាំង, មួយចំណែកឲ្យក្រុមអភិបាល, មួយចំណែកឲ្យក្រុមបច្ចេកទេស (តិចនិក), មួយចំណែកទៀត ធ្វើជាសាលពិគ្រោះ ។

មន្ទីរពេទ្យនេះចាប់សង់កន្លង គ. ស. ១៩៥៣ បានធ្វើបុណ្យបញ្ចុះបឋមសិលានៅថ្ងៃ ទី ២១ កុម្ភៈ ១៩៥៣ មកដល់ថ្ងៃសម្ពោធទី ២១ កុម្ភៈ ១៩៥៦ នេះ ត្រូវជា ៣ ឆ្នាំគត់ ។ តម្លៃ ១២ លានរៀល ។

កងចំនួនប្រាក់នេះ ចំណែកប្រជាជនខ្មែរបានចេញប្រាក់ចំនួន ៣ លាន ៥ សែនរៀល, ជំនួយពីរាជរដ្ឋាភិបាល ៦ លាន ៥ សែនរៀល, ជំនួយអាមេរិកាំង ២ លានរៀល រួមជា ១២ លានរៀល ។

ការសាងសង់ទីកន្លែងនេះបានពេបប្រទះនឹងឧបសគ្គផ្សេងៗ គឺ ខ្វះកម្មករ, ខ្វះភ្លើង, ខ្វះទឹក ខ្វះបុគ្គលិក ។ល។

កាលមន្ទីរពេទ្យចាប់សង់ដំបូងកន្លង គ. ស. ១៩៥៣ នៅកន្លែងវាលទំបុងភូមិបាក់ទូកមកទល់នឹងថ្នល់យោមករ ឃើញតែមានវាលស្រែគុម្ពផ្ទះអ្នកស្រុក ១ ខ្នង សោះឡើយ, លុះមន្ទីរពេទ្យសង់បានចំរើនជា

លំដាប់ឡើង ប្រជាជនក៏កាន់តែសង់ផ្ទះទីលំនៅច្រើនឡើង ។ ពេលនេះទីវាលស្រែក៏ត្រឡប់ក្លាយទៅជាភូមិករពាសពេញ រកដីទំនេរមួយដុំពុំមានការខ្វះខាតក៏ដោះស្រាយទៅឯង ។

ចំណែកបញ្ហាទឹកភ្លើង បុគ្គលិកទីប្រាក់សម្រាប់ផ្គត់ផ្គង់មន្ទីរពេទ្យ ក៏បានដោះស្រាយរួចស្រេចដែរ, តែការអនុវត្តន៍យឺតយូរបន្តិច មិនបានឲ្យផលទាន់ពេលសម្គោល ។

សូមទ្រង់ព្រះមេត្តាប្រោស!

តាងនាមនៃសមាគម ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានអនុញ្ញាតយកឱកាសនេះ សំដែងជាឱឡារិកនូវព្រះអំណរព្រះគុណ ទិគុណដ៏ខ្ពង់ខ្ពស់ចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង ដែលទ្រង់ព្រះរាជទានព្រះបរមរាជានុញ្ញាតឲ្យព្រះរាជរដ្ឋាភិបាលជួយឧបត្ថម្ភសមាគមនេះ ពេញកំឡាំងតាំងពីដំបូងរហូតមក ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានអនុញ្ញាតសំដែងចំពោះព្រះទីនាំង នូវអំណរគុណចំពោះព្រះរាជរដ្ឋាភិបាលព្រមទាំងរដ្ឋមន្ត្រីកាន់តំណែងតៗគ្នាមក ដែលបានជួយពេញកំឡាំងដោះស្រាយបញ្ហាដ៏លំបាកគ្រប់បែបគ្រប់យ៉ាងបានរួចពីដំពាក់ ។

ការជួយនេះ មិនមែនត្រាន់តែកំឡាំងរបស់ខ្លួន ថែមទាំងយកចិត្តទុកដាក់ចំពោះការដែលខ្លួនធ្វើពុំកើត ពឹងពាក់ប្រទេសក្រៅឲ្យជួយខ្វះថែមទៀតផង ។

ទូលព្រះបង្គំជាខ្ញុំ ចង់ក្រាបបង្គំទូលអំពីជំនួញសេដ្ឋកិច្ចអាមេរិកាំង

និងជំនួយសេដ្ឋកិច្ចពាក់ពន្ធ័ពិសេស ព្រះរាជរដ្ឋាភិបាលបានជួយរាល់ឆ្នាំ ក្នុង ១ ឆ្នាំ ២ លានរៀល ព្រមទាំងកិច្ចការគ្រប់ចំពូកផង ដែលជួយបានដូចគិលានុបដ្ឋាក និងការជួយផ្តល់ថ្នាំពេទ្យខ្លះជាដើម, ជំនួយនេះឃើញថាពេញកំណត់ហើយ លើសពីនេះទៅទៀតពុំកើត តែថាយកមកប្រមូល និងប្រាក់ភាគទានសមាជិកនិងអំណោយគ្រប់យ៉ាងពីពុទ្ធបរិស័ទទាំងឡាយ ក៏ពុំទាន់គ្រប់គ្រាន់, ទើបព្រះរាជរដ្ឋាភិបាលផ្ញើពាក្យសូមទៅបេសកកម្មសេដ្ឋកិច្ចអាមេរិកាំង និងបេសកកម្មសេដ្ឋកិច្ចពាក់ពន្ធ័ពិសេស ឲ្យជួយតាមកំឡាំងចិត្តរបស់គេ ។

អាមេរិកាំង គេបានជួយប្រាក់លើកដំបូងមួយលានប្រាំសែនរៀល ដើម្បីបង្កើតគ្រឹះស្ថាន និងបានជួយប្រដាប់ប្រដាសម្រាប់ពេទ្យក្នុងភាគចំនួនគ្រែ ១០០ រូបពេលបន្ទាប់គាមក ជួយប្រាក់ជាលើកទី ២ ប្រាំសែនរៀលទៀត សម្រាប់ទិញសេនាសនភ័ណ្ឌ ។

ដោយកម្លាំងជំនួយប្រាក់គេលើកដំបូងនេះហើយ ទើបគ្រឹះស្ថាននេះបានសង់រួចស្រេចក្នុងឆ្នាំនេះ តែគ្មានរបស់អ្វីសម្រាប់ប្រើប្រាស់នៅឡើយ ។

ដោយកំឡាំងជំនួយផ្តល់ប្រដាប់ប្រដាសម្រាប់មន្ទីរពេទ្យ ក្នុងភាគនេះហើយ ទើបគ្រឹះស្ថាននេះមានគ្រែ ៩៥ ព្រមទាំងបរិក្ខារនិងប្រដាប់ប្រដាប្រើប្រាស់ក្នុងមន្ទីរពេទ្យនេះខ្លះនៅវេលាសម្ពោធ ។

ដោយកម្លាំងជំនួយ ៥ សែនរៀលខាងក្រោយនេះទៀត ទើបមន្ទីរពេទ្យព្រះសង្ឃនិងមានសេនាសនភ័ណ្ឌប្រើប្រាស់នៅវេលាឆាប់ៗនេះ ។

ដោយជំនួយគ្រូពេទ្យនាយមួយរូប គិលានុបដ្ឋាកនាយមួយរូប ឡានដឹកទឹកមួយគ្រឿងពីបេសកកម្មសេដ្ឋកិច្ចនិងតិចនិកបាកំងសែស តាមពាក្យសុំពីព្រះរាជរដ្ឋាភិបាល ទើបសមាគមដោះស្រាយរួចនូវបញ្ហាបុគ្គលិកនិងទឹកសម្រាប់ប្រើប្រាស់ក្នុងមន្ទីរពេទ្យ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាត សូមព្រះរាជរដ្ឋាភិបាលផ្ញើទៅបេសកកម្មជំនួយអាមេរិកាំង និងបេសកកម្មជំនួយបាកំងសែស នូវអំណរគុណដ៏ក្រៃលែង ពីសមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃទាំងអស់ក្នុងព្រះរាជាណាចក្រ ។

ទីអវសាន, ទូលព្រះបង្គំជាខ្ញុំសូមអរគុណចំពោះលោកវិស្វករ ជី និងលោកមេការ ញ៉ា ដែលជាអ្នកត្រួតត្រាការសាងសង់នេះតាំងពីដើមរហូតដល់ហើយ ។

ទូលព្រះបង្គំជាខ្ញុំ សូមអរគុណចំពោះរាជការក្រុង ដែលបានចែកដីធ្វើមន្ទីរពេទ្យព្រះសង្ឃនេះ និងបានជួយនូវកិច្ចការបន្តិចបន្តួច មានការលក់ទឹកឲ្យជាដើម ព្រមទាំងលោកអ្នកសប្បុរសទាំងឡាយ ដែលបានជួយទំនុកបម្រុងទោះតិចទោះច្រើនក្នុងការសាងសង់មន្ទីរពេទ្យនេះ ដោយកម្លាំងទ្រព្យក្តី ដោយកម្លាំងកាយក្តី ដោយកម្លាំងចិត្តក្តី សូមប្រកបដោយពរ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ប្រតិភាណៈ និងវឌ្ឍភាពជានិច្ចនិរន្តរ៍រៀងទៅ កុំបីឃ្លាតឃ្លាយទៅជាប្រការដទៃឡើយ ។

ចប់សុន្ទរកថាលោក យួន - ណៃ

## សុន្ទរកថា ព្រះតេជព្រះគុណព្រះអរិយកស្សប អ៊ុប

ខ្ញុំព្រះករុណា អាត្មាភាពក្នុងនាមនៃព្រះសង្ឃគណៈធម្មយុត្តិកនិកាយ បានត្រូវឯកឧត្តមអធិបតី នៃសមាគមគិលានសង្គ្រោះនិមន្តមកកាន់សន្និបាតក្នុងថ្ងៃនេះ ដើម្បីថ្លែងនូវសុន្ទរកថាមួយតាំងនាមនៃព្រះសង្ឃគណៈធម្មយុត្តិទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសនៃពិធីសម្ពោធនូវមន្ទីរពេទ្យព្រះសង្ឃនេះ ។

បពិត្រព្រះនរបតី !

បពិត្រសម្ដេចជាអម្ចាស់ !

ព្រះករុណាគ្រប់ព្រះអង្គ !

ទ្រង់ឯកឧត្តម អស់លោក · អ្នកគង់ជ្រាបបានយ៉ាងជាក់ច្បាស់ហើយថា គិលានុបដ្ឋាកដែលសម្រាប់ទំនុកបម្រុងព្រះសង្ឃពុទ្ធសាសនិកនៅប្រទេសយើង បានវិនាសបាត់បង់ទៅជាច្រើនរយឆ្នាំណាស់មកហើយ ។ ទើបតែមកដល់រជ្ជកាលនៃព្រះបាទសម្ដេចព្រះនរោត្តមសីហនុវរ្ម័ន និងក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះនរោត្តមសុរាម្រិត ព្រះចៅព្រះរាជាណាចក្រយើងសព្វថ្ងៃនេះ ព្រះពុទ្ធសាសនានៅប្រទេសយើង ក៏ត្រូវបានជួបប្រទះនឹងសេចក្ដីចំរើនរុងរឿងឡើងវិញ ស្មើរតែប្រៀបធៀបទៅនឹងសេចក្ដីចំរើនរុងរឿងនាសម័យព្រះបាទជយវរ្ម័នទី ៧ បាន, ដោយសារតែព្រះប្រិយមហាក្សត្ររបស់យើងទ្រង់ជាពុទ្ធសាសនូបត្ថម្ភ ។

ឯសេចក្ដីចំរើន ដែលបានបង្ហាញនូវរូបរាងឲ្យយើងបានឃើញជាក់ច្បាស់ នឹងចក្ខុប្រសាទក្នុងបច្ចុប្បន្នសម័យនេះ គឺស្ថាបនានូវមន្ទីរ

ពេទ្យព្រះសង្ឃ ដែលព្រះករុណា គ្រប់ព្រះអង្គ ទ្រង់ឯកឧត្តមទាំងអស់លោក អ្នកបានជួបប្រទះក្នុងថ្ងៃនេះឯង ។

រីឯមន្ទីរពេទ្យសម្រាប់ព្រះសង្ឃពុទ្ធសាសនិក ដែលបានចាប់កំណើតជាថ្មីឡើងវិញ នៅក្នុងចំណោមនៃសេចក្តីក្រខ្សត់របស់ពួកពុទ្ធបរិស័ទគ្រប់រូបយ៉ាងនេះបាន, តាមដែលខ្ញុំព្រះករុណា-អាត្មាភាព បានសង្កេតឃើញដោយជាក់ច្បាស់ថា មិនគួរណានឹងឧប្បត្តិកើតឡើងបានឡើយ, ព្រោះអីបើព្រះករុណា គ្រប់ព្រះអង្គ - ទ្រង់ - ឯកឧត្តម - អស់លោក - អ្នកផ្ទៀងនេត្រាសំឡឹងមើលទៅខាងអតីតកាលដែលកន្លងទៅហើយថ្មីៗនេះ គង់នឹងឃើញបានថា ប្រទេសយើងបានកប់ប្រទះនឹងឧបសគ្គដ៏អព្ភមង្គលយ៉ាងសម្បើមក្រៃលែង ដែលនាំឲ្យពុទ្ធមាមកជនយើង ដល់នូវសេចក្តីលំបាកច្រើនប្រការ ហួសវិស័យនឹងពណ៌នាឲ្យសព្វគ្រប់បាន ។

ប៉ុន្តែជាភ័ព្វល្អ ដែលបណ្តាលឲ្យប្រទេសយើងត្រូវតែបានជួបប្រទះនឹងសេចក្តីចំរើន, ទោះបីនៅក្នុងទេសៈកាលៈដ៏គ្រៀមក្រំដូចម្តេចក៏ដោយ ព្រះពុទ្ធសាសនាដែលជាសាសនាប្រចាំរដ្ឋរបស់យើង ក៏ត្រូវតែចំរើនរុងរឿងឡើងវិញ តាមសភាពរបស់ប្រទេសឥតមានអ្វីមកពាំងស្ទះបានឡើយ ដោយសារតែព្រះបរិយមហាក្សត្រជាទីស្នេហានិងព្រះរាជ-រដ្ឋាភិបាលរបស់យើងបានជួយទំនុកបម្រុង ។

ទើបក្នុងឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ ដែលកន្លងទៅហើយនោះ ឯកឧត្តមយួន-ណៃ ដែលជាប្រធាននៃសមាគមគិលានសង្គ្រោះព្រមទាំងសហការីទាំងឡាយនៃសមាគមនេះ មុនពេលដែលនឹងបង្កើត

ជាសមាគមមានចិត្តគិតនឹកជានិច្ចដល់សេចក្តីមិនទៀងទាត់ នៃសង្ខាររបស់ខ្លួន ៗ ថា រមែងមានសេចក្តីប្រែប្រួលទៅជាធម្មតា ដោយសារតែការកើត ចាស់-ឈឺ-ស្លាប់ ដែលនាំឲ្យសត្វលោកភិតភ័យ ហើយផុតវិស័យនឹងគេចវេះចៀសរួចបាន ។

កាលបើគំនិតយ៉ាងនេះកើតឡើង, ឯកឧត្តមក៏ពុំបានបំភ្លេចចោលឡើយ ខំប្រឹងប្រែងលុះត្រាតែបានសម្រេចនូវគោលបំណងយ៉ាងធំទូលាយ គឺការកសាងនូវមន្ទីរពេទ្យព្រះសង្ឃ ដែលឯកឧត្តមយល់ឃើញថាជាមហាកុសលមួយយ៉ាងធំបំផុត អាចកំចាត់បង់នូវទុក្ខសោកភេកភ័យរបស់ខ្លួនទៅអនាគតបាន ។ ឯកឧត្តមតាំងផ្តើមបង្កើតជាសមាគមមួយ ដើម្បីសាងនូវមន្ទីរពេទ្យមួយខ្នងសម្រាប់ទំនុកបំរុងព្រះពុទ្ធសាសនិក ។

បពិត្រព្រះនរបតី !

ព្រះករុណាគប់ព្រះអង្គ !

ទ្រង់, ឯកឧត្តម, អស់លោក-អ្នក !

ការស្ថាបនានូវមន្ទីរពេទ្យសម្រាប់ព្រះសង្ឃ ដែលប្រកបដោយជាន់ ៤ និងទំហំយ៉ាងធំល្វឹងល្វើយ ហើយប្រកបទៅដោយលំអរឆើតឆាយស្រស់បំព្រងយ៉ាងទាន់សម័យនេះ បានឲ្យខ្ញុំព្រះករុណាអាត្មាភាព ដែលបានមកប្រទះឃើញច្បាស់នឹងភ្នែករបស់ខ្លួនក្នុងពេលនេះ មានសេចក្តីរំភើបស្ញប់ស្ញែងក្នុងចិត្តយ៉ាងក្រៃលែង គួរឲ្យពោលសរសើរនូវស្នាដៃនៃឯកឧត្តម ឃួន-ណៃ ព្រមទាំងសហការីទាំងឡាយនៃសមាគម ដែលបេះ

ប្រមូលផ្តុំនូវកំឡាំងសាមគ្គីនៃពុទ្ធបរិស័ទគ្រប់ជាន់គ្រប់ថ្នាក់ ឲ្យបេះស្គាល់នូវជំនឿនៃព្រះពុទ្ធសាសនារបស់ខ្លួន ។

បពិត្រព្រះនរបតី ! បពិត្រសម្តេច !

ព្រះករុណាគ្រប់ព្រះអង្គ ! ទ្រង់, ឯកឧត្តម, អស់លោក-អ្នក !

នៅទីបំផុតនៃសុន្ទរកថានេះ ក្នុងនាមនៃព្រះសង្ឃគណៈធម្មយុត្តិក-និកាយ ខ្ញុំព្រះករុណាអាត្មាភាព សូមសំបូងសំរូងដល់គុណព្រះរតនត្រ័យទាំង ៣ ប្រការ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយនឹងវត្ថុស័ក្តិសិទ្ធិទាំងអម្បាលម៉ានដែលមាននៅក្នុងពិភពលោកនេះ សូមជួយអភិបាលនូវព្រះប្រិយមហាក្សត្រទាំង ៣ ព្រះអង្គរបស់យើង ព្រមទាំងព្រះរាជរដ្ឋាភិបាលរបស់ព្រះអង្គ សូមទ្រង់បានប្រកបដោយសេចក្តីសុខក្នុងព្រះសេរីរាជ-សម្បត្តិគ្រប់កាលទាំងពួង កុំបីមានសឹកសត្រូវណាមួយមកបៀតបៀនព្រះអង្គ ព្រមទាំងព្រះរាជវង្សានុវង្សនឹងប្រជារាស្ត្ររបស់ព្រះអង្គបានឡើយ ។

ហើយសូមឲ្យឯកឧត្តមអធិបតីនៃសមាគមគិលានសង្គ្រោះ ព្រមទាំងសមាជិកទាំងឡាយនៃសមាគមនេះ ហើយនឹងទ្រង់ឯកឧត្តម, អស់លោក-អ្នក ដែលបានស្តេចយាង-អញ្ជើញមកកាន់ទីសន្និបាតនេះ បានប្រកបដោយសេចក្តីសុខដ៏គាប់ប្រសើរ ប្រាសចាកទុក្ខសោករោគភ័យចង្រៃឧបទ្រពគ្រប់ប្រការ សមតាមប្រាថ្នានៃទ្រង់, ឯកឧត្តម, អស់លោក-អ្នកកុំបីឃ្លៀងឃ្លាត ។ ហើយសូមឲ្យទេវតាទាំង ១ មុឺនលោកធាតុជួយគាំទ្រសមាគមគិលានសង្គ្រោះនេះ ឲ្យមានអាយុគ្រប់ ៥ ពាន់ព្រះវស្សា កុំបីឃ្លាតឡើយ ។

# ពិធីបុណ្យព្រហ្មទានលើកទី ៧
# នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ

ប្រគេនរង្វាន់ដល់សមណនិស្សិតដែលប្រឡងចេញពីពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

## លោក ហាប់-ពិន រៀបរៀង

---

កាលពីថ្ងៃទី ២៦ កុម្ភៈ ព.ស. ២៤៩៨ គ.ស. ១៩៥៦,

នៅបរិវេណពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានធ្វើពិធីបុណ្យព្រហ្មទានប្រគេនសមណនិស្សិតដែលប្រឡងចេញពីពុទ្ធិកវិទ្យាល័យនេះ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

បុណ្យនេះជាបុណ្យព្រហ្មទានលើកទី ៧ នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ ដែលមានលោក ញ៉យ-ប៊ុក ជាប្រធាន និងក្រុមអភិបាលសមាគមនេះ បានធ្វើរួមជាមួយពុទ្ធបរិស័ទអ្នកជ្រះថ្លាក្នុងឧត្តមគតិនេះ, គេផ្តើមធ្វើពីល្ងាចថ្ងៃសៅរ៍ទី ២៥ កុម្ភៈ ១៩៥៦ ដោយកម្មវិធីនិមន្តព្រះសង្ឃចម្រើនព្រះបរិត្តរួចនិមន្តព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតសំដែងធម៌ ។

នៅថ្ងៃអាទិត្យទី ២៦ កុម្ភៈ វេលារសៀលម៉ោង ១៦ សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះថេរៈមួយអង្គតំណាងព្រះសង្ឃនាយកស្តីទីគណៈធម្មយុត្តិ, សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម, ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ព្រះមហាព្រហ្មមុនី ទេព-អ៊ួ ចាងហ្វាងរង,

ព្រះរាជាគណៈឋានានុក្រម, សាស្ត្រាចារ្យទាំងបព្វជិតទាំងគ្រហស្ថ ព្រមទាំងសមណនិស្សិតដែលត្រូវទទួលព្រហ្មទាន បាននិមន្ត-បានអញ្ជើញមកជួបជុំកងទីសន្និបាតនេះ ។

នៅថ្ងៃដដែល វេលាម៉ោង ១៦ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងស្ដេចយាងដល់ ដោយមានសម្ដេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រឹង្គារ ប៉ែន-នុត, លោក យឹម-ទិត, ឯកឧត្ដមប្រាក់-ប្រាព្រឿង, ឯកឧត្ដមសម-សារី សមាជិកក្រុមប្រឹក្សាព្រះរាជា, លោក ស៊ឹម-វ៉ា ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ, លោក អ៊ុំ-ឈាងស៊ុន ប្រធានរដ្ឋសភា និងវរជនជាច្រើនរូបក្រៅពីនេះ ដែលយើងសូមអភ័យទោសដោយពុំបានបញ្ចេញនាមសព្វគ្រប់ បានអញ្ជើញមកជួបជុំជារាជបរិវារ ។

បន្ទាប់ពីពេលធ្វើគារវកិច្ចចំពោះព្រះរាជាតាមប្រពៃណី, លោកកែយ-ប៉ុក ប្រធានសមាគមបានថ្វាយសុន្ទរកថា ទទួលអំណរស្វាគមន៍ព្រះរាជា និងថ្វាយពត៌មានតាមដែលសមាគមបានផ្ដើមធ្វើព្រហ្មទាន ។ រួចហើយ ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត បានថ្វាយសុន្ទរកថាពណ៌នាអំពីព្រឹត្តិការណ៍នៃពុទ្ធិកវិទ្យាល័យនេះនឹងព្រហ្មទាន ។ បន្ទាប់ពីនេះ ព្រះរាជាទ្រង់ថ្វាយព្រះរាជសុន្ទរកថាតប; ក្នុងព្រះរាជសុន្ទរកថានោះទ្រង់ព្រះរាជទានព្រះបរមរាជោវាទ រំលឹកសមណនិស្សិតឲ្យប្រព្រឹត្តតាមព្រះពុទ្ធឱវាទ ដើម្បីឲ្យចំរើនទាំងផ្លូវលោកផ្លូវធម៌ ដល់ប្រទេសជាតិ ។

លុះចប់ព្រះរាជសុន្ទរកថា, គណៈកម្មការបុណ្យព្រហ្មទានបានកាន

ថ្វាយនូវបញ្ជីរាយនាមសមណនិស្សិតដែលជាប់សញ្ញាប័ត្រលេខ ១ ហើយលើកព្រហ្មទានទី ១ ថ្វាយព្រះរាជា ។ ទ្រង់ទទួលហើយទ្រង់ប្រគេនដល់សមណនិស្សិតនោះ ។ បន្ទាប់ពីនោះ គណៈកម្មការបានអានជូននូវបញ្ជីរាយនាមសមណនិស្សិតដែលជាប់សញ្ញាប័ត្រតមក និងលើកព្រហ្មទានជូនវេនទាំងឡាយមានសម្តេចចៅហ្វាវាំងជាដើមឲ្យប្រគេនសមណនិស្សិតតាមលំដាប់លេខរៀង ព្រមទាំងអញ្ជើញពុទ្ធបរិស័ទជាម្ចាស់ព្រហ្មទានឲ្យប្រគេនដរាបដល់គ្រប់ចំនួនសមណនិស្សិតត្រឹម ២០ រូប តាមដែលគណៈកម្មការបានកំណត់ទុកថាត្រូវផ្អាកការប្រគេន ១ លើក ដើម្បីថ្វាយព្រះរាជឱកាសចំពោះព្រះរាជាស្តេចយាងទៅ កុំបាច់គង់ចាំយូរនាំពិបាកព្រះអង្គ, ចាំព្រះរាជាស្តេចយាងចេញហើយ ទើបប្រគេនតទៅទៀត ។ លុះចប់កិច្ចប្រគេនព្រហ្មទានលើកទី ១, សំឡេងស្វាធ្យាយជយន្តោ នៃព្រះសង្ឃក៏លាន់ឮរំពងឡើង ដែលនាំឲ្យកើតបីតិប្រាមោជដល់អ្នកស្តាប់យ៉ាងក្រៃលែង ។ កាលចប់ការស្វាធ្យាយន៍នៃព្រះសង្ឃ, ពុទ្ធបរិស័ទបានឧទ្ទិសផលដោយបត្តិទានគាថា ( យំកិញ្ចិ ) ។ លុះព្រះរាជាស្តេចយាងហើយ គណៈកម្មការបានផ្តើមប្រគេនព្រហ្មទានម្តងទៀតជាលើកទី ២ ដរាបដល់គ្រប់ចំនួនសមណនិស្សិតដែលប្រឡងជាប់ទាំង ៥២ រូប ។

ពិធីបុណ្យនេះបានបញ្ចប់នៅវេលាម៉ោង ១៧ កន្លះ ប្រកបដោយបរិយាកាសដ៏រីករាយមហិមា ។